# កម្មវិធីស្ត្រី ដើម្បីការផ្លាស់ប្តូរ





# ខ្ញុំមកសុំទាននៅទីក្រុង ពីព្រោះ ...

**ខែមិនា ឆ្នាំ ២០០២**

**ភ្នំពេញ-កម្ពុជា**

# អារម្ភកថា

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលប្រឈមមុខទៅនឹងបញ្ហាជាច្រើន ហើយបញ្ហាមួយក្នុងចំណោមបញ្ហាធំៗទាំងនោះគឺការកើនឡើងនូវភាពក្រីក្រ ជាពិសេសគឺស្ត្រីក្រីក្រ ។ នៅក្នុងគ្រួសារ ស្ត្រីគឺជាអ្នកទទួលខុសត្រូវខាងផ្នែកសុខមាលភាពនិងការផ្គត់ផ្គង់ម្ហូបអាហារ ដូច្នេះពួកគេត្រូវតែស្វែងរកជំរើសចុងក្រោយដើម្បីរកលុយមកចិញ្ចឹមគ្រួសារ ហើយជំរើសមួយក្នុងចំណោមជំរើសជាច្រើននោះគឺមុខរបរសុំទាន ។ សព្វថ្ងៃនេះ ចំនួនអ្នកសុំទានមានការកើនឡើងយ៉ាងខ្លាំងនៅទីក្រុងភ្នំពេញ ហើយភាគច្រើននៃអ្នកសុំទានទាំងនោះគឺជាស្ត្រី ។ កំណើននេះ មានសារៈសំខាន់ខ្លាំងណាស់សំរាប់កម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ ដោយសារតែវាជះឥទ្ធិពលយ៉ាងខ្លាំងទៅលើស្ត្រីខ្មែរ ។

កម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរគឺធ្វើការជាមួយស្ត្រីរកស៊ីផ្លូវភេទ កម្មការិនីរោងចក្រ ស្ត្រីនៅតាមមូលដ្ឋាន និងស្ត្រីមានវិបត្តិ ក្នុងគោលបំណងស្វែងយល់ពីបញ្ហាទាំងឡាយដែលប៉ះពាល់ទៅលើស្ត្រី និងដើម្បីធ្វើឱ្យមានការប្រសើរឡើងនូវការផ្តល់ដំណឹងអំពីការធ្វើអន្តរាគមន៍នៃការអភិវឌ្ឍន៍ ដែលអាចធ្វើឱ្យមានការរីកចំរើនទាំងលក្ខខ័ណ្ឌនិងការជីវិតរបស់ស្ត្រីខ្មែរ ។ កម្មវិធីយើងគាំទ្រ/សំរបសំរួលនូវដំណើរការនៃការពង្រឹងភាពម្ចាស់ការដល់ស្ត្រីទាំងនេះ តាមរយៈការផ្តល់ឱកាសដល់ពួកគេដើម្បីធ្វើការចែករំលែកនូវបទពិសោធន៍ រៀនពីគ្នាទៅវិញទៅមក និងតាមរយៈការបើកវគ្គបណ្តុះបណ្តាលឬសិក្ខាសាលាផ្សេងៗ ។

កាលពីដើមខែមិនា ឆ្នាំ២០០២ ក្រុមការងាររបស់កម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ បានចាប់ផ្តើមធ្វើការស្រាវ-ជ្រាវមួយជាមួយអ្នកសុំទាន ក្នុងគោលបំណងស្វែងយល់ពីមូលហេតុនិងកត្តាដែលរុញច្រាន និងអូសទាញស្ត្រីទាំងនោះឱ្យក្លាយទៅជាអ្នកសុំទាន និងដើម្បីសិក្សាអំពីឧបសគ្គដែលពួកគេប្រឈមមុខ ។ ការសិក្សាស្រាវជ្រាវនេះគឺផ្តោតទៅលើយេនឌ័រ ភាពក្រីក្រ និងវិសមភាពយេនឌ័រ ។

ក្រុមស្រាវជ្រាវមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយសារស្ត្រីសុំទានទាំងនោះហ៊ាននិយាយយ៉ាងបើកចំហរពីកត្តាផ្សេងៗដែលជំរុញឱ្យពួកគេចាកចោលផ្ទះសំបែងនិងគ្រួសារ ។ នៅពេលរៀបចំគំរោង ពួកយើងបានគិតថាភាពក្រីក្រគឺជាមូលហេតុចម្បងដែលធ្វើឱ្យស្ត្រីទាំងនោះមកសុំទាននៅទីក្រុង ។ ប៉ុន្តែនៅមានកត្តាដទៃជា

ច្រើនទៀត ដូចជាអំពើហិង្សាក្នុងគ្រួសារ ភាពគ្មានដីធ្លី ប្តីបោះបង់គ្រួសារ និងជាពិសេសការជំពាក់បំណុល ក៏ជាកត្តាសំខាន់ផងដែរ ។ ពតិមានទាំងនេះបានធ្វើអោយក្រុមផ្លាស់ប្តូរនូវយុទ្ធវិធីក្នុងការស្រាវជ្រាវ ។

ជាទីបញ្ចប់នេះ ក្រុមការងារយើងសង្ឃឹមយ៉ាងមុតមាំថាការសិក្សាស្រាវជ្រាវនេះ នឹងក្លាយជាជំនួយមួយដែលជួយឱ្យអស់លោកអ្នកបានយល់កាន់តែច្បាស់ពីបញ្ហាទាំងឡាយដែលស្ត្រីខ្មែរ ជាពិសេសគឺស្ត្រីសុំទានកំពុងប្រឈមមុខដោះស្រាយ ។

# បុព្វកថា

យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះស្ត្រីសុំទានទាំងអស់ ដែលបានផ្តល់ឱកាសដល់ក្រុមការងារយើងបានជួបនិយាយ និងសំភាសន៍ជាមួយ ។ សូមថ្លែងអំណរគុណផងដែរ ដល់លោកស្រីរ៉ូសាណា បាប៊ីរ៉ូ អ្នកសំរបសំរួលកម្មវិធីស្ត្រីដើម្បីធ្វើការផ្លាស់ប្តូរ និងលោកស្រីម៉ាហ្គរីតា ម៉ាហ្វី ទីប្រឹក្សានៃកម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ និងអ្នកស្ម័គ្រចិត្តទាំងអស់។

# ផ្នែកទី១: ការពណ៌នាពីការសិក្សាស្រាវជ្រាវ

## ១. អារម្ភកថា

យោងទៅតាមលទ្ធផលនៃ "**ការសិក្សាស្រាវជ្រាវពីស្ត្រីកម្មករនៅក្នុងឧស្សាហកម្មកាត់ដេរនៅកម្ពុជា** " របស់កម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ យើងឃើញថាភាគច្រើននៃកម្មករទាំងនោះ គឺសុទ្ធសឹងតែជាស្ត្រីវ័យក្មេង ដែលមានអាយុក្រោម២៥ឆ្នាំ ដែលមកពីគ្រួសារដែលមានជីវភាពដុនដាបនៅជនបទ ។ ក្រោយពេលដែលពួកគេបានចូលបំរើការងារនៅក្នុងរោងចក្រ កម្មការិនីទាំងនោះតែងតែចាយវាយប្រាក់កាសយ៉ាងត្បិតត្បៀតជាទីបំផុត ដើម្បីសន្សំប្រាក់ផ្ញើទៅឪពុកម្តាយ និងក្រុមគ្រួសាររបស់គេនៅស្រុកកំណើត។

ការធ្វើស្រែចំការនៅក្នុងភូមិមិនបានផលល្អ ដោយសារតែគ្រោះមហន្តរាយទឹកជំនន់ និងភាពរាំងស្ងួត ហើយកត្តាទាំងនេះបានធ្វើឱ្យឪពុកម្តាយរបស់កម្មការិនីទាំងនោះ កាន់តែពឹងផ្អែកខ្លាំងឡើងៗមកលើប្រាក់ខែ ដែលកូនស្រីផ្ញើរមកឱ្យជារៀងរាល់ខែ ។ ក្នុងចំណោមកម្មការិនី១៥០នាក់ដែលក្រុមការងារបានជួបសម្ភាសន៍ គឺមានកម្មការិនីជាច្រើនមកពីខេត្តព្រៃវែង និង ខេត្តស្វាយរៀង ។ ក្រោយពីការចុះទៅធ្វើការនៅក្នុងភូមិ ដែលជាស្រុកកំណើតរបស់កម្មករិនីភាគច្រើនគឺខេត្តព្រៃវែង ក្រុមការងារយើងក៏បានឃើញនិងដឹងពីស្ថានភាពរស់នៅជាក់ស្តែងរបស់កសិករ យើងក៏បានសំរេចយកខេត្តព្រៃវែងនេះ ធ្វើជាខេត្តគោលដៅសំរាប់ការសិក្សាស្រាវជ្រាវខាងផ្នែកកសិកម្មគឺទាក់ទងទៅ " **ស្ត្រីនិងស្រូវ** " ។

ក្រុមការងារសិក្សាស្រាវជ្រាវរបស់យើងបានចុះទៅដល់ភូមិ-ឃុំ របស់កម្មការិនី ហើយបានជួបសំណេះសំណាលជាមួយឪពុកម្តាយរបស់ពួកគេ ។ ពួកយើងក៏បានសាកសួរផងដែរ នូវពតិមានទាក់ទងនឹងមូលហេតុដែលបណ្តាលឱ្យពួកគាត់សំរេចចិត្តបញ្ជូនកូនស្រីដែលនៅក្មេងៗ ឱ្យមកចូលបំរើការងារនៅក្នុងរោងចក្រនៅឯទីក្រុងភ្នំពេញ ។ តាមប្រសាសន៍របស់អ្នកភូមិ បានប្រាប់អោយយើងដឹងថា :

- ចំពោះគ្រួសារដែលមានកូនស្រីអាចធ្វើការបាន ឪពុកម្តាយសំរេចចិត្តបញ្ជូនកូនស្រីរបស់ខ្លួនឱ្យ មកចូលធ្វើការនៅក្នុងរោងចក្រ ព្រោះប្រសិនបើគាត់មិនបានបញ្ជូនកូនរបស់ពួកគាត់ឱ្យមកទេនោះ ពួកគាត់ពិតជាប្រឈមមុខទៅនិងការដាច់ពោះស្លាប់ ដោយសារនៅតាមស្រុកស្រែចំការនាពេលបច្ចុប្បន្ន

នេះគ្មានទឹកគ្រប់គ្រាន់សំរាប់ធ្វើស្រែចំការទេ ហើយក្រៅពីការងារស្រែចំការ គឺគ្មានការងារណាផ្សេងទៀតសំរាប់ធ្វើឡើយ ។

- ចំពោះក្រុមគ្រួសារដែលមានកូននៅតូចៗ ឪពុកម្តាយសំរេចចិត្តចាកចោលភូមិស្រុកដើម្បីមករកការងារធ្វើ ដូចជាធ្វើជាកម្មករសំណង់, កម្មករនៅក្នុងចំការកៅស៊ូ អ្នករែកដី ឬក៏ដើរសុំទានគេនៅទីក្រុងភ្នំពេញ ក្នុងគោលបំណងរកប្រាក់យកទៅចិញ្ចឹមខ្លួននិងក្រុមគ្រួសារ ។ ជំរើសដែលអ្នកភូមិខ្លះជ្រើសរើសមកដើរសុំទាននៅក្នុងទីក្រុង បានធ្វើឱ្យក្រុមការងារស្រាវជ្រាវរបស់យើងមានការចាប់អារម្មណ៍យ៉ាងខ្លាំង ហើយនេះគឺជាលើកទីមួយដែលក្រុមការងាររបស់យើងចាប់ផ្តើមចុះធ្វើការសិក្សាស្រាវជ្រាវជាមួយនិងអ្នកសុំទាន។

ដូចដែលបានជំរាបជូននៅក្នុងអារម្ភកថារួចមកហើយ កម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរក៏បានធ្វើការជាមួយស្ត្រីរកស៊ីផ្លូវភេទនិងស្ត្រីនៅតាមមូលដ្ឋានផងដែរ ហើយតាមរយៈបទពិសោធន៍ជាច្រើនដែលយើងបានសិក្សាស្វែងយល់អំពីស្ត្រីទាំងនោះ យើងសង្កេតឃើញថាបញ្ហាដែលពួកគេកំពុងតែជួបប្រទះនោះ គឺប្រហាក់ប្រហែលគ្នាខ្លាំងណាស់ ។ ស្ត្រីគឺជាក្រុមដែលងាយទទួលរងគ្រោះជាងគេ ហើយងាយក្នុងការរងនូវការកេងប្រវ័ញ្ចជាងគេនៅក្នុងគ្រប់ស្ថានភាពផ្សេងៗ ទោះបីជាពួកគេជាស្ត្រីរកស៊ីផ្លូវភេទ កម្មការិនីរោងចក្រ ស្ត្រីនៅតាមជនបទនិង/ឬអ្នកសុំទានក៏ដោយ ។ កត្តាដែលបាននិងកំពុងតែរុញច្រាន និងអូសទាញពួកគេឱ្យមកធ្វើជា កម្មការិនីរោងចក្រ ស្ត្រីរកស៊ីផ្លូវភេទ ឬអ្នកសុំទាន មានដូចជាភាពគ្មានដីធ្លី អំពើហិង្សាប្រឆាំងនិងនារីភេទ ការជំពាក់បំណុល ជាពិសេសគឺភាពក្រីក្រ ។ វដ្តនៃការកើតឡើងនេះ បង្ហាញឱ្យឃើញនូវទំនាក់ទំនងដែលស្ត្រីក្រីក្រទាំងអស់តែងតែជួបប្រទះនៅក្នុងជីវិតរស់នៅរបស់ពួកគេ ។ ជាការឆ្លើយតបមកវិញ ស្ត្រីទាំងនោះត្រូវប្រឈមមុខនិងការរើសអើងពីសំណាក់អ្នកដែលរស់នៅជុំវិញរបស់ពួកគេ ហើយសង្គមបានទុកពួកគេជាមនុស្សបាតសង្គម។

## ២. គោលបំណងនៃការចុះធ្វើការស្រាវជ្រាវ

- ដើម្បីធ្វើការស្វែងយល់អំពីមូលហេតុ និងកត្តាដែលជំរុញឱ្យអ្នកភូមិសំរេចចិត្តជ្រើសយកមុខរបរសុំទាន?
- ដើម្បីធ្វើការស្វែងយល់ថា តើមានបញ្ហាអ្វីខ្លះដែលពួកគេជួបប្រទះ ក្នុងពេលដែលពួកគាត់មកដើរសុំទាន?

## ៣. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ការពិភាក្សារបស់ក្រុមស្រាវជ្រាវ

- ដើម្បីកំណត់ទីតាំងដែលអ្នកសុំទានភាគច្រើនទៅសុំទាន
- ដើម្បីកំណត់ចំនួនអ្នកសុំទានដែលត្រូវសម្ភាសន៍ ។ យើងបានសំរេចចិត្តសំភាសន៍ស្ត្រីអ្នកសុំទានចំនួន៣០នាក់ ។ យើងសំភាសន៍តែស្ត្រីអ្នកសុំទានណាដែលយល់ព្រមឱ្យយើងសំភាសន៍តែប៉ុណ្ណោះ ។
- ដើម្បីពិភាក្សាថាតើយើងគួរតែទិញអ្វីដើម្បីចែកជូនពួកគាត់ជាការតបស្នងដែលពួកគាត់បានចំណាយពេលវេលាឆ្លើយសំនួររបស់យើង ។ សំរាប់អំណោយ យើងបានសំរេចទិញរបស់របរមួយចំនួនដូចជា: មី ត្រីខកំប៉ុង សាច់ប៊ូវផ្អែម តែជួនកាលពួកយើងក៏បានអញ្ជើញពួកគាត់ឱ្យទៅស្រស់ស្រូបអាហារពេលព្រឹក ឬញ៉ាំភេសជ្ជៈជាមួយពួកយើង ។
- ដើម្បីធ្វើការសាកសួរពត៌មាន ដែលផ្តោតទៅលើបញ្ហា យេនឌ័រនិងភាពក្រីក្រ និងវិសមភាពយេនឌ័រ ។ យើងមិនបានប្រើបញ្ជីសំនួរដើម្បីសាកសួរពត៌មានពីអ្នកសុំទានទាំងនោះឡើយ ប៉ុន្តែនៅពេលដែលយើងបានជួបពួកគាត់គឺយើងចាប់ផ្តើមនិយាយសន្ទនា ឬសំណេះសំណាលជាមួយពួកគាត់និងព្យាយាមសិក្សាស្វែងយល់ពីជីវិតរបស់ពួកគាត់ ពីព្រោះពួកគាត់គឺជាអ្នកដែលដឹងច្បាស់នូវរាល់បញ្ហាទាំងឡាយដែលកើតឡើង ។
- ករណីសិក្សាជាភាសាខ្មែរនិងអង់គ្លេសត្រូវបានសរសេរឡើងបន្ទាប់យើងបានទទួលពត៌មាន

## ៤. បញ្ហាដែលជួបប្រទះនៅពេលចុះធ្វើការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវពីជីវិតរបស់អ្នកសុំទាននេះ គឺត្រូវបានរៀបចំឡើងដោយបុគ្គលិកខ្មែរនៃកម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរទាំងអស់ ។ ទោះបីជាពួកយើងបានចូលរួមធ្វើការស្រាវជ្រាវជាច្រើនដើម្បីប្រមូលពត៌មានក៏ដោយ លើកនេះគឺជាលើកទីមួយ ដែលក្រុមការងារយើងបានរៀបចំដំណើរការសិក្សាស្រាវជ្រាវនេះតាំងពីដើមរហូតដល់ចប់ដោយខ្លួនឯង ហើយយើងនៅតែយល់ថា ការសិក្សាស្រាវជ្រាវនេះគឺជាដំណើរការមួយក្នុងការព្យាយាមរៀននិងស្វែងយល់ដើម្បីឱ្យខ្លួនយើងអាចបង្កើនសមត្ថភាពបន្ថែមក្នុងកម្មវិធីផ្នែកស្រាវជ្រាវនេះ ។ នេះគឺជាបទពិសោធន៍ដ៏ល្អសំរាប់ពួកយើងសិក្សារៀនសូត្រ ទោះបីជាមានបញ្ហាខ្លះៗកើតឡើងនៅពេលដែលយើងចុះសំភាសន៍ក៏ដោយ ។ បញ្ហាទាំងនោះមានដូចជា:

- កន្លែងដែលយើងកំណត់ថាមានអ្នកសុំទានច្រើនតែបែរជាមិនសូវមានអ្នកសុំទានទៅវិញ

- ពេលដែលក្រុមស្រាវជ្រាវជួបជាមួយអ្នកសុំទាន ពួកគាត់ខ្លះបានយល់ព្រមឱ្យក្រុមការងារយើងសំភាសន៍ តែខ្លះទៀតបែរជាបដិសេធន៍មិនព្រមឱ្យពួកយើងធ្វើការសម្ភាសន៍ពួកគាត់ឡើយ ពីព្រោះពួកគាត់ខ្លាចថាយើងជាភ្នាក់ងាររបស់ប៉ូលីសឬជាបុគ្គលិកស្ថាប័នណាមួយដែលធ្វើការដើម្បីប្រមូលអ្នកសុំទានក្នុងទីក្រុង ។ ពួកគេគិតថា ក្រុមការងារយើងបន្លំខ្លួនធ្វើជាបុគ្គលិកអង្គការដើម្បីចុះចាប់ឬប្រមូលពួកគាត់យកទៅដាក់ប៉ុស្តិ៍ប៉ូលីសឬមណ្ឌលផ្សេងទៀត ។ល។ ដូច្នេះក្រុមការងារយើងក៏បានស្វែងរកមនុស្សផ្សេងទៀតដើម្បីសំភាសន៍ ។ ឆ្លៀតក្នុងឱកាសនេះ ក្រុមការងារយើងសូមលើកយកនូវឧទាហរណ៍ជាក់ស្តែងទាក់ទងទៅនឹងបញ្ហាក្នុងការចុះទៅធ្វើកិច្ចសម្ភាសន៍ដូចជា :

ថ្ងៃដំបូង ក្រុមការងារយើងបានសំរេចយកផ្សារច្បារអំពៅជាទីកន្លែងសាកល្បង ព្រោះយើងយល់ថានៅទីនោះមានអ្នកសុំទានច្រើន តែការរំពឹងទុករបស់ពួកយើងគឺមិនបានចេញជាលទ្ធផលវិជ្ជមានឡើយ ព្រោះថ្ងៃដែលពួកយើងចុះទៅដំបូងគឺជាថ្ងៃសីល ហើយអ្នកសុំទានភាគច្រើនគឺគេបាននាំគ្នាធ្វើដំណើរមកសុំនៅតាមទីវត្តអារាម ឬមុខវាំង ។ល។ ដូច្នេះពួកយើងបាននាំគ្នាដើរជុំវិញផ្សារអស់មួយសន្ទុះធំ ទើបប្រទះឃើញស្ត្រីវ័យចំណាស់ម្នាក់ដែលមានអាយុប្រហែលជា៦៥ឆ្នាំ កំពុងតែដើរសុំទាន ។ ឆ្លៀតឱកាសពេលនោះ ក្រុមការងារយើងបានដើរចូលទៅរកគាត់ហើយបានធ្វើការណែនាំខ្លួន កន្លែងធ្វើការ និងគោលបំនងរបស់ពួកយើងដែលបាននាំគ្នាចុះមកទីនេះ ? ពេលឃើញពួកយើងភ្លាម គាត់មានការភ័យខ្លាំងណាស់ រំពេចនោះគាត់ក៏បានប្រាប់យើងថា មូលហេតុដែលគាត់មកនេះគឺដោយសារតែភាពក្រីក្រ និងគ្មានកូនចៅជួយទំនុកបំរុងគាត់ ។ គាត់មិនចង់មកទេ តែឥលូវនេះប្រសិនបើពួកយើងចង់ឱ្យគាត់ត្រលប់ទៅផ្ទះវិញ ក៏គាត់សុខចិត្តទៅដែរ គឺសូមតែកុំឱ្យពួកយើងចាប់គាត់យកទៅប៉ុស្តិ៍ប៉ូលីសបានហើយ ។ ពួកយើងបានព្យាយាមនិយាយជាមួយគាត់អស់មួយសន្ទុះធំ ទើបគាត់យល់ព្រមឱ្យពួកយើងសម្ភាសន៍ បន្ទាប់មកយើងក៏អញ្ជើញអ៊ំស្រីម្នាក់នោះ ទៅពិសារអាហារពេលព្រឹកជាមួយពួកយើង គាត់ក៏យល់ព្រមទៅតែពេលដែលពួកយើងសួរគាត់ចង់ពិសារអ្វី គាត់បានឆ្លើយតបថាគាត់មិនឃ្លានទេព្រោះគាត់ហូបឆ្អែតហើយ ។ ទោះបីជាគាត់ឆ្លើយបែបនេះក៏ដោយ ក៏យើងនៅតែរិះរកមធ្យោបាយដើម្បីឱ្យគាត់ពិសារឱ្យទាល់តែបាន ព្រោះយើងដឹងថាគាត់ប្រាកដជាមិនទាន់បានពិសារអីនៅឡើយទេ ។ ក្រោយពីបានសំភាសន៍អ៊ំស្រីនោះហើយ ពួកយើងក៏បានស្វែងរកអ្នកសុំទានផ្សេងទៀត តែយើងត្រូវបានពួកគាត់ បដិសេធន៍រហូតដោយគាត់បានលើកហេតុផលថា គាត់ប្រញាប់ដើររកគ្នីគ្នា ដើម្បីធ្វើដំណើរត្រលប់ទៅស្រុកវិញ គាត់ប្រញាប់ទៅមើលកូនត្បិតកូនយំនៅឯផ្ទះ ហើយអ្នកខ្លះក៏បានបដិសេធន៍ថាខ្លួនគាត់នេះមិនមែនជាអ្នកដើរសុំទានទេ គឺគាត់កំពុងតែដើររកប្តីព្រោះវង្វេងប្តីបាត់នៅក្នុងផ្សារ ទោះបីជា

យើងដឹងច្បាស់ ថាគាត់ជាអ្នកសុំទានក៏ដោយ (មូលហេតុ ដែលយើងដឹងព្រោះយើងបានឃើញផ្ទាល់នឹងភ្នែក គឺឃើញគាត់កំពុងតែដើរសុំទានគេ) ។

## ៥. ទីកន្លែងនៃការចុះស្រាវជ្រាវ

ទីតាំងដែលពួកយើងបានចុះទៅធ្វើការស្រាវជ្រាវមានដូចជាផ្សារច្បារអំពៅ ផ្សារបឹងកេងកង ផ្សារអូឡាំពិក ផ្សារតាប៉ាង ផ្សារធំថ្មី ផ្សារកណ្ដាល តាមមាត់ទន្លេ ទល់មុខវត្តបុទុមវតី និងកន្លែងមួយចំនួន ដែលពួកគាត់ស្នាក់នៅ ។

***រូបភាពទីមួយៈផែនទីទីក្រុងភ្នំពេញបង្ហាញអំពីទីកន្លែងដែលមានអ្នកសុំទាន***



# ផ្នែកទី២ៈ ជីវិតពិតរបស់អ្នកសុំទាន

## ករណីសិក្សាទី១

នាងខ្ញុំមានអាយុ ៤៣ឆ្នាំ មានទីលំនៅនៅភូមិច្រកស្គរ ឃុំស្វាយចេក ស្រុករំដួល ខេត្តស្វាយរៀង ។ ខ្ញុំជាស្ត្រីម៉េម៉ាយ មានកូនប្រុស ២នាក់ កូនបងអាយុ ១៧ឆ្នាំ និងកូនប្អូនអាយុ ១៥ឆ្នាំ ។

នាងខ្ញុំបានមកសុំទាន(ភ្នំពេញ)នៅដើមខែមិនាគឺមកជាមួយកូនប្រុសបងរួមទាំងអ្នកភូមិ៣នាក់ផ្សេងទៀត ។ មូលហេតុ ដែលខ្ញុំមកដើរសុំទាន ព្រោះនៅក្នុងភូមិរបស់នាងខ្ញុំបានជួបប្រទះនូវគ្រោះធម្មជាតិ និងទឹកជំនន់បីឆ្នាំជាប់គ្នា ។

ដោយសារតែបញ្ហានេះហើយបានធ្វើឱ្យជីវភាពរស់នៅរបស់ពួកយើងចុះដុនដាប រហូតដល់មានពេលខ្លះខ្ញុំ គ្មានលុយទិញបាយ និងម្ហូបឱ្យកូនប្រុសទាំង២នាក់របស់ខ្ញុំហូបផង ។ ពីមួយថ្ងៃទៅមួយថ្ងៃ យើងរស់នៅក្នុងលក្ខខណ្ឌដ៏សែនលំបាក ដូច្នេះខ្ញុំក៏បានសំរេចចិត្តបញ្ចាំដីស្រែរបស់ខ្ញុំដែលមានទំហំ ២០អា ទៅឱ្យអង្គការគណៈកម្មការសុខភាពប្រជាជនកម្ពុជា ក្នុងទឹកប្រាក់ចំនួន ៥០០,០០០រៀល ដោយក្នុងមួយខែខ្ញុំត្រូវបង់ថ្លៃការប្រាក់ចំនួន២០,០០០រៀល (ការប្រាក់៤%) ។ ប៉ុន្តែជារៀងរាល់ខែខ្ញុំគ្មានលទ្ធភាពរកលុយ ដើម្បីបង់ការប្រាក់នេះឡើយ ខ្ញុំក៏បានទៅខ្ចីមាស៣ជីពីអ្នកចងការប្រាក់ដែល រស់នៅក្នុងភូមិនេះដោយក្នុងមួយខែៗ ខ្ញុំត្រូវបង់ ១០,០០០រៀលថ្លៃការប្រាក់ (ក្នុង១០,០០០គេយកការប្រាក់ ២,០០០រៀល/ខែ) ។ បំណុលរបសខ្ញុំកាន់តែច្រើនឡើងៗប៉ុន្តែខ្ញុំមិនអាចរកប្រាក់បានគ្រប់គ្រាន់ដើម្បីមកដោះបំណុលបានឡើយ ដូច្នេះខ្ញុំក៏សំរេចចិត្តលក់ដី លក់គោ-ក្របី ដើម្បីយកលុយមកសងបំណុលគេតែប្រាក់ដែលខ្ញុំប្រមូលបានពីការលក់របស់របរទាំងអស់នោះនៅតែសងគេមិនគ្រប់ទៀត ។ សព្វថ្ងៃនេះខ្ញុំនៅតែជំពាក់លុយ គណៈកម្មការសុខភាពគ្រួសារប្រជាជនកម្ពុជា ចំនួន២០០,០០០រៀលថែមទៀត ។ មុនពេលដែលខ្ញុំបានចាកចេញមកសុំទាននៅទីក្រុង ខ្ញុំបានខ្ចីលុយ១៥,០០០រៀលពីអ្នកជិតខាងសំរាប់ធ្វើសាហ៊ុយមកភ្នំពេញ ដោយក្នុងមួយម៉ឺនរៀលគេយកការប្រាក់៣,០០០ រៀលក្នុងមួយខែ ។

ជារៀងរាល់យប់ខ្ញុំស្នាក់នៅជិតក្បែររបងមន្ទីរពេទ្យគន្ធៈបុប្ផាជិតព្រះបរមរាជវាំង ។ ក្នុងមួយថ្ងៃខ្ញុំនិងកូនប្រុសរបស់ខ្ញុំទាំងពីរនាក់ម្តាយកូនអាចរកលុយបាន២,០០០-៣,០០០រៀល ក្នុងនោះគឺខ្ញុំចំណាយ១,០០០រៀលដើម្បីទិញម្ហូបហើយប្រាក់ដែលនៅសល់គឺសន្សំទុកយកទៅសងបំណុលគេ ។

ជាចុងបញ្ចប់ខ្ញុំសូមធ្វើការអំពាវនាវដល់អង្គការក្រៅរដ្ឋាភិបាល និងរដ្ឋាភិបាលមេត្តាជួយពួកខ្ញុំផង ពីព្រោះពួកយើងខ្ញុំកំពុងតែយ៉ាប់យ៉ឺន ហើយថែមទាំងគ្មានលទ្ធភាពរកលុយដើម្បីបញ្ជូនកូនឱ្យទៅរៀនសូត្រនឹងគេ ។

&& ☆☆☆ &&

# ករណីសិក្សាទី២

꧁✧꧂

នាងខ្ញុំមានអាយុ ៧០ឆ្នាំ មានទីលំនៅនៅភូមិបង្ក្រែ ឃុំអង្គរសរ ស្រុកមេសាង ខេត្តព្រៃវែង។ សព្វថ្ងៃនេះខ្ញុំរស់នៅតែម្នាក់ឯងព្រោះប្តី និងកូន៧ខ្ញុំបានស្លាប់អស់តាំងពីសម័យប៉ុលពត ។

កាលពីមុនជំនាន់ប៉ុលពត ខ្ញុំមានដីធំណាស់ដោយសារខ្ញុំមានកូនច្រើន ប៉ុន្តែនៅពេលដែលកូនរបស់ខ្ញុំស្លាប់អស់ដីរបស់ខ្ញុំក៏ត្រូវបានគេយកអស់ ហើយសព្វថ្ងៃនេះខ្ញុំមានដីស្រែត្រឹមតែ៥អាប៉ុណ្ណោះ។ ខ្ញុំគ្មានកំលាំងកំហែងឯណាមកធ្វើស្រែទៀតឡើយ ព្រោះខ្ញុំចាស់ណាស់ទៅហើយម្យ៉ាងគ្មានលុយទិញពូជនិងជីទៀត ។ ដូច្នេះខ្ញុំក៏បានបង្វាស់វែសនេះទៅឱ្យអ្នកភូមិឯទៀតធ្វើ លុះពេលគេច្រូតស្រូវរួចអស់កាលណាទើបយើងវាល់ស្រូវចែកគ្នាក៏ប៉ុន្តែស្រូវដែលខ្ញុំទទួលបាននោះខ្ញុំហូបមិនគ្រប់ឡើយ ព្រោះខ្ញុំហូបបាយម្តង៧ច្រើនណាស់ ។

នៅក្នុងភូមិរបស់ខ្ញុំពេលមាននរណាម្នាក់ទៅចែកអំណោយដល់ប្រជាជនក្នុងភូមិម្តង៧ ប្រធានឃុំនិងប្រធានភូមិមិនដែលមកហៅអ្នកក្រឱ្យទៅបើកអំណោយឡើយ គឺពួកគាត់ហៅតែអ្នកណាដែលមាន ឬអ្នកដែលមានជីវភាពគ្រាន់បើ ចំណែកអ្នកណាដែលក្រគឺពួកគាត់ផាត់ចោល ។ ខ្ញុំខឹងនឹងពួកគាត់ខ្លាំងណាស់ ។

ដោយសារតែគ្មានស្រូវគ្រប់គ្រាន់សំរាប់ហូបនិងដោយសារតែមួម៉ៅខឹងប្រធានភូមិពេក ខ្ញុំក៏បានទៅខ្ចីលុយអ្នកនៅក្នុងភូមិជាមួយចំនួន ៥០,០០០រៀលដោយមិនយកការប្រាក់ សំរាប់ធ្វើសាហ៊ុយមកសុំទាននៅភ្នំពេញ ។ ខ្ញុំបានមកជាមួយអ្នកភូមិដទៃទៀត ព្រោះខ្ញុំមិនហ៊ានមកម្នាក់ឯងទេខ្ញុំខ្លាចហើយណាមួយ ខ្ញុំមិនស្គាល់ទីតាំងច្បាស់ ជាពិសេសគ្មានសាច់ញាតិរស់នៅឯទីក្រុងទៀត ។ ខ្ញុំទើបតែមកបានប្រាំថ្ងៃប៉ុណ្ណោះ ពេលយប់ខ្ញុំស្នាក់នៅជិតវាំង។

ជារៀងរាល់ថ្ងៃ ខ្ញុំអាចរកលុយបានពី ២,០០០-៣,០០០រៀល ប៉ុន្តែខ្ញុំហូបច្រើនហើយខ្ញុំឈឺផងនោះ ដូច្នេះលុយដែលខ្ញុំរកបានគឺខ្ញុំបានដកមួយភាគធំយកទៅទិញម្ហូប និងថ្នាំពេទ្យលេបចំណែកប្រាក់ឯនៅសល់គឺខ្ញុំសន្សំវាទុកតែវាមិនច្រើនទេ ។

ប្រសិនបើគ្មាននរណាមកហាមខ្ញុំមិនឱ្យដើរសុំទានទេនោះ ខ្ញុំនឹងដើរសុំរហូតដល់ចាស់ព្រោះថាបើខ្ញុំមិនដើរសុំគ្មាននរណាមកចិញ្ចឹមខ្ញុំឡើយ ។ ក្នុងរយៈពេលប្រាំថ្ងៃនេះខ្ញុំធ្លាប់បានដើទៅសុំនៅផ្សារទួលទំពូង ផ្សារបឹងកេងកង និងផ្សារច្បារ អំពៅ ។

&& ☆☆☆ &&

# ករណីសិក្សាទី៣

នាងខ្ញុំមានអាយុ ៦៥ ឆ្នាំ ខ្ញុំជាស្ត្រីមេម៉ាយ សព្វថ្ងៃរស់នៅភូមិកំពង់ត្របែក ឃុំកំពង់ត្របែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។ ខ្ញុំមានកូនបីនាក់ស្រីមួយប្រុសពីរនាក់ពួកគេបានរៀបការរួចអស់ហើយ ។ កូនប្រុសរបស់ខ្ញុំម្នាក់បានទៅរស់នៅជាមួយប្រពន្ធរបស់វាឯខេត្តសៀមរាប និងម្នាក់ទៀតរស់នៅភ្នំពេញ ។ ចំណែកឯកូនស្រីរបស់ខ្ញុំវិញ ត្រូវបានប្តីស្លាប់ចោលកាលពីឆ្នាំទៅដោយបន្សល់ទុកនូវកូនបីនាក់ ហើយសព្វថ្ងៃនេះនាងព្រមទាំងកូនរបស់នាងបានមករស់នៅ ជាមួយខ្ញុំ ហើយសព្វថ្ងៃនេះនាងកំពុងតែឈឺទៀត ។

ដោយសារតែកូនស្រីឈឺ ខ្ញុំក៏បានសំរេចចិត្តយកដីស្រែ(១ហិចតា)ទៅបញ្ចាំគេ ក្នុងតំលៃ១ជីកន្លះមាសដើម្បីយកប្រាក់ទៅមើលជំងឺ និងទិញថ្នាំឱ្យកូនតែអាការៈរោគរបស់នាងមិនបានធូរស្រាលឡើយ ហើយនាងបានលាចាកលោកនេះទៅកាលពីខែមុន ។ រាល់ថ្ងៃនេះខ្ញុំត្រូវចិញ្ចឹមកូនទាំង៣នាក់របស់នាង ហើយពួកវាសុទ្ធតែនៅរៀនទៀត(រៀននៅ សាលាបឋម) ។

កាលពីមុនខ្ញុំនៅមានកំលាំង ខ្ញុំបានដាំត្រកួនរួចបេះយកទៅលក់នៅក្នុងភូមិហើយខ្ញុំក៏បានចិញ្ចឹមមាន់-ជ្រូក ខ្លះដែរ ។ ឥឡូវនេះខ្ញុំចាស់ហើយ ខ្ញុំគ្មានកំលាំងដើម្បីទៅជីកកាប់គាស់ដី ដើម្បីដាំដំណាំបានទៀតទេ ។ ខ្ញុំទើបតែមកសុំទាននៅភ្នំពេញនេះបាន១៥ថ្ងៃហើយ ។ មូលហេតុដែលខ្ញុំមកសុំទានគេនេះព្រោះខ្ញុំគ្មានដីសំរាប់ធ្វើស្រែ ហើយព្រមទាំងគ្មានលុយ ទិញម្ហូបនិងបាយសំរាប់ចិញ្ចឹមចៅៗនិងចំណាយទៅលើតំរូវការចាំបាច់ ។

ជារៀងរាល់យប់ ខ្ញុំស្នាក់នៅជិតផ្សារថ្មីជាមួយអ្នកសុំទានដទៃទៀត ។ ជួនកាលមានពួកជើងកាងបានមកបន្លំខ្លួនចូលដេកជិតខ្ញុំ ពួកវាបានលូកដៃចូលក្នុងហោប៉ៅរបស់ខ្ញុំដើម្បីរកលុយហើយមានយប់មួយនោះមួយក្នុងខណៈពេលដែលខ្ញុំកំពុងតែដេកលក់ ស្រាប់តែមានគេមកលួចយកលុយរបស់ខ្ញុំអស់ ៥,០០០រៀល ។ ខ្ញុំបានសំរេចចិត្តមកសុំទានដោយទុកឱ្យចៅៗចោល គ្មានអ្នកណាមើលថែទាំនៅឯផ្ទះពួកវាឡើយ នៅពេលបុណ្យចូលឆ្នាំខ្មែរខ្ញុំនឹងត្រឡប់ទៅផ្ទះវិញ ហើយខ្ញុំក៏មិនទាន់ប្រាកដក្នុងចិត្តដែរថា តើខ្ញុំនឹងត្រឡប់មកវិញឬក៏អត់នោះ ។

ខ្ញុំគិតថា នៅឆ្នាំក្រោយខ្ញុំនិងមានលទ្ធភាពសងលុយគេរួចយកដីស្រែមកវិញ ដោយខ្ញុំនឹងទៅសុំលុយពីកូនប្រុសរបស់ខ្ញុំដើម្បីយកមកលួសយកដីស្រែវិញ ដូច្នេះខ្ញុំអាចធ្វើស្រូវវស្សានៅលើដីស្រែនោះបាន ។

&& ☆☆☆ &&

# ករណីសិក្សាទី ៤

☆☆ ☆☆

នាងខ្ញុំមានអាយុ៤៧ ឆ្នាំ សព្វថ្ងៃខ្ញុំរស់នៅភូមិព្រៃពោន ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ខ្ញុំជាស្ត្រីមេម៉ាយ ប្តីរបស់ខ្ញុំបានស្លាប់កាលពីឆ្នាំមុន ពីព្រោះគាត់មានជំងឺលើសឈាម ខ្ញុំមានកូន ៥នាក់ ស្រី២ និងកូនប្រុស៣ ។

កាលពីប្តីរបស់ខ្ញុំនៅរស់ខ្ញុំនិងកូនខ្ញុំមិនដែលចាកចេញទៅរកអ្វីទេ ពីព្រោះប្តីរបស់ខ្ញុំគាត់តែងតែទៅវាលនៅជិតស្រែដើម្បីរកម្ហូប (ដូចជាចាប់ត្រីនៅក្នុងបឹង ចាប់ក្តាម-ខ្យងនៅក្នុងស្រែ)។ យើងតែងតែជួយគ្នាទៅវិញទៅមកនៅពេលរដូវធ្វើស្រែ ប៉ុន្តែបន្ទាប់ពីប្តីរបស់ខ្ញុំបានស្លាប់ទៅជីវភាពនៅក្នុងគ្រួសារបានធ្លាក់ចុះដុនដាប ពីព្រោះខ្ញុំត្រូវចិញ្ចឹមកូនតែម្នាក់ឯងព្រោះពួកគេសុទ្ធតែនៅក្មេងៗ ជាពិសេសខ្ញុំមិនមានដីសំរាប់ធ្វើស្រែទេ ខ្ញុំបានយកដីស្រែទៅបញ្ចាំឱ្យអ្នក ចងការប្រាក់នៅក្នុងតំលៃមាស៧ជី ដើម្បីព្យាបាលប្តីរបស់ខ្ញុំកាលពីគាត់ឈឺ ។ ឥឡូវនេះពួកយើងគ្មានលុយដើម្បីលោះយកដីមកវិញទេ សំណាងល្អណាស់ដោយអ្នកចងការប្រាក់គេមិនយកថ្លៃការប្រាក់ចំពោះលុយដែលខ្ញុំយកដីទៅបញ្ចាំ ប៉ុន្តែពួកគេនិងមិនឱ្យដីមកខ្ញុំវិញទេ ព្រោះពួកគេបានធ្វើស្រែលើដីនោះ រហូតដល់ខ្ញុំមានលុយសងគេគ្រប់ចំនួនមាស៧ជីទើប ពួកគេឱ្យដីនោះត្រឡប់មកវិញ ។

ខ្ញុំទើបតែមកភ្នំពេញក្នុងរយៈពេល៧ខែកន្លងមកហើយជាមួយកូនស្រីពៅរបស់ខ្ញុំដែលមានអាយុ៥ឆ្នាំ ។ កូនៗផ្សេងទៀតរបស់ខ្ញុំរស់នៅឯភូមិ ហើយកូនបងគេបង្អស់ជាអ្នកមើលថែរក្សាប្អូនៗ ។ ក្នុងរយៈពេលដែលខ្ញុំមិននៅផ្ទះ ប្រសិនបើពេលខ្លះដែលគេគ្មានអ្វីហូបទេនោះ គឺអោយពួកគេសុំសាច់ញាតិនិងអ្នកនៅជិតខាងដើម្បីហូបរយៈពេលដែលខ្វះ ។

កូនស្រីរបស់ខ្ញុំនិងខ្ញុំអាចរកលុយបានពី ២,៥០០-៣,០០០រៀលតែប៉ុណ្ណោះក្នុងមួយថ្ងៃ ហើយពួកយើងតែងតែត្រឡប់ទៅផ្ទះវិញនៅពេលណាដែលពួកយើងអាចសន្សំលុយបាន ៣០,០០០រៀល (នៅរៀងរាល់មួយខែម្តង) ពីព្រោះប្រសិនបើខ្ញុំមិនត្រឡប់ទៅផ្ទះវិញទេនោះ កូនៗរបស់ខ្ញុំប្រាកដជាគ្មានអ្វីសំរាប់ហូបឡើយ ។

ខ្ញុំបានខ្ចីលុយចំនួន ១០,០០០រៀលពីអ្នកនៅក្នុងភូមិ សំរាប់ថ្លៃធ្វើដំណើរមកភ្នំពេញ ។ សំរាប់ការប្រាក់ដែលគេគិតគឺ ៣,០០០រៀលក្នុងមួយខែ ។ ខ្ញុំប្រហែលជាមិននៅសុំទានក្នុងរយៈពេលយូរនោះទេ ពីព្រោះវាជាការ

ពិបាកណាស់សំរាប់ខ្ញុំ ហើយខ្ញុំថែមទាំងមានអារម្មណ៍ថាអៀនខ្មាស់យ៉ាងខ្លាំង នៅពេលដែលយើងលើកដៃឡើងដើម្បីសុំលុយពីមនុស្សទាំងឡាយហើយនិយាយថា "ឱ្យខ្ញុំសុំលុយ ១០០រៀលដើម្បីទិញបាយហូប" ។ នៅពេលយប់ពួកយើងស្នាក់នៅក្រោមស្ពានជ្រោយចង្វា ជាមួយនិងអ្នកសុំទានដទៃទៀតដែលខ្ញុំបានស្គាល់នៅពេលសុំទាននៅឯផ្សារថ្មីជាមួយគ្នា ។

នៅពេលរដូវវស្សាខ្ញុំនិងត្រឡប់ទៅផ្ទះវិញដើម្បីស៊ីឈ្នួល ដក ស្ទូង និងច្រូត ឱ្យអ្នកនៅក្នុងភូមិ ហើយគេឱ្យតំលៃពលកម្ម ២,០០០រៀលក្នុងមួយថ្ងៃ ដោយមានអាហារបីពេល ។

&&& ☆☆☆ &&&

# ករណីសិក្សាទី ៥

នាងខ្ញុំមានអាយុ ៣៨ឆ្នាំ ជាស្ត្រីមេម៉ាយ ហើយមានកូនស្រីម្នាក់អាយុ ៥ឆ្នាំ ។ នាងខ្ញុំរស់នៅក្នុង ភូមិត្រពាំងស្រែ ឃុំម៉ារិញ ស្រុកមេសាង ខេត្តព្រៃវែង ។

ប្តីរបស់ខ្ញុំគាត់ធ្វើទាហាន តែគាត់បានស្លាប់ហើយដោយសារជំងឺគ្រុនចាញ់ ។ សព្វថ្ងៃនេះខ្ញុំមានដីស្រែប្រវែង ៣០អា ប៉ុន្តែក្នុងរយៈពេល២ឆ្នាំកន្លងមកនេះខ្ញុំធ្វើស្រែមិនកើតសោះដោយសារភាពរាំងស្ងួត ។ ខ្ញុំគ្មានមុខរបរណាផ្សេងក្រៅពីធ្វើស្រែឡើយ ដូច្នេះនៅពេលដែលធ្វើស្រូវមិនបានខ្ញុំក៏មិនមានអ្វីហូបដែរ ។ កាលពីឆ្នាំមុនស្ថានភាពរស់នៅរបស់ខ្ញុំមាន សភាពយ៉ាប់យ៉ឺនខ្លាំណាស់ដោយមិនអាចទ្រាំរស់នៅក្នុងសភាពបែបនេះបាន ខ្ញុំក៏បានសំរេចចិត្តទៅខ្ចីលុយពីអ្នកចងការលុយ ដែលរស់នៅក្នុងភូមិជាមួយគ្នាចំនួន ៤០,០០០-៥០,០០០រៀល ដើម្បីទិញអង្ករនិងម្ហូប ដោយក្នុងមួយខែខ្ញុំត្រូវ បង់ការពី ៨០,០០០-១០,០០០រៀល (គឺគេយក២០%) ។ សព្វថ្ងៃនេះខ្ញុំនៅតែជំពាក់លុយគេដដែល ។

ដោយសារតែការជំពាក់បំណុលនេះហើយ បានជាខ្ញុំសំរេចចិត្តមកសុំទាននៅភ្នំពេញជាមួយនឹងកូនស្រីរបស់ខ្ញុំ តែខ្ញុំមិនបានដើរសុំដោយខ្លួនឯងទេ គឺខ្ញុំបានកូនស្រីរបស់ខ្ញុំជាអ្នកដើរសុំព្រោះខ្ញុំខ្មាស់គេណាស់ ណាមួយបារម្ភណ៍ខ្លាចពេលសុំទៅគេមិនឱ្យ ព្រោះខ្ញុំនៅក្មេងហើយមិនមែនជាមនុស្សពិការឯណា ។

នៅពេលដែលកូនស្រីរបស់ខ្ញុំទៅដើរសុំលុយ ខ្ញុំតែងតែអង្គុយចាំនាងនៅកន្លែងមួយដែលយើងទាំងពីរនាក់ស្គាល់ ក្នុងមួយថ្ងៃកូនស្រីរបស់ខ្ញុំអាចរកលុយបានពី ១,០០០-២,០០០ រៀលដោយក្នុងនោះខ្ញុំបានដកលុយ ១,០០០រៀល សំរាប់ទិញ បាយនឹងម្ហូបហូបទាំងពីរនាក់ម៉ែកូនហើយនៅពេលយប់ទាំងពីរនាក់ម្តាយនិងកូនបាននាំគ្នាទៅសំរាកនៅមុខសណ្ឋាគារមួយ ទល់មុខសាលាបឋមសិក្សានរោត្តម (តាមបណ្តោយផ្លូវនរោត្តម) ។ នៅពេលដែលពួកយើងសំរាកនៅទីនោះខ្ញុំមាន ភ័យខ្លាចខ្លាំងណាស់ព្រោះខ្លាចមានជនខិលខូចណា មកចាប់រំលោភនាងខ្ញុំ តែទោះបីជាមានភ័យខ្លាចយ៉ាងណាក៏ដោយក៏ខ្ញុំ ចេះតែទ្រាំដែរព្រោះនាងខ្ញុំគ្មានមធ្យោបាយណាសំរាប់ ឱ្យនាងខ្ញុំជ្រើសរើសបានឡើយ ។

ខ្ញុំបានមកភ្នំពេញនេះប្រហែលជា ២សប្តាហ៍មកហើយ ។ មុនពេលដែលនាងខ្ញុំមកនេះ នាងខ្ញុំបានខ្ចីលុយពីអ្នកជិតខាងចំនួន ៥,០០០រៀល ដើម្បីធ្វើសោហ៊ុយមក ហើយពួកយើងនឹងដើរសុំរហូតដល់ពេលចូលឆ្នាំខ្មែររួច

(ព្រោះនៅថ្ងៃបុណ្យ កូនរបស់ខ្ញុំអាចរកលុយបានច្រើន) លុះបន្ទាប់មកនៅពេលដែលយើងអាចសន្សំលុយបានច្រើន ហើយនោះពួកយើងនឹងត្រលប់ទៅផ្ទះវិញ ដើម្បីយកលុយទៅសងគេ ។

&& ☆☆☆ &&

# ករណីសិក្សាទី ៦

នាងខ្ញុំមានអាយុ ៤១ឆ្នាំ និង ប្តីរបស់ខ្ញុំអាយុ ៣៩ឆ្នាំ ។ យើងបានរៀបការជាមួយគ្នាតាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះហើយ សព្វថ្ងៃនេះយើងមានកូន ៤នាក់ (ប្រុស២ ស្រី២)។ យើងរស់នៅភូមិអង្គរសរ ឃុំអង្គរសរ ស្រុកមេសាង ខេត្តព្រៃវែង។

ខ្ញុំមកភ្នំពេញនេះជាមួយប្តី កូនប្រុសអាយុ ១០ឆ្នាំ និងកូនស្រីអាយុ ៥ឆ្នាំ ហើយពួកគេទាំងពីរនាក់ក៏ដើរសុំទានដែរ ចំណែកឯកូនស្រីម្នាក់ទៀតខ្ញុំបានទុកវាឱ្យនៅឯភូមិជាមួយកូនប្រុសច្បង និងកូនប្រសារខ្ញុំ ។

មូលហេតុដែលពួកយើងមកសុំទាននៅភ្នំពេញនេះ គឺដើម្បីមករកលុយយកទៅលោះដីស្រែដែលមានទំហំ ៤០ អា ពីអ្នកចងការប្រាក់វិញ ព្រោះកាលពីមុនខ្ញុំបានយកដីនោះទៅបញ្ចាំក្នុងតំលៃ៣-៤ជីមាស សំរាប់យកលុយមកមើលជំងឺប្តី របស់ខ្ញុំ ។ សព្វថ្ងៃនេះពួកគេកំពុងធ្វើស្រែនៅលើដីនោះ ពួកគេបានប្រាប់ខ្ញុំថា នៅពេលណាដែលខ្ញុំមានលុយខ្ញុំអាចយកលុយទៅលោះយកដីស្រែនោះមកវិញបាន ។ ជារៀងរាល់ឆ្នាំពួកយើងរស់នៅពឹងផ្អែកទៅលើផលស្រូវដែលយើងបាន ប្រមូលនៅរដូវច្រូតកាត់ និងរស់នៅទៅលើប្រាក់ចំណូលរបស់ប្តីខ្ញុំដែលបានមកពីការធ្វើកម្មករសំណង់ប៉ុន្តែគាត់បានបាត់ បង់ការងារនៅពេលដែលគាត់ធ្លាក់ខ្លួនឈឺដូច្នេះឥឡូវនេះក្នុងមួយឆ្នាំៗ ពួកយើងគ្មានរកប្រាក់ចំណូលចូលឡើយ ។

ប្តីរបស់ខ្ញុំឥឡូវបានគ្រាន់បើហើយ ហើយសព្វថ្ងៃនេះគាត់កំពុងតែដើរស្វែងរកការងារធ្វើនៅកន្លែងផ្សេងៗទៀត ប៉ុន្តែនៅមិនទាន់រកបាននៅឡើយ ។ ដូច្នេះសព្វថ្ងៃនេះពួកយើងរស់នៅគឺពឹងទៅលើកូនតូចរបស់ពួកយើងទាំងស្រុងដោយពួកវា ទាំង ២នាក់ជាអ្នកដើរសុំទានគេដើម្បីយកលុយមកចិញ្ចឹមពួកយើង ។

ពួកខ្ញុំគ្មានលុយសំរាប់ធ្វើដំណើរមកភ្នំពេញទេ ដូច្នេះពួកខ្ញុំក៏បានទៅខ្ចីលុយ ៣០.០០០ រៀលពីអ្នកនៅក្នុងភូមិដើម្បីធ្វើ សោហ៊ុយមក តែការប្រាក់ខ្ពស់ណាស់គឺ ១០.០០០រៀលគេយកការ ៣.០០០រៀល/ខែ ។

ពួកយើងមកដល់ (ភ្នំពេញ) បាន៣ថ្ងៃហើយជារៀងរាល់ថ្ងៃខ្ញុំបាននាំកូនរបស់ខ្ញុំមកសុំនៅផ្សារតាប៉ាងនៅពេលទៅដល់ទីនោះខ្ញុំអត់ដើរសុំទេគឺឱ្យកូនរបស់ខ្ញុំទៅសុំម្នាក់ឯង ។ នៅពេលបាយថ្ងៃត្រង់យើងត្រឡប់មក

កន្លែងដែលយើងស្នាក់នៅ (មុខវាំង) និងទិញបាយ-ម្ហូបដើម្បីញុំាំទាំងអស់គ្នាបន្ទាប់មកយើងត្រឡប់ទៅផ្សារតាប៉ាងម្តងទៀត ។

កូនទាំង២របស់ខ្ញុំក្នុងមួយថ្ងៃអាចរកបាន ១,000-២,000 រៀល និងពួកយើងចំណាយតែ ១,000រៀលសំរាប់ទិញបាយហូបហើយសល់ពីនោះគឺសន្សំទុក ។

ពួកយើងគិតថា នៅពេលយើងអាចសន្សំប្រាក់បានពី ៥0,000-៦0,000រៀល (ប្រាក់ដែលកូនទាំងពីររកបាន) នោះ ពួកនឹងទិញអង្ករនិងម្ហូបអាហារមួយចំនួនយកទៅផ្ញើរកូននៅឯស្រុក ពីព្រោះប្រសិនបើយើងមិនទិញទៅទេនោះ ពួកគេ នឹងគ្មានអ្វីសំរាប់ហូបទេ ។

&& ☆☆☆ &&

# ករណីសិក្សាទី ៧

នាងខ្ញុំមានអាយុ ៤៥ ឆ្នាំ ហើយប្តីរបស់ខ្ញុំមានអាយុ៤៨ ឆ្នាំ ។ យើងមានកូន៤ នាក់ ស្រីពីរ ប្រុសពីរ ។ យើងរស់នៅភូមិប៉ាយ៉ុង ឃុំទាវ ស្រុកបាភ្នំ ខេត្តព្រៃវែង។ កូនស្រីរបស់ខ្ញុំម្នាក់បានរៀបការរួចហើយ ខ្ញុំនៅមានកូននៅលីវបីនាក់ទៀត ។

ខ្ញុំមានដីស្រែទំហំ ១ ហិចតា និងដីភូមិ ទំហំ ១០ម៉ែត្រ X ១៥ ម៉ែត្រ ដែលខ្ញុំបានសង់ផ្ទះនៅ ។ ប៉ុន្តែនៅពេលដែលខ្ញុំឈឺ ខ្ញុំបានលក់ដីស្រែដើម្បីយកប្រាកមកព្យាបាលជំងឺ ។ បន្ទាប់ពីកូនស្រីរបស់ខ្ញុំរៀបការរួច ខ្ញុំគ្មានអ្វីចែកឱ្យកូនដើម្បីរកស៊ីទេ ហេតុដូចនេះហើយខ្ញុំបានយកដីភូមិទៅដាក់បញ្ចាំ ១០០ ដុល្លាជាមួយអ្នករកស៊ីចងការប្រាក់នៅក្នុង ដើម្បីយកប្រាក់មកទិញម៉ូតូឱ្យកូនប្រសារខ្ញុំរត់ម៉ូតូឌុបនៅក្នុងភូមិ ហើយគេយកការពីខ្ញុំ ២០%ក្នុងមួយខែ ។ ប៉ុន្តែឥឡូវនេះ កូនប្រសារខ្ញុំមិនអាចរត់ម៉ូតូដើម្បីជួយដោះបំណុលនេះបានទេ ដោយសារតែពេលខ្លះវាមិនអាចរកប្រាក់បានសោះក្នុងមួយថ្ងៃក៏មានដែរ ហើយបំណុលបានកើនឡើងរហូតដល់ ២៧០ ដុល្លាហើយ ។ ប្រពន្ធរបស់វាចង់ចងកសំលាប់ខ្លួនដោយសារតែបំណុលនេះ ។

ដោយសារតែមូលហេតុនេះហើយបានជាប្តីខ្ញុំ កូនតូចៗរបស់ខ្ញុំនិងខ្ញុំបានសំរេចចិត្តមកភ្នំពេញ ដើម្បីដើរសុំទានគេ ប៉ុន្តែកូនស្រីរបស់ខ្ញុំនិងប្តីរបស់វារស់នៅក្នុងភូមិ ។ នៅទីក្រុងពេលថ្ងៃពួកយើងតែងតែទៅសុំទាននៅតាមមាត់ទន្លេ ហើយទាំងខ្ញុំនិងប្តីខ្ញុំអាចរកបានពី ២,០០០-៣,០០០ រៀលនៅថ្ងៃធម្មតា ។ ប៉ុន្តែបើសិនជានៅថ្ងៃបុណ្យជាតិ ឬក៏ថ្ងៃឈប់សំរាកវិញ យើងអាចរកលុយបានច្រើន ។

យើងទើបតែមកសុំទានបានប្រហែលមួយខែប៉ុណ្ណោះ ហើយនៅពេលយប់ យើងសុំប៉ូលីសដើម្បីដេកនៅត្រង់រូបព្រះគម្លង់ ( ឈ្មោះរបស់ទីកន្លែងមួយដែលប្រជាជនតែងតែទៅបន់ស្រន់) នៅខាងមុខវត្តឧណ្ណាលោម ។

# ករណីសិក្សាទី ៨

ꕥ✧ꕥ

នាងខ្ញុំអាយុ ៨២ឆ្នាំ ជាស្ត្រីមេម៉ាយ ហើយមានកូន ៥នាក់ (ស្រី៣ ប្រុស២នាក់) ។ កូនទាំងប្រាំបានរៀបការហើយប៉ុន្តែពួកគេក្រខ្លាំងណាស់ ។ កូនស្រីម្នាក់ក្នុងចំណោមកូនទាំង៥រស់នៅជាមួយខ្ញុំចំណែក ឯកូន៤នាក់ទៀត គឺបែកផ្ទះនៅរៀងៗខ្លួនតែនៅក្នុងភូមិជាមួយគ្នា ។ ពួកយើងរស់នៅក្នុង ភូមិរាប ឃុំរាប ស្រុកពារាំង ខេត្តព្រៃវែង ។

សព្វថ្ងៃនេះខ្ញុំមានវ័យចំណាស់ណាស់ទៅហើយ តែខ្ញុំនៅតែជួយចិញ្ចឹមចៅប្រាំនាក់ និងកូនស្រីរបស់ខ្ញុំម្នាក់ដែលនាងមានអាយុ៣៣ឆ្នាំ ។ នាងក៏មេម៉ាយដូចខ្ញុំដែរហើយរាល់ថ្ងៃនេះនាងកំពុងតែដេកឈឺរ៉ាំរ៉ៃរង់ចាំតែថ្ងៃស្លាប់ ព្រោះនាងបានឆ្លងរោគពីប្តីរបស់នាងដែលកាលពីមុនប្តីរបស់នាងមានមុខរបរធ្វើជាប៉ូលីស ។ ប្តីរបសនាងបានស្លាប់រយៈពេល ៤-៥ឆ្នាំមកហើយដោយសារតែជំងឺអ្វីនោះមិនដឹងទេ ព្រោះមិនបានទៅពេទ្យពិនិត្យឈាម ។

ខ្ញុំមានដីស្រែប្រហែល៥អា ប៉ុន្តែក្នុងរយះពេល៣ឆ្នាំនេះធ្វើស្រែមិនបានសោះដោយសារតែភាពរាំងស្ងួតនិងទឹកជំនន់ ។ នាងខ្ញុំគ្មានសមត្ថភាពដាំបន្លែ ឬទៅលក់ដូរដើម្បីយកលុយមកចិញ្ចឹមកូនស្រីនិងចៅៗទាំង៥នាក់របស់ខ្ញុំបានទៀតទេ ដូច្នេះខ្ញុំក៏បានទៅខ្ចីលុយពីអ្នកភូមិចំនួន ៥០,០០០រៀលយកទិញថ្នាំពេទ្យនិងម្ហូបអាហារខ្លះៗឱ្យកូននិងចៅហូបដោយ ក្នុង ១០,០០០រៀល គេគិតការប្រាក់ពីខ្ញុំចំនួន ៣០%ក្នុងមួយខែ ។ ខ្ញុំគ្មានលទ្ធភាពនិងរកលុយឯណាមកសងគេវិញឡើយ ដូច្នេះអស់រយៈពេលមួយឆ្នាំ ហើយដែលនាងខ្ញុំនៅតែជំពាក់បំណុលលុយគេ ប៉ុន្តែខ្ញុំប្រាកដជានឹងសងគេរួចប្រសិន បើខ្ញុំសំរេចចិត្តលក់ដីស្រែរបស់ខ្ញុំនោះ ទោះបីជាយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនអាចលក់វាបានទេ ព្រោះខ្ញុំចង់រក្សាវាទុកឱ្យ ចៅៗរបស់ខ្ញុំ ។

ខ្ញុំបានសំរេចចិត្តមកភ្នំពេញដើម្បីដើរសុំទានសន្សំលុយយកទៅសងគេ និងទិញថ្នាំល្អៗយកទៅព្យាបាលជំងឺកូនស្រីរបស់ខ្ញុំ ។ ខ្ញុំបានមកភ្នំពេញនេះជាមួយនិងអ្នកភូមិ២នាក់ទៀត ហើយពួកយើងទើបតែមកដល់បាន១០ថ្ងៃប៉ុណ្ណោះ ។ ពេលយប់ ពួកយើងនាំគ្នាទៅសំរាកនៅក្បែររបងសណ្ឋាគារកាំបូឌីយ៉ាណា ។

មានថ្ងៃខ្លះខ្ញុំអាចសុំគេបានត្រឹមតែទិញបាយហូបសំរាប់មួយថ្ងៃតែប៉ុណ្ណោះ តែថ្ងៃណាដែលនាងខ្ញុំអាចសុំបានពី ១,០០០-២,០០០រៀលវិញនោះខ្ញុំតែងតែដក១,០០០រៀលទុកសំរាប់សន្សំជានិច្ច ។ ចំពោះថ្ងៃសីលខ្ញុំអាចរកបានពី ៥,០០០-៦,០០០រៀលក្នុងមួយថ្ងៃ ។

ខ្ញុំមានការព្រួយបារម្ភណ៍ខ្លាំងណាស់ចំពោះកូនស្រីនិងចៅ៧របស់ខ្ញុំដែលរស់នៅឯភូមិ ដូច្នេះរាល់ពេលដែលអ្នកភូមិជាមួយ ខ្ញុំត្រឡប់ទៅផ្ទះនោះខ្ញុំតែងតែផ្ញើរលុយតាមគេ ៥០០-១,០០០ រៀលដើម្បីយកទៅឱ្យកូនស្រីខ្ញុំទិញម្ហូបហូប ។

ចំពោះដីស្រែរបស់ខ្ញុំវិញនោះខ្ញុំគិតថា ពេលណាខ្ញុំសន្សំលុយបានច្រើនខ្ញុំច្រើន ខ្ញុំនឹងជួលអ្នកភូមិឱ្យធ្វើគ្រាន់និងបានស្រូវខ្លះ យកមកទប់ទល់ជីវភាព ។ ចំណែកឯមុខរបរដើរសុំទានសព្វថ្ងៃវិញខ្ញុំយល់ណាប្រសិនបើខ្ញុំរកលុយមិនបានទៀតទេនោះ ខ្ញុំនឹងត្រឡប់ទៅស្រុកវិញដើម្បីមើលថែទាំកូននិងចៅរបស់ខ្ញុំ ។

&& ☆☆☆ &&

# ករណីសិក្សាទី ៩

នាងខ្ញុំមានអាយុ៧០ឆ្នាំ ជាស្ត្រីមេម៉ាយមានកូនប្រុស ២នាក់ ម្នាក់អាយុ៤៥ ហើយម្នាក់ទៀតអាយុ៤០ឆ្នាំ ។ ពួកគេមាន ប្រពន្ធកូនអស់ហើយ សព្វថ្ងៃនេះគេបាននាំគ្នាមកជួលផ្ទះនៅភ្នំពេញ (តំលៃ១០ដុល្លាក្នុងមួយខែ) ដើម្បីរត់ម៉ូតូឌុបហើយ កូនប្រសារខ្ញុំម្នាក់បានចៀនចេកលក់នៅមុខផ្ទះ ។ ពួកវាទាំងពីរនាក់មិនបានយកកូនទៅនៅជាមួយទេ គឺវាទុកឱ្យខ្ញុំជាអ្នកចិញ្ចឹមនិងមើលថែទាំ។ ខ្ញុំរស់នៅក្នុងភូមិ ជីហែ ឃុំ កោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

ខ្ញុំគ្មានដីស្រែនិងដីភូមិនឹងគេទេ ប៉ុន្តែសាច់ញាតិរបស់នាងខ្ញុំបានអនុញ្ញាតិឱ្យខ្ញុំសង់ខ្ទមដ៏តូចមួយសំរាប់នៅជាមួយនិងចៅបួននាក់នៅលើដីរបស់ពួកគេ ។ ពេលមានភ្លៀវឬក៏ខ្យល់ម្តងៗខ្ញុំតែងតែហៅចៅៗទាំងបួននាក់របស់ខ្ញុំទៅជ្រកនៅក្រោមផ្ទះអ្នកជិតខាងព្រោះខ្ញុំខ្លាចផ្ទះរបស់ខ្ញុំរលំ ។ មានថ្ងៃខ្លះខ្ញុំនិងចៅ បាននាំគ្នាសុំបាយកកអ្នកជិតខាងយកមកហូបព្រោះ យើងគ្មានលុយសំរាប់ទិញអង្ករនិងម្ហូប ។

ខ្ញុំបានទៅខ្ចីលុយអ្នកជិតខាងចំនួន ១,០០០,០០០រៀល (អត់យកការប្រាក់ទេ) យកទៅទិញម្ហូបអាហារនិងបង់ថ្លៃសាលាឱ្យចៅខ្ញុំរៀន ព្រោះឪពុកម្តាយរបស់ពួកគេចិត្តមិនបាននិងខ្ញុំឡើយទោះបីជាកូនៗរបស់ពួកគេខ្ញុំជាអ្នកចិញ្ចឹមក៏ដោយ មិនត្រឹមតែប៉ុណ្ណោះប្រពន្ធទាំងពីររបស់ពួកគេថែមទាំងមើលងាយខ្ញុំទៀត ព្រោះពួកវាឃើញខ្ញុំក្រគ្មានដី គ្មានផ្ទះសំបែង ។ ខ្ញុំមិនដែលទិញត្រីធំៗហូបឡើយ គឺហូបតែត្រីល្អិតល្មោច ឃើញខ្ញុំហូបដូច្នោះ អ្នកជិតខាងបានបន្ទោសខ្ញុំថា" អីប្រាកដជាគ្មានកំលាំងកំហែង ហើយឈឺទៀតប្រសិនបើអ៊ីនៅតែពិសារត្រីតូចៗបែបនេះតទៅទៀត" ។

ខ្ញុំបានសំរេចចិត្តមកសុំទាននៅភ្នំពេញតែម្នាក់ឯងដោយទុកឱ្យអាចៅបងដែលមានអាយុ១៨ឆ្នាំ ជាអ្នកមើលថែទាំប្អូនប្រុស-ប្អូនស្រីរបស់វា ។ ខ្ញុំអាណិតចៅៗរបស់ខ្ញុំខ្លាំងណាស់ព្រោះខ្ញុំបានទុកពួកវាឱ្យនៅតែឯងហើយថែមទាំងគ្មានអ្វីហូបទៀតផង។ មុនពេលខ្ញុំមកភ្នំពេញ ក្មួយៗរបស់ខ្ញុំនៅឯស្រុកបាននាំគ្នារៃលុយគ្នាបានចំនួន ៥,០០០រៀលសំរាប់ឱ្យខ្ញុំធ្វើ សាហ៊ុយមក ។

ខ្ញុំទើបតែមកបាន ២០ថ្ងៃ ប៉ុណ្ណោះហើយក្នុងមួយថ្ងៃខ្ញុំអាចរកបានត្រឹមតែ ៣០០-៥០០ រៀលទេ ព្រោះខ្ញុំមិនហ៊ានសុំគេ ណាមួយខ្មាសគេទៀត ។ នៅពេលយប់ខ្ញុំសំរាកនៅផ្ទះរបស់ក្មួយខ្ញុំជិតរដ្ឋសភា ។ ក្មួយរបស់ខ្ញុំក៏ក្រណាស់ដែរ ។

ខ្ញុំមិនទាន់ច្បាស់ក្នុងចិត្តថា តើពេលណាខ្ញុំនឹងត្រឡប់ទៅផ្ទះវិញ ? ព្រោះខ្ញុំមិនទាន់សន្សំប្រាក់បាននៅឡើយ។ ខ្ញុំចង់ជួបនិយាយជាមួយសម្តេចនាយករដ្ឋមន្ត្រីហ៊ុនសែន ឱ្យគាត់ជួយសង់ផ្ទះថ្មីឱ្យខ្ញុំខ្លាំងណាស់ តែខ្ញុំគិតថាវាពិបាកខ្លាំងណាស់ក្នុងការជួបនិយាយជាមួយគាត់ដោយផ្ទាល់ ។

&&& ☆☆☆ &&&

# ករណីសិក្សាទី ១០

ꕥ✧ꕥ

នាងខ្ញុំមានអាយុ៦៣ឆ្នាំ។ ខ្ញុំរស់នៅភូមិ ត្រពាំងវែង ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្តកំពត។ ខ្ញុំគឺជាស្ត្រីមេម៉ាយ ព្រោះប្តី របស់ខ្ញុំបានស្លាប់កាលពីជំនាន់ ប៉ុល ពត ហើយខ្ញុំគ្មានកូនចៅទេ ។ ឥឡូវនេះខ្ញុំ រស់នៅតែម្នាក់ឯង ។

ខ្ញុំបានមកភ្នំពេញដើម្បីសុំទានពីរថ្ងៃមកហើយ ។ ខ្ញុំមកទីនេះតែម្នាក់ឯងពីព្រោះនៅក្នុងភូមិដែលខ្ញុំរស់នៅគ្មាននរណាម្នាក់ចង់មកសុំទាននៅទីក្រុងនេះទេ ។ ខ្ញុំមានដីស្រែទំហំ៥អា ប៉ុន្តែផលស្រូវដែលទទួលបានពីការច្រូតកាត់កាលពីឆ្នាំមុនគឺមិនគ្រប់គ្រាន់សំរាប់ខ្ញុំហូបពេញមួយឆ្នាំនោះទេ ទោះបីជាខ្ញុំរស់នៅតែម្នាក់ឯងក៏ដោយ ។ កាលពីឆ្នាំមុន ខ្ញុំបានប្រើពូជប្រហែលជា៨គីឡូក្រាមនៅលើដីនេះ ប៉ុន្តែខ្ញុំបានទទួលផលតែ៦០គីឡូក្រាមប៉ុណ្ណោះ ។ ជួនកាលខ្ញុំគ្មានអ្វីហូបទេ សាច់ញាតិរបស់ខ្ញុំឱ្យបាយ-សម្លមកខ្ញុំហូប ក៏ប៉ុន្តែខ្ញុំមិនចង់ពឹងផ្អែកលើគេរហូតនោះទេ ហេតុដូចនេះហើយទើបខ្ញុំមកភ្នំពេញដើម្បីសុំទាន ។ ខ្ញុំមិនបានប្រាប់ពួកគេថា ខ្ញុំមកសុំទាននៅទីនេះទេ ប៉ុន្តែបាននិយាយថាខ្ញុំចង់មកលេងភ្នំពេញថា តើវាផ្លាស់ប្តូរប៉ុណ្ណាហើយ តាំងពីលើកចុងក្រោយដែលខ្ញុំបានមកលេងវានោះ (តាំងពីយូរហើយ) ។ នៅពេលដែលខ្ញុំប្រាប់ពួកគេ ដូចនេះពួកគេបានប្រមូលលុយគ្នាខ្លះ៥០០រៀល ខ្លះ១,០០០រៀលដើម្បីឱ្យខ្ញុំធ្វើសោហ៊ុយមកភ្នំពេញ ។ មូលហេតុដែលខ្ញុំកុហកពួកគេ ព្រោះប្រសិនបើខ្ញុំប្រាប់គេតាមត្រង់ ពួកគេនឹងមិនឱ្យខ្ញុំមកសុំទានដូចនេះទេ។ ប៉ុន្តែតើមានការងារអ្វីផ្សេងទៀតដែលខ្ញុំអាចធ្វើបានដើម្បីចិញ្ចឹមខ្លួនឯងបាន បើនៅក្នុងភូមិគ្មានការងារធ្វើក្រៅពីធ្វើស្រែ ផងនោះ ?

នៅក្នុងទីក្រុងខ្ញុំគ្មានសាច់ញាតិទេ ដូចនេះនៅពេលយប់ ខ្ញុំដេកនៅក្បែរផ្សារថ្មីជាមួយអ្នកសុំទានផ្សេងទៀតដែលខ្ញុំបាន ជួបនៅពេលខ្ញុំសុំទាន។ ក្នុងមួយថ្ងៃៗ ខ្ញុំអាចរកបានប្រហែល១,០០០រៀល ហើយខ្ញុំចំណាយ៥០០រៀលដើម្បីទិញបាយហូប ។ នៅកន្លែងដែលខ្ញុំសំរាកពេលយប់នោះ មានក្រុមជើងកាងដែលមកលួចលុយរបស់អ្នកសុំទាន នៅពេលដែលពួកយើងកំពុងតែដេកលក់ ។ ប៉ុន្តែខ្ញុំមិនទាន់មានបទពិសោធន៍នេះទេ ។

ខ្ញុំមានគំរោងត្រឡប់ទៅផ្ទះវិញ នៅរដូវវស្សាខាងមុខនេះពីព្រោះរដូវនេះ ខ្ញុំអាចធ្វើស្រែបាន ។

ꕥꕥ ☆☆☆ ꕥꕥ

# ករណីសិក្សាទី ១១

នាងខ្ញុំមានអាយុ ៣១ឆ្នាំ។ ប្តីរបស់នាងខ្ញុំនិងខ្ញុំបានលែងលះគ្នាហើយ ព្រោះគាត់មានប្រពន្ធថ្មី។ នាងខ្ញុំមានកូនប្រុស២នាក់ តែពួកវាឈឺស្លាប់បាត់អស់ទៅហើយ ។ នាងខ្ញុំរស់នៅក្នុងភូមិ ស្វាយមីង ឃុំ អង្គតាសូ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ។

នាងខ្ញុំមកសុំទាននៅភ្នំពេញនេះអស់រយៈពេល ៤-៥ ខែមកហើយ ។ មូលហេតុបានជានាងខ្ញុំមកដើរសុំគេ ព្រោះនៅឯភូមិនាងខ្ញុំគ្មានការងារធ្វើហើយភ្នែកម្ខាងរបស់ខ្ញុំត្រូវខ្វាក់ទៀត ដោយសារតែនាងខ្ញុំបានឈ្លោះជាមួយនិងបងប្អូន ហើយវាបានយកឈើមួយយ៉ាងស្រួចមកចាក់ត្រង់ភ្នែករបស់ខ្ញុំ។ នាងខ្ញុំមានដីស្រែចំនួន២០អា តែសព្វថ្ងៃនេះនាងខ្ញុំបានដីស្រែនោះទៅបងប្អូនខ្ញុំម្នាក់ទៀតធ្វើ លុះដល់ពេលច្រូតកាត់ទើបយើងចែកផលស្រូវគ្នា។ ពេលដែលនាងខ្ញុំកំពុងសំរាកព្យាបាលភ្នែកនោះ ខ្ញុំបានបញ្ចាំដីស្រែរបស់ខ្ញុំក្នុងតំលៃ៥០០,០០០រៀល ទៅឱ្យគេដើម្បីយកលុយមកទិញថ្នាំសង្កូវសំរាប់ព្យាបាលភ្នែក ប៉ុន្តែការព្យាបាលនេះគឺមិនបានលទ្ធផលល្អសោះ ទីបំផុតនាងខ្ញុំក៏បានធ្លាក់ខ្លួនពិការ ។ ប៉ុន្តែសំណាងល្អនាងខ្ញុំអាចមាន លទ្ធភាពលួសយកដីស្រែនោះមកវិញបាន។

ខ្ញុំបានខ្ចីលុយអ្នកភូមិចំនួន ២០,០០០រៀលដើម្បីយកមកទិញអង្ករ ម្ហូបនិងរបស់របរត្រូវការចាំបាច់មួយចំនួន តែគេ មិនយកការប្រាក់ពីខ្ញុំទេ ។

ជារៀងរាល់យប់ខ្ញុំសំរាកនៅជិតរោងចក្រផលិតមីនៅសង្កាត់ចាក់អង្រែជាមួយ និងក្មួយប្រុសរបស់ខ្ញុំ។ ខ្ញុំយកក្មួយមកជា មួយសំរាប់ដើរសុំទានជាមួយនិងដឹកដៃខ្ញុំ ចំណែកប្រាក់ដែលរកបានគឺខ្ញុំជាអ្នកទុកហើយក៏ជាអ្នកចាត់ចែងក្នុងការទិញម្ហូបអាហារដែរ ។

ខ្ញុំមិនទាន់មានគំរោងនឹងត្រឡប់ទៅស្រុកវិញពេលណានោះទេ ព្រោះនៅឯស្រុកគ្មានការងារធ្វើ ។ ប្រសិនបើខ្ញុំចង់ធ្វើស្រែ ខ្ញុំត្រូវការជួលគេមកធ្វើព្រោះខ្ញុំនៅតែម្នាក់ឯងហើយពិការទៀត ។

# ករណីសិក្សាទី ១២

នាងខ្ញុំមានអាយុ ៤០ឆ្នាំ។ នាងខ្ញុំមានកូនទាំងអស់៤នាក់សុទ្ធតែប្រុស ។ នាងខ្ញុំរស់នៅក្នុងភូមិដូនឱ ឃុំអូរាំង ស្រុកជុំគីរី ខេត្តកំពត ។ មុនពេលដែលនាងខ្ញុំមិនទាន់បានលែងលះប្តីនោះ ប្តីរបស់នាងខ្ញុំតែងតែផឹកស្រាស្រវឹងហើយរករឿងវាយធ្វើបាបខ្ញុំហើយនិងកូន ។ ប៉ុន្តែសព្វថ្ងៃនេះគាត់បានរៀបការជាមួយនិងប្រពន្ធថ្មីហើយពួកគេបាននាំគ្នាទៅរស់នៅឯក្រុងព្រះសីហនុអស់រយៈពេលជិតមួយឆ្នាំហើយ ។ កូនប្រុសបងរបស់ នាងខ្ញុំសព្វថ្ងៃនេះរស់នៅស៊ីឈ្នួលមើលគោគេនៅឯស្រុក ដោយក្នុងមួយឆ្នាំគេឱ្យស្រូវ៣ថាំង ចំណែកឯកូនទីពីរវិញគឺស្នាក់នៅជាមួយគេដែរតែ វាបានរៀនបានសូត្រត្រឹមត្រូវ ចំពោះកូនទី៣ និង ទី៤ គឺមក ភ្នំពេញតាមខ្ញុំ ។

មូលហេតុដែលនាងខ្ញុំមកទីក្រុងភ្នំពេញនេះគឺដើម្បីមកដើររើសអេតចាយតែពេលខ្លះនាងខ្ញុំក៏បានដើរសុំទានគេដើម្បីយកលុយមកទិញម្ហូបអាហារទទួលទាន ។ ខ្ញុំបានមកភ្នំពេញនេះអស់រយៈពេល២ឆ្នាំមកហើយគឺមកតាំងពីពេលដែលនាងខ្ញុំនៅជុំនិងប្តីរបស់នាងខ្ញុំមកម្លេះគឺមក ដើម្បីរកលុយយកទៅចិញ្ចឹមប្តីនិងកូន។ លើកនេះនាងខ្ញុំបានមកស្នាក់នៅភ្នំពេញអស់រយៈពេលពីរខែមកហើយ ។ សព្វថ្ងៃនេះនាងខ្ញុំគ្មានសេសសល់ដីស្រែ គ្មានផ្ទះសម្បែងនិងគ្មានអ្វីទាំងអស់ ។ កាលពីមុនខ្ញុំមានដីស្រែតែក្រោយមកប្តីរបស់ខ្ញុំបានលក់ដីនោះ ដើម្បីយកលុយទៅការប្រពន្ធថ្មីហើយបានប៉ុន្មាននោះ ខ្ញុំមិនដឹងទេ ។ ថ្ងៃមួយប្តីរបស់នាងខ្ញុំបានយកចានមកវាយខ្ញុំ ពេលនោះខ្ញុំក៏បានទៅមន្ទីរពេទ្យស្រាប់តែក្នុងថ្ងៃនោះដែលប្តី របស់ខ្ញុំក៏បានលួចលក់ដីស្រែទៅឱ្យគេ ។

នៅពេលយប់ជាទូទៅខ្ញុំតែងតែទៅសំរាកនៅវត្តសារាវ័ន្ត ឬវត្តនាគវ័ន្ត។ មានពេលខ្លះក្នុងខណៈពេលដែលខ្ញុំកំពុងតែដើរសុំទានគេនោះស្រាប់តែមានឡានមួយដែលក្នុងនោះមានមនុស្សពីរ-បីនាក់ជិះមកឈប់ហើយដើរចាប់អ្នកសុំទាន ប៉ុន្តែខ្ញុំមិនស្គាល់ថាពួកគេជានរណា? ហើយហេតុអ្វីបានជាគេមកចាប់អ្នកសុំទានដូច្នេះទេ ? ខ្ញុំបានព្យាយាមរត់គេចពីពួកគេ ។

# ករណីសិក្សា ទី ១៣

នាងខ្ញុំមានអាយុ ៤៨ ឆ្នាំ ។ ខ្ញុំរស់នៅភូមិ តាងឫស្សី, ភូមិពោតស, ស្រុកបាទី ខេត្តតាកែវ ។

ក្រោយរបបប៉ុលពត ខ្ញុំបានរៀបការជាមួយទាហ៊ានម្នាក់ហើយយើងមានកូន ២នាក់ កូនប្រុសម្នាក់ដែលបច្ចុប្បន្ននេះមានអាយុ២០ឆ្នាំ ហើយនិងកូនស្រីម្នាក់ដែលមានអាយុ១២ឆ្នាំ ។ កូនប្រុសខ្ញុំសព្វថ្ងៃនេះបួសជាលោកសង្ឃនៅវត្តក្នុង ភូមិហើយកូនស្រីខ្ញុំកំពុងរៀននៅក្នុងភូមិដែរ ។ ប៉ុន្តែឥលូវនេះ ខ្ញុំជាស្ត្រីមេម៉ាយ ពីព្រោះប្តីរបស់ខ្ញុំបានស្លាប់ដោយសារជំងឺគ្រុនចាញ់នៅពេលដែលគាត់ទៅកាប់ឆ្កាព្រៃនៅប៉ៃលិន ក្បែរទល់ដែនថៃ ។

ខ្ញុំគ្មានដីស្រែឬដីផ្ទះទេ ទោះជាតាំងពីប្តីរបស់ខ្ញុំនៅរស់គឺយើងរស់នៅជាមួយបងស្រី ហើយខ្ញុំតែងតែជួយស្ទូងឬច្រូតគាត់ ហើយគាត់ចែកផលស្រូវដែលទទួលបាននោះឱ្យខ្លះ ។ ប៉ុន្តែបន្ទាប់ពីប្តីរបស់ខ្ញុំស្លាប់ទៅ បងស្រីរបស់ខ្ញុំបានហៅខ្ញុំឱ្យហូបបាយជាមួយគាត់ ពីព្រោះដោយសារតែគាត់មើលឃើញជីវភាពរស់នៅរបស់ខ្ញុំលំបាកពេក ។ ពីមួយថ្ងៃទៅមួយថ្ងៃ ជីវភាពរស់នៅរបស់ពួកយើងកាន់តែធ្លាក់ចុះទៅៗ ព្រោះមានសមាជិកជាច្រើននៅក្នុងគ្រួសារ ហើយផលស្រូវដែលយើងទទួលបានគឺមិនគ្រប់គ្រាន់សំរាប់ហូបក្នុងមួយឆ្នាំ ហើយយើងក៏មិនអាចរកចំណូលផ្សេងទៀតបានដែរក្រៅពីការងារស្រែចំការ ។ ដោយសារតែហេតុផលនេះហើយ ទើបខ្ញុំសំរេចចិត្តមកសុំទាននៅភ្នំពេញដើម្បីរកលុយឧបត្ថម្ភបងស្រី ហើយនិងឧបត្ថម្ភកូនស្រីឱ្យបានរៀនសូត្រ ។ ខ្ញុំបានមកសុំទាននៅភ្នំពេញនេះប្រាំឆ្នាំមកហើយ ។ ខ្ញុំស្នាក់នៅជិតផ្សារថ្មីជាមួយអ្នកសុំទានដទៃទៀត ហើយក្នុងមួយថ្ងៃខ្ញុំអាចរកបានពី១,៥០០-២,០០០រៀល។ ខ្ញុំចំណាយប្រហែល១,០០០ រៀលដើម្បីទិញ បាយហូប ។

ខ្ញុំនឹងត្រឡប់ទៅស្រុកវិញ ដើម្បីជួយបងស្រីច្រូតកាត់និងស្ទូងនៅពេលរដូវវស្សា ហើយក្រោយពេលដែលការងារនេះរួចរាល់ហើយ ខ្ញុំនឹងស៊ីឈ្នួលច្រូតនិងស្ទូងឱ្យអ្នកភូមិហើយគេនឹងឱ្យថ្លៃឈ្នួល ៣,០០០រៀលក្នុងមួយថ្ងៃ រួមទាំងបាយពេលព្រឹកនិងពេលថ្ងៃត្រង់ផង ។ ក្រោយរដូវច្រូតកាត់ ខ្ញុំនឹងត្រឡប់មកសុំទានម្តងទៀត ពីព្រោះនៅក្នុងភូមិនឹងគ្មានការងារ សំរាប់ខ្ញុំធ្វើទេក្រៅពីការងារស្រែចំការ ។

# ករណីសិក្សាទី ១៤

នាងខ្ញុំអាយុ ៦៦ឆ្នាំ ។ ខ្ញុំរស់នៅភូមិព្រៃកពោធិ៍ ឃុំព្រៃកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ ខ្ញុំរស់នៅតែម្នាក់ឯងទេ ព្រោះប្តីរបស់ខ្ញុំនិងកូនស្រីរបស់ខ្ញុំបានស្លាប់កាលពីជំនាន់ ប៉ុល ពត ។

ខ្ញុំមានដីស្រែ៥ម៉ែត្រ ប៉ុន្តែខ្ញុំគ្មានលទ្ធភាពធ្វើស្រែនៅលើដីនេះទេ ពីព្រោះខ្ញុំចាស់ហើយ ហេតុដូចនេះហើយខ្ញុំឱ្យអ្នកភូមិជាមួយគ្នាឱ្យប្រើដីនេះដើម្បីធ្វើស្រែ ហើយគេចែកផលស្រូវខ្លះដែលគេធ្វើបានឱ្យខ្ញុំនៅពេល ដែលគេប្រមូលផល ។ ស្រូវដែលខ្ញុំទទួលបាននោះ គឺមិនគ្រប់គ្រាន់សំរាប់ខ្ញុំហូបពេញមួយឆ្នាំទេ ទោះបីជាខ្ញុំរស់នៅតែម្នាក់ឯងក៏ដោយ។ ដូច្នេះ ខ្ញុំសំរេចចិត្តខ្ចីលុយគេ ២០០,០០០រៀលពីអ្នកចងការលុយ ដើម្បីទិញអង្ករ-ម្ហូប និងតំរូវការផ្សេងៗទៀត ហើយនឹង ចំណាយទៅលើការធ្វើដំណើរ ។ ក្នុងមួយខែគេយកការពីខ្ញុំ ២០% ។

ដោយសារតែបំណុលនេះ ខ្ញុំបានសំរេចចិត្តមកភ្នំពេញដើម្បីសុំទាន តាមវិធីនេះខ្ញុំអាចរកលុយដើម្បីដោះបំណុលនេះ ។ ខ្ញុំមកសុំទាននៅភ្នំពេញនេះជាលើកតំបូង ហើយខ្ញុំមកជាមួយអ្នកភូមិពីរនាក់ផ្សេងទៀតកាលពីបីថ្ងៃមុន ហើយគ្មាននរណាម្នាក់បង្ខំឬស្នើឱ្យខ្ញុំមកទីនេះទេ ។

នៅថ្ងៃទីពីរដែលយើងមកដល់ទីក្រុង ខ្ញុំនិងអ្នកភូមិពីរនាក់ទៀតបានចាញ់បោកបុរសម្នាក់ដែលមានអាយុ៣០ឆ្នាំ ។ យើងបានជួបគាត់នៅមាត់ទន្លេ នៅខណៈពេលដែលយើងកំពុងតែសុំទាន គាត់បានអញ្ជើញពួកយើងឱ្យទៅវត្តភ្នំដើម្បីទៅទទួលអង្ករនិងលុយចំនួន ៣០០,០០០ រៀល ពីសាច់ញាតិរបស់គាត់ម្នាក់ដែលទើបតែមកពីសហរដ្ឋអាមេរិច ។ នៅពេលដែលយើងទៅដល់វត្តភ្នំ គាត់បានសួរយើងថា តើយើងមានលុយសំរាប់ទិញសំបុត្រទៅយកអំណោយទាំងនោះឬទេហើយ យើងទាំងបីនាក់បានប្រមូលលុយបាន៤០,០០០រៀល ឱ្យទៅគាត់ ហើយបន្ទាប់មកគាត់បានប្រាប់យើងឱ្យនៅចាំហើយគាត់ទៅទិញសំបុត្រ ក៏ប៉ុន្តែយើងបានចាំគាត់យ៉ាងយូរ តែមិនឃើញគាត់ត្រឡប់មកវិញឡើយ ។

នេះគឺជាលើកទីមួយហើយដែលខ្ញុំនិងអ្នកជិតខាងខ្ញុំបានមកសុំទាននៅភ្នំពេញ ហើយពួកយើងក៏មិនដឹងថា តើកន្លែងណាដែលមានសុវត្ថិភាពសំរាប់យើងស្នាក់នៅដែរ ដូច្នេះយើងសំរេចចិត្តស្នាក់នៅមុខផ្ទះរបស់គេនៅម្តុំផ្សារចាស់នៅពេលយប់ ប៉ុន្តែយើងមានសំណាងណាស់ដោយមានស្ត្រីម្នាក់ដែលរស់នៅតែម្នាក់ឯងនៅផ្ទះក្បែរផ្សារចាស់បានហៅយើងឱ្យទៅស្នាក់នៅពេលយប់ជាមួយគាត់ ប៉ុន្តែគាត់គ្មានលទ្ធភាពផ្តល់ម្ហូបអាហារឱ្យដល់

យើងទេ ពីព្រោះគាត់ក៏ចាស់ណាស់ដែរ ។ នៅពេលថ្ងៃ បងស្រីថ្លៃរបស់ខ្ញុំនិងខ្ញុំដើរសុំទាននៅមុខវាំង ហើយតាំងពីព្រឹករហូតដល់ល្ងាចយើងរកប្រាក់បានប្រហែល ៨០០-១,០០០រៀល ហើយខ្ញុំបានចំណាយ៥០០រៀលដើម្បីទិញម្ហូបហូប ។ ខ្ញុំមានគំរោងត្រឡប់ទៅផ្ទះវិញនៅពេលចូលឆ្នាំខ្មែរ ខាងមុខនេះ ។

&& ☆☆☆ &&

# ករណីសិក្សាទី ១៥

នាងខ្ញុំមានអាយុ ៥៥ឆ្នាំ ប្តីរបស់ខ្ញុំមានអាយុ ៦០ឆ្នាំ ។ យើងរស់នៅ ភូមិព្រហ៊ូត ឃុំត្រពាំងស្រែ ស្រុកមេសាង ខេត្តព្រៃវែង ។

យើងមានកូន ៨នាក់ ស្រី៣នាក់ ប្រុស៥នាក់ ប៉ុន្តែកូន ៤នាក់ក្នុងចំណោមកូន៨នាក់នោះ បានរៀបការរួច ហើយ (ប្រុស ២នាក់ ស្រី ២នាក់) ចំណែកឯកូនប្រុសទី៤ គឺវាបានទៅនៅក្នុងភូមិច្រេស ឃុំច្រេស ស្រុក មេសាង ខេត្តព្រៃវែង ជាមួយនឹងប្រពន្ធរបស់វា ។

យើងមានដីស្រែ៣០អា ប៉ុន្តែសព្វថ្ងៃនេះយើងនៅសល់ដីតែ២០អាទេ ព្រោះពួកយើងបានចែកឱ្យកូនដែលបាន រៀបការរួចក្នុងម្នាក់ ៥អា ដើម្បីធ្វើស្រែ ប៉ុន្តែកូនដែលនៅក្នុងភូមិច្រេសនេះវាមិនយកទេ ។

ជារៀងរាល់ឆ្នាំ គ្រួសាររបស់យើងរស់នៅពឹងផ្អែកទៅលើផលស្រូវដែលយើងប្រមូលបានពីរដូវច្រូតកាត់ ប៉ុន្តែ បីឆ្នាំកន្លងមកនេះ យើងមិនអាចធ្វើស្រែនៅលើផ្ទៃដី២០ អានោះបានសោះដោយសារតែភាពរាំងស្ងួត ។ នៅ ពេលដែលយើងប្រមូលផលស្រូវមិនបានគ្រួសាររបស់យើងគឺត្រូវរស់នៅក្នុងលក្ខខណ្ឌមួយយ៉ាងលំបាក ហើយ កាលពីខែមេសាឆ្នាំទៅនេះខ្ញុំព្រមទាំងប្តីរបស់ខ្ញុំបានសំរេចចិត្តទៅខ្ចីលុយពីធនាគារអេស៊ីលីដាចំនួន១៥០,០០០ រៀល ដើម្បីយកមកទិញមាន់និងជ្រូកចិញ្ចឹមដោយក្នុងមួយខែគេគិតការប្រាក់ពីយើង៣០%ជារៀលរាល់ខែ ពួកយើងមិនអាចរកលុយមកបង់ឱ្យថ្លៃការប្រាក់គេគ្រប់ចំនួនឡើយ ។ ដូច្នេះកាលពី៣ខែមុន យើងបានសំរេច ចិត្តទៅខ្ចីលុយ ៥៥០,០០០ រៀលពីអ្នកចងការប្រាក់ ដើម្បីយកទៅបង់ថ្លៃការប្រាក់ឱ្យធនាគារអេស៊ីលីដា ចំណែកឯប្រាក់ដែលនៅសល់គឺយើងខ្ញុំបានយកទៅទិញម្ហូបអាហារ និងតំរូវការចាំបាច់ផ្សេងៗទៀតនៅក្នុង គ្រួសារ ។ អ្នកចងការប្រាក់នោះមិនបានឱ្យយើងបញ្ចាំរបស់របរឬយកការប្រាក់ពីយើងឡើយ ពីព្រោះពួកគេ បានប្រាប់យើងថាដីស្រែដែលពួកយើងមាននោះប្រសិនបើលក់គឺបានថ្លៃមិនស្មើនឹងទឹកប្រាក់ ដែលពួកយើងទៅ ខ្ចីគេបានឡើយ ប៉ុន្តែគេបានឱ្យពួកយើងចុះកិច្ចសន្យាថា " ក្នុងរយៈពេល៧ខែ ប្រសិនបើយើងគ្មានលុយសងគេ គ្រប់ចំនួនទេនោះ គេនឹងគិតលុយពីយើងទ្វេរមួយជាពីរ " ។ ពួកយើងមានការព្រួយបារម្ភខ្លាំងណាស់ខ្លាច គេ គិតលុយទ្វេរមួយជាពីរ ។

កាលពីមុនប្តីរបស់ខ្ញុំគាត់គឺជាអ្នកលេងភ្លេងបុរាណខ្មែរនៅក្នុងភូមិ ប៉ុន្តែឥឡូវគាត់ឈប់ហើយ ព្រោះតែរកលុយមិនសូវបាន ។ ដោយសារតែមូលហេតុនេះហើយទើបប្តីរបស់ខ្ញុំ និងខ្ញុំសំរេចចិត្តមកសុំទាននៅភ្នំពេញនេះជាមួយអ្នកភូមិ ៥នាក់ទៀត និងបងថ្លៃរបស់ខ្ញុំដើម្បីមករកលុយយកទៅសងដល់ម្ចាស់បំណុល ។ នៅក្នុងភូមិនេះក្រៅពីការងារស្រែចំការគឺ គ្មានអ្វីធ្វើទេ ។

ពួកយើងទើបតែមកទីនេះបានពីរខែនិងទុកកូនទី៥ឱ្យរស់នៅឯភូមិដែលមានអាយុ ១៨ឆ្នាំ និងកំពុងរៀននៅសាលា ។ រាល់ថ្ងៃវាឡើងដើម្បីត្នោតដើម្បីយកលុយមកឧបត្ថម្ភដល់ប្អូនប្រុសស្រីនៅពេលខ្ញុំមកឆ្ងាយ ។

ជារៀងរាល់ថ្ងៃ ខ្ញុំតែងតែទៅសុំទាននៅមុខវាំងជាមួយអ្នកជិតខាងនិងបងថ្លៃរបស់ខ្ញុំ ប៉ុន្តែប្តីរបស់ខ្ញុំគាត់មិនទៅទេ ព្រោះគាត់មានអារម្មណ៍ខ្មាស់នៅពេលទៅសុំពីនរណាម្នាក់ ហើយគាត់ខ្លាចជួបនរណាម្នាក់ដែលស្គាល់គាត់ ដូច្នេះគាត់គឺគ្រាន់តែដេកនិងរង់ចាំខ្ញុំដើម្បីទិញម្ហូបមកហូប ។

ក្នុងមួយថ្ងៃខ្ញុំអាចរកលុយបាន ១,០០០រៀល ប៉ុន្តែនៅថ្ងៃឈប់សំរាក សម្តេចព្រះសីហនុ តែងតែមកឱ្យលុយពី ៥០០-១,០០០រៀល ដល់អ្នកសុំទានទាំងអស់ ដូច្នេះថ្ងៃនោះយើងអាចរកលុយច្រើនជាងថ្ងៃធម្មតា និងអាចសន្សំលុយទុកបាន ខ្លះដែរ ។

នៅពេលយប់ពួកយើងទាំងអស់គ្នាដេកនៅតាមបណ្តោយសួននៅជិតកន្លែងប៊ូឌិញនិងតាំងពី២ខែមុន ខ្ញុំមិនដែលទៅមើលកូនរបស់ខ្ញុំទេ ព្រោះខ្ញុំគ្មានលុយសំរាប់ធ្វើដំណើរនិងទិញម្ហូបសំរាប់ពួកគេ ហើយពួកយើងក៏គ្មានគំរោងច្បាស់លាស់ ដើម្បីត្រឡប់ទៅផ្ទះវិញដែរ ។

&& ☆☆☆ &&

# ករណីសិក្សាទី ១៦

នាងខ្ញុំមានអាយុ៦២ ឆ្នាំ ។ ខ្ញុំគឺជាស្ត្រីមេម៉ាយពីព្រោះប្តីរបស់ខ្ញុំបានស្លាប់កាលពី ១០ ឆ្នាំមុនដោយសារជំងឺលើសឈាម ។ ខ្ញុំមានកូន ១០ នាក់ប៉ុន្តែកូនបីនាក់បានស្លាប់កាលពីជំនាន់ប៉ុល ពត ហើយសព្វថ្ងៃនេះ ខ្ញុំនៅសល់កូន៧នាក់ទៀត (កូនស្រីពីរនាក់ និងកូនប្រុសប្រាំនាក់) ហើយមានកូនប្រាំនាក់ ហើយដែលបានរៀបការរួច ។ ខ្ញុំរស់នៅភូមិប៊ីគុយ ឃុំស្រែ ស្រុកមេសាង ខេត្តព្រៃវែង ។

កាលពីមុនខ្ញុំមានដីស្រែជាច្រើន ប៉ុន្តែបច្ចុប្បន្ននេះ ខ្ញុំនៅសល់តែដីទំហំ ២០ អាប៉ុណ្ណោះ ដោយសារតែខ្ញុំបានចែកទៅឱ្យកូនទាំងប្រាំនាក់ដែលបានរៀបការហើយ ដើម្បីឱ្យពួកវាធ្វើស្រែចិញ្ចឹមគ្រួសារ ។ ខ្ញុំអាចធ្វើស្រែបាននៅរដូវវស្សា ប៉ុន្តែនៅរដូវប្រាំងខ្ញុំមិនអាចធ្វើបានទេ ដោយសារតែគ្មានទឹកសំរាប់ប្រើ ។ ក្នុងមួយឆ្នាំយើងអាចប្រមូលផលបានប្រហែល ១០ថាំង ប៉ុន្តែផលស្រូវនេះគឺមិនគ្រប់គ្រាន់សំរាប់ហូបក្នុងពេលមួយឆ្នាំទេ ពីព្រោះដោយសារតែយើងមានសមាជិកជាច្រើននៅក្នុងគ្រួសារ ។

កាលពីឆ្នាំមុន ខ្ញុំបានខ្ចីមាសចំនួនប្រាំជីពីបងប្អូន ដើម្បីយកទៅធ្វើផ្ទះថ្មីព្រោះដោយសារតែផ្ទះរបស់ខ្ញុំនោះវាចាស់ទ្រុឌទ្រោមណាស់ហើយ ហើយមាសប្រាំជីនេះគឺគេយកការប្រាក់២០,០០០រៀលក្នុងមួយខែ ។ ប៉ុន្តែខ្ញុំគ្មានលទ្ធភាពរកប្រាក់ឱ្យបានគ្រប់គ្រាន់ដើម្បីបង់ថ្លៃការប្រាក់នោះទេ ដូច្នេះខ្ញុំបានសំរេចចិត្តមកភ្នំពេញ ដើម្បីសុំទាន ។ ខ្ញុំមកជាមួយបងស្រីថ្លៃរបស់ខ្ញុំនិងអ្នកភូមិប្រាំនាក់ផ្សេងទៀត។ នៅពេលយប់ ពួកយើងស្នាក់នៅតំបន់ប៊ូឌិញ ។

ខ្ញុំបានមកទីនេះពីរខែមកហើយ ។ ក្នុងមួយថ្ងៃ ខ្ញុំអាចរកប្រាក់បានប្រហែល ២,០០០ រៀលហើយខ្ញុំចំណាយ ៥០០រៀល ដើម្បីទិញម្ហូប ហើយប្រាក់ដែលនៅសល់គឺខ្ញុំសន្សំទុកដើម្បីសងបងប្អូនរបស់ខ្ញុំវិញ ។ ខ្ញុំតែងតែត្រឡប់ទៅផ្ទះវិញ នៅពេលដែលខ្ញុំសន្សំលុយបានប្រហែល ៣០,០០០-៤០,០០០រៀល ដើម្បីយកលុយនេះទៅបង់ថ្លៃការប្រាក់ហើយបើសិនជាមាន លុយនៅសល់គឺខ្ញុំទិញម្ហូបអាហារដើម្បីឧបត្ថម្ភគ្រួសារខ្ញុំនឹងទុកខ្លះសំរាប់ធ្វើសោហ៊ុយត្រឡប់មកភ្នំពេញវិញ ។

នៅពេលដែលខ្ញុំត្រឡប់ទៅវិញ កូនប្រុសពៅរបស់ខ្ញុំធ្វើស្រែឱ្យគេនៅអ្នកលឿង ហើយក្នុងមួយខែគេឱ្យប្រាក់ខែ ៦០,០០០ រៀលសំរាប់ថ្លៃពលកម្ម ហើយកូនប្រុសម្នាក់ទៀតដែលមានអាយុ ២១ឆ្នាំនៅផ្ទះតែម្នាក់ឯង ហើយមើលថែរក្សាផ្ទះនិង រៀន។

&&☆☆☆&&

# ករណីសិក្សាទី ១៧

នាងខ្ញុំមានអាយុ៦៧ ឆ្នាំ ។ ខ្ញុំគឺជាស្ត្រីមេម៉ាយហើយខ្ញុំរស់នៅតែម្នាក់ពីព្រោះប្តីរបស់ខ្ញុំ និងកូនប្រុសពីរនាក់របស់ខ្ញុំបានស្លាប់កាលពីជំនាន់ ប៉ុល ពត ទៅហើយ ។ ខ្ញុំរស់នៅភូមិព្រែកពោធិ៍ ឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

ខ្ញុំមានដីទំហំ ១០ម៉ែត្រការ៉េ ប៉ុន្តែខ្ញុំគ្មានលទ្ធភាពដើម្បីធ្វើស្រែនៅលើដីនេះដោយខ្លួនឯងបានទេ ដោយសារតែខ្ញុំចាស់ណាស់ទៅហើយ ហើយរស់នៅតែម្នាក់ឯង ។ ដូចនេះហើយទើបខ្ញុំឱ្យអ្នកភូមិជាមួយគ្នាប្រើដីនេះ ដើម្បីធ្វើស្រែហើយពេលបានផលគឺយើងចែកគ្នា ។ ផលស្រូវដែលគេចែកឱ្យខ្ញុំគឺវាមិនគ្រប់គ្រាន់សំរាប់ខ្ញុំហូបពេញមួយឆ្នាំនោះទេ ពីព្រោះដីនេះវាតូច ។ កាលពីមុនដែលខ្ញុំមានកំលាំងនៅឡើយ ខ្ញុំធ្លាប់ស៊ីឈ្នួលធ្វើការឱ្យអ្នកភូមិជាមួយគ្នា ហើយគេឱ្យតំលៃពលកម្ម២,០០០រៀលក្នុងមួយថ្ងៃរួមទាំងអាហារពីរពេលក្នុងមួយថ្ងៃ ប៉ុន្តែឥឡូវនេះ ខ្ញុំឈប់ធ្វើការនេះហើយដោយសារតែខ្ញុំចាស់ណាស់ហើយ ។

ខ្ញុំបានមកភ្នំពេញនេះពីរថ្ងៃមកហើយជាមួយអ្នកភូមិបីនាក់ទៀត ។ មូលហេតុតែមួយដែលខ្ញុំមកពីនេះ គឺដើម្បីរកលុយដោះបំណុលរបស់ខ្ញុំដែលខ្ញុំបានខ្ចីពីអ្នកចងការប្រាក់ចំនួន ២០០,០០០រៀល កាលពីខែមុនដើម្បីទិញម្ហូបនិងអង្ករ ហើយលុយដែលនៅសល់ខ្ញុំប្រើដើម្បីធ្វើដំណើរមកភ្នំពេញ ។ អ្នកចងការយកការប្រាក់ពីខ្ញុំ ២០%ក្នុងមួយខែ ។ នៅក្នុងភូមិគ្មានការងារណាសំរាប់ខ្ញុំធ្វើក្រៅពីធ្វើស្រែទេ និងស៊ីឈ្នួលគេទេ ។

ក្នុងមួយថ្ងៃ ខ្ញុំអាចរកប្រាក់បានពី១,០០០-១,៥០០រៀលដូចដែលខ្ញុំគ្មានបទពិសោធន៍ក្នុងការដើរសុំទានទេ ។ នៅថ្ងៃទីពីរ ដែលយើងមកដល់ទីក្រុង ខ្ញុំនិងអ្នកភូមិពីរនាក់ទៀតបានចាញ់បោកបុរសម្នាក់ដែលមានអាយុ៣០ ឆ្នាំ ។ យើងបានជួបគាត់នៅមាត់ទន្លេនៅខណៈពេលដែលយើងកំពុងតែសុំទាន គាត់បានអញ្ជើញពួកយើងឱ្យទៅវត្តភ្នំដើម្បីទៅទទួលអង្ករ និងលុយចំនួន៣០០,០០០ រៀលអំពីសាច់ញាតិរបស់គាត់ម្នាក់ ដែលទើបតែមកពីសហរដ្ឋអាមេរិក ។ នៅពេលដែលយើងទៅដល់វត្តភ្នំ គាត់បានសួរយើងថា តើយើងមានលុយសំរាប់ទិញសំបុត្រទៅយកអំណោយទាំងនោះឬទេ ហើយយើងទាំងបីនាក់បានប្រមូលលុយបាន៤០,០០០រៀលឱ្យទៅគាត់ហើយ បន្ទាប់មកគាត់បានប្រាប់យើងឱ្យនៅចាំហើយគាត់ទៅទិញសំបុត្រ ក៏ប៉ុន្តែយើងបានចាំគាត់យ៉ាងយូរតែមិនឃើញគាត់ត្រឡប់មកវិញឡើយ ។

នេះគឺជាលើកទីមួយហើយ ដែលខ្ញុំនិងអ្នកជិតខាងខ្ញុំបានមកសុំទាននៅភ្នំពេញ ហើយយើងក៏មិនដឹងថាតើកន្លែងណាដែលមានសុវត្ថិភាពសំរាប់យើងស្នាក់នៅដែរ ដូច្នេះយើងសំរេចចិត្តស្នាក់នៅមុខផ្ទះរបស់គេនៅម្តុំផ្សារចាស់នៅពេលយប់ ប៉ុន្តែយើងមានសំណាងណាស់ដោយមានស្ត្រីម្នាក់ដែលរស់នៅតែម្នាក់ឯងនៅផ្ទះក្បែរផ្សារចាស់ បានហៅយើងឱ្យទៅស្នាក់នៅពេលយប់ជាមួយគាត់ ប៉ុន្តែគាត់គ្មានលទ្ធភាពផ្តល់ម្ហូបអាហារឱ្យដល់យើងទេ ពីព្រោះគាត់ក៏ចាស់ណាស់ដែរ ។ នៅពេលថ្ងៃ បងស្រីថ្លៃរបស់ខ្ញុំនឹងខ្ញុំដើរសុំទាននៅមុខវាំង ហើយតាំងពីព្រឹករហូតដល់ល្ងាចយើងរកប្រាក់បានប្រហែល ៨០០-១០០០រៀល ហើយខ្ញុំបានចំណាយ៥០០រៀលដើម្បីទិញម្ហូបហូប ។ ខ្ញុំមានគំរោងត្រឡប់ទៅផ្ទះវិញនៅពេលចូលឆ្នាំខ្មែរខាងមុខនេះ ។

&& ☆☆☆ &&

# ករណីសិក្សាទី ១៨

នាងខ្ញុំមានអាយុ ៣២ឆ្នាំ ហើយប្តីរបស់ខ្ញុំអាយុ ៣១ ឆ្នាំ ។ ខ្ញុំបានរៀបការជាមួយគាត់កាលពីខ្ញុំមានអាយុ ១៥ឆ្នាំ ។ យើងមានកូនប្រាំនាក់( កូនប្រុស៤នាក់និងកូនស្រីម្នាក់) ហើយកូនស្រីម្នាក់ទៀតបានស្លាប់ដោយសារជំងឺនៅពេលដែល នាងមានអាយុ ៥ឆ្នាំ ។ យើងរស់នៅភូមិស្វាយរៀង ឃុំស្វាយរៀង ស្រុក ស្វាយរៀង ខេត្តស្វាយរៀង ។

មុនពេលជំនាន់ប៉ុល ពត គ្រួសាររបស់ខ្ញុំមានដីទំហំ ២ហិចតា ប៉ុន្តែឥលូវនេះយើងនៅសល់ដីតែ២០អាប៉ុណ្ណោះ ដោយសារតែដីរបស់យើងត្រូវគេរឹបអូសយក ។ ក្នុងមួយឆ្នាំ ខ្ញុំអាចប្រមូលផលបាន១០ថាំង ក្នុងទំហំ ដី២០ អា របស់ខ្ញុំ ។ ប៉ុន្តែកាលពីប្រាំឆ្នាំមុន ខ្ញុំមិនបានទទួលផលស្រូវទាល់តែសោះដោយសារតែភាពរាំងស្ងួតហើយ ជីវភាពរស់នៅរបស់គ្រួសារខ្ញុំបានធ្លាក់ចុះជាលំដាប់ ។ ដូចនេះហើយ ប្តីរបស់ខ្ញុំនិងខ្ញុំបានសំរេចចិត្តយកដីស្រែនោះ ទៅដាក់បញ្ចាំជាមួយអង្គការក្រៅរដ្ឋាភិបាល មួយឈ្មោះគណកម្មាធិការសុខភាពកម្ពុជាចំនួនទឹកប្រាក់ ៣០០,០០០ រៀលដើម្បីយកប្រាក់ទិញម្ហូប, អង្ករនិងតំរូវការផ្សេងៗទៀត ។ សំរាប់បំណុលនេះ ខ្ញុំត្រូវបង់ប្រាក់ ៩,០០០រៀលក្នុងមួយខែ ( ដែល ៣,០០០រៀលគឺជាការប្រាក់) ។ ប៉ុន្តែបច្ចុប្បន្ននេះដីរបស់ខ្ញុំត្រូវគណៈ-កម្មាធិការសុខភាពកម្ពុជា ដកហូតយកទៅហើយ ដោយសារតែខ្ញុំគ្មានលទ្ធភាពសង ប្រាក់និងការប្រាក់កាលពីបួនឆ្នាំមុន ហើយអង្គការនោះបានយកដីរបស់ខ្ញុំលក់ឱ្យទៅអ្នកមានម្នាក់នៅក្នុងភូមិ ។ ខ្ញុំមិនបានដឹងថា តើគេលក់ដីរបស់ខ្ញុំនោះតំលៃប៉ុន្មានទេ ដោយសារគេមិនបានប្រាប់ខ្ញុំឱ្យដឹង ។

នៅពាក់កណ្តាលខែមិនា ខ្ញុំបានខ្ចីប្រាក់ ១០០,០០០រៀល ពីអ្នកចងការប្រាក់ ដើម្បីទិញអង្ករហូបនិងធ្វើដំណើរមកទីក្រុងភ្នំពេញ ហើយលុយខ្លះទៀតខ្ញុំបានទុកឱ្យប្តីរបស់ខ្ញុំដើម្បីទុកទិញម្ហូបអាហារនិងថ្នាំសង្កូវក្នុងករណីដែលកូនប្រុសរបស់ខ្ញុំឈឺ ។ លុយដែលខ្ចីនេះគេយកការប្រាក់៣០% (៣០,០០០រៀល)ក្នុងមួយខែ ។ ប៉ុន្តែបើសិនជាខ្ញុំគ្មានប្រាក់ដើម្បីសងគេវិញទេនោះ គេនឹងឱ្យខ្ញុំធ្វើជាអ្នកបំរើនៅផ្ទះរបស់គេ ។

ពីមួយថ្ងៃទៅមួយថ្ងៃ ក្រុមគ្រួសាររបស់ខ្ញុំរស់នៅក្នុងស្ថានភាពដ៏យ៉ាប់យឺន ដោយសារយើងបានបាត់បង់ដីស្រែ ហើយគ្មាន ការងារណាមួយសំរាប់យើងធ្វើក្រៅពីការងារស្រែចំការនោះទេ ហើយពួកយើងក៏ជំពាក់បំណុលគេទៀត ។ នៅពេលដែលអ្នកភូមិផ្សេងទៀតដែលធ្លាប់មកដើរសុំទាននៅភ្នំពេញគេដឹងអំពីស្ថានភាពរបស់ខ្ញុំ

គេបានបបួលខ្ញុំឱ្យមកដើរសុំទាន ជាមួយគេដើម្បីយកប្រាក់ទៅដោះបំណុល ។ ពួកគេបានប្រាប់ខ្ញុំថា "***បើសិនជាឯងនៅតែរស់នៅក្នុងភូមិទៀតនោះ ឯងនឹងស្លាប់ជាមិនខានទេដោយសារតែឯងគ្មានអ្វីហូប ហើយបំណុលក៏នៅតែជំពាក់គេទៀត ។ យកល្អឯងគួរតែទៅសុំទាននៅភ្នំពេញជាមួយពួកយើង ដើម្បីយកលុយមកដោះបំណុលនេះ ។***" បន្ទាប់ពីនោះមក ខ្ញុំបានពិភាក្សាជាមួយប្តីរបស់ខ្ញុំពីបញ្ហានេះ ហើយគាត់បានអនុញ្ញាតឱ្យខ្ញុំនឹងកូនប្រុសពីរនាក់របស់ខ្ញុំមកភ្នំពេញជាមួយអ្នកភូមិ (៥នាក់) ដែលធ្លាប់មកសុំទាននោះ ។ កូនប្រុសរបស់ខ្ញុំម្នាក់អាយុ ៦ឆ្នាំហើយកូនប្រុសម្នាក់ទៀតអាយុ ៥ខែ ។ ឥឡូវនេះនៅក្នុងភូមិ បើសិនជាមាននរណាម្នាក់ត្រូវការមនុស្សឱ្យជីកប្រឡាយទឹក គេតែងតែមករកប្តីខ្ញុំឱ្យទៅធ្វើហើយឱ្យប្រាក់គាត់២,០០០-៣,០០០ រៀលក្នុងមួយថ្ងៃ ប៉ុន្តែបើសិនជានៅថ្ងៃចុងសប្តាហ៍ គេឱ្យលុយគាត់ច្រើនជាងនេះ ។

ខ្ញុំទើបតែមកដល់ព្រឹកមិញនេះឯង ហើយតាំងពីព្រឹករហូតមកទល់ពេលនេះ (ម៉ោង ១១:៣០នាទី) ខ្ញុំមិនទាន់រកលុយបាននៅឡើយទេ ពីព្រោះខ្ញុំមិនទាន់ស្គាល់ទីតាំងនៅឡើយទេ ។ ខ្ញុំបានដើរសុំទានជាមួយកូនប្រុសទាំងពីររបស់ខ្ញុំ ប៉ុន្តែអ្នកភូមិ៥នាក់ផ្សេងទៀតដើរសុំទាននៅផ្សារថ្មី ហើយយើងនឹងមកជួបគ្នាពេលយប់នៅផ្សារថ្មី ហើយស្នាក់នៅមាត់ទន្លេ ។ ខ្ញុំមិនទាន់ដឹងថាតើពេលណាខ្ញុំនឹងត្រឡប់ទៅផ្ទះវិញទេ ។

&& ☆☆☆ &&

# ករណីសិក្សាទី ១៩

ꕥ✧ꕥ

នាងខ្ញុំអាយុ ៣៤ឆ្នាំ ហើយប្តីរបស់ខ្ញុំ គាត់មានអាយុ ៣០ឆ្នាំ ។ យើងបានរៀបការជាមួយគ្នា ១០ឆ្នាំមកហើយ យើងមានកូនពីរនាក់។ កូនប្រុសរបស់យើងមានអាយុ៥ឆ្នាំ ហើយកូនស្រីរបស់ខ្ញុំមានអាយុ៦ខែ ។ តាំងពីយើងរៀបការរហូតមកទល់និងពេលនេះ ខ្ញុំគឺជាមនុស្សតែម្នាក់គត់ដែលទទួលខុសត្រូវនៅក្នុងគ្រួសារ ពីព្រោះប្តីរបស់ខ្ញុំគ្មានធ្វើអ្វីទេក្រៅពី ផឹកស្រាស្រវឹងហើយវាយដំខ្ញុំនិងកូនៗ ។ យើងរស់នៅ ភូមិជ្រៃ ឃុំក្រាំងស្វាយ ស្រុកព្រះស្តេច ខេត្តព្រៃវែង ។

កាលពីប្រាំឆ្នាំមុនប្តីរបស់ខ្ញុំបានលក់ដីស្រែទំហំមួយហិចតាក្នុងតំលៃ៣ជីមាសឱ្យទៅអ្នកភូមិម្នាក់ ដើម្បីយកប្រាក់មកទិញម៉ូតូរត់ឌុបនៅទីក្រុងភ្នំពេញ ។ បន្ទាប់មកគាត់បានរស់នៅភ្នំពេញតែម្នាក់ឯងរយៈពេលពីរឆ្នាំ ។ ខ្ញុំមិនដែលមករកគាត់នៅភ្នំពេញទេ ពីព្រោះខ្ញុំមិនដឹងថាតើគាត់រស់នៅកន្លែងណា ហើយតើគាត់ធ្វើអ្វីនៅភ្នំពេញនេះ ហើយខ្ញុំក៏មិនដែលមកភ្នំពេញនេះពីមុនមកដែរ ។ បន្ទាប់មកគាត់បានត្រឡប់មកវិញដោយយកម៉ូតូមកជាមួយតែគ្មានលុយមួយរៀលសោះ ។ ក្នុងរយៈពេលពីរឆ្នាំដែលគាត់រស់នៅភ្នំពេញ គាត់មិនដែលទៅលេងខ្ញុំឬផ្ញើលុយកាក់ទៅផ្ទះទេ ។

ខ្ញុំបានមកសុំទាននៅទីនេះ(ភ្នំពេញ)បួនថ្ងៃមកហើយ ។ ខ្ញុំបានមករកលុយនៅទីនេះដើម្បីយកទៅសងបំណុលពីព្រោះកាលពី៥ខែមុន ខ្ញុំបានខ្ចីលុយគេ៤០០,០០០-៥០០,០០០រៀល ដើម្បីយកទៅទិញម្ហូបអាហារ អង្ករ និងចំណាយទៅលើតំរូវការផ្សេងទៀត ដូចដែលប្តីរបស់ខ្ញុំគ្មានធ្វើការងារអ្វីសោះនៅក្នុងភូមិ ។ នៅរៀងរាល់ពេលដែលប្តីរបស់ខ្ញុំគាត់ស្រវឹង គាត់តែងតែសួររកលុយពីខ្ញុំ ហើយប្រសិនបើខ្ញុំគ្មានលុយឱ្យគាត់ទេនោះ គាត់តែងតែវាយធ្វើបាបខ្ញុំនិងកូនៗ ។ នៅពេលដែលខ្ញុំទៅចរចារសុំខ្ចីលុយពីអ្នកចងការប្រាក់ គេបានឱ្យខ្ញុំយកដីផ្ទះទំហំ៦០អាទៅដាក់បញ្ចាំជាមួយគេ ពីព្រោះគេខ្លាចថាខ្ញុំគ្មានលទ្ធភាពនិងសងលុយគេនៅថ្ងៃក្រោយ ។ គេប្រាប់ខ្ញុំថា"ប្រសិនបើអ្នកចង់បានលុយ អ្នកត្រូវតែយកដីមកដាក់បញ្ចាំ ។ ប្រសិនបើអ្នកមិនយកដីមកបញ្ចាំទេនោះ ខ្ញុំនឹងមិនឱ្យលុយអ្នកទេ"។ ខ្ញុំបានយល់ព្រមជាមួយនឹងតំរូវការរបស់ពួកគេ ហើយជារៀងរាល់ខែគេយកប្រាក់ពីខ្ញុំ ១០០,០០០រៀល ដែលក្នុងនោះ ៥,០០០រៀលគឺជាការប្រាក់ ។ តាំងពីខ្ញុំខ្ចីលុយគេរហូតមកទល់ពេលនេះ ខ្ញុំមិនទាន់បានបង់ការប្រាក់ឱ្យគេទេពីព្រោះខ្ញុំរកលុយមិនបានសោះនៅក្នុងភូមិ ហើយប្តីរបស់ខ្ញុំក៏គ្មានការងារធ្វើដែរ ។ ខ្ញុំបានសំរេចចិត្តមកភ្នំពេញដើម្បីរកលុយសងការប្រាក់គេ ហើយនឹងលោះយកដីផ្ទះ

ពីគេមកវិញ ហើយខ្ញុំក៏មិនចង់ឱ្យប្តីរបស់ខ្ញុំវាយធ្វើបាបខ្ញុំតទៅទៀតដែរ ។ ខ្ញុំបានលែងលះជាមួយប្តីរបស់ខ្ញុំប្រាំលើកមកហើយ ហើយរៀងរាល់ពេលគាត់តែងតែត្រឡប់មកវិញហើយសុំអង្វរករខ្ញុំ ដើម្បីឱ្យទទួលគាត់វិញ ហើយខ្ញុំមិនដែលបដិសេធន៍ម្តងណាទេ ដោយសារតែខ្ញុំគិតអំពីកូនមិនចង់ឱ្យពួកវាបាត់បង់អនាគត ហើយក៏មិនចង់ឱ្យអ្នកដទៃនិយាយថា កូនរបស់ខ្ញុំជាកូនគ្មានឪពុកដែរ ។

នេះជាលើកតំបូងហើយដែលខ្ញុំមកសុំទាន ហើយខ្ញុំបានមកដល់ទីនេះជាមួយកូនរបស់ខ្ញុំបួនថ្ងៃមកហើយ ។ ក្នុងមួយថ្ងៃ ខ្ញុំអាចរកបាន ៥០០រៀលហើយខ្ញុំចំនាយលុយដែលរកបាននេះទិញម្ហូបនិងបាយហូប ដូចនេះខ្ញុំគ្មានបានសន្សំអ្វីទេ ។ នៅពេលយប់យើងដេកនៅក្រោមដើមពោធិ៍នៅមុខវត្តបុទុមជាមួយនិងអ្នកសុំទានផ្សេងទៀត ។ បើសិនជាខ្ញុំមិនព្យាយាមឱ្យអស់ពីលទ្ធភាពដើម្បីរកលុយទៅសងគេវិញទេនោះ គេនឹងរឹបអូសយកដីរបស់ខ្ញុំហើយ ។

នៅរដូវច្រូតកាត់ ខ្ញុំនឹងត្រឡប់ទៅផ្ទះវិញហើយទៅធ្វើការស៊ីឈ្នួលច្រូតឱ្យគេ ហើយគេនឹងឱ្យថ្លៃពលកម្មខ្ញុំ ២,០០០រៀល ក្នុងមួយថ្ងៃរួមទាំងអាហារបីពេលផងដែរ ។

&&☆☆☆&&

# ករណីសិក្សាទី ២០

ខ្ញុំអាយុ ៣៦ ឆ្នាំ ។ ប្តីរបស់ខ្ញុំអាយុ ៦០ ឆ្នាំ ។ យើងបានរៀបការកាលពីឆ្នាំ ១៩៨០ ហើយយើងមានកូនទាំងអស់ ៨ នាក់ (កូនស្រី៧នាក់និងកូនប្រុសម្នាក់) ហើយកូន៤នាក់បានស្លាប់ដោយសារជំងឺក្តៅខ្លួន ពេលដែលពួកវាទើបតែមានអាយុមួយខែ ។ បច្ចុប្បន្ននេះ ខ្ញុំនៅសល់កូនតែបួននាក់ទេ កូនស្រីម្នាក់ដែលមានអាយុ១៩ឆ្នាំធ្វើការនៅកប់ស្រូវ-ភ្នំពេញ កូនប្រុសអាយុ១៤ឆ្នាំដែលរៀននៅថ្នាក់ទី៦ កូនស្រីភ្លោះពីរនាក់អាយុ៤ឆ្នាំនិងកូនស្រីពៅរបស់ខ្ញុំដែលរៀននៅសាលាមតេយ្យ ។ គ្រួសាររបស់យើងរស់នៅភូមិព្រីង ឃុំក្រាំងតា ស្រុកពាមជរ ខេត្តព្រៃវែង ។

បច្ចុប្បន្ននេះ យើងគ្មានដីស្រែឬដីផ្ទះទៀតឡើយ ពីព្រោះកាលពីឆ្នាំ ១៩៨២ខ្ញុំនិងប្តីរបស់ខ្ញុំបានផ្លាស់ប្តូរទីលំនៅទៅនៅស្រុកតាងចូវ នៅវៀតណាម ហើយនៅពេលដែលពួកយើងត្រឡប់មកផ្ទះវិញនៅក្នុងឆ្នាំ១៩៨៧ ប្រធានឃុំបានបែងចែកដីស្រែនិងដីផ្ទះរបស់យើងឱ្យទៅអ្នកភូមិផ្សេងទៀតទៅហើយ ដូច្នេះយើងគ្មានសល់អ្វីសោះ។ ហេតុនេះហើយ ខ្ញុំបានសុំការអនុញ្ញាតអំពីបងស្រីរបស់ខ្ញុំដើម្បីសង់ផ្ទះនៅលើដីរបស់គាត់នៅ ។

ខ្ញុំធ្លាប់ជួលដី ១ហិចតាពីអ្នកភូមិដើម្បីធ្វើស្រែ ហើយក្រោយពេលច្រូតកាត់ហើយខ្ញុំទទួលផលស្រូវបានពី ៣-៥តោន ហើយម្ចាស់ដីបានយកពីខ្ញុំពី១.៥ តោនក្នុងមួយឆ្នាំ។ ខ្ញុំប្រើជីដែលផលិតដោយក្រុមហ៊ុនអាមេរិចកាំង ហើយក្នុងដីមួយបាវតំលៃ ៣៥.០០០រៀល ប៉ុន្តែដោយសារតែយើងគ្មានលុយគ្រប់គ្រាន់ដើម្បីទិញ យើងទិញជំពាក់អ្នកលក់ហើយ នៅពេលដែលយើងសងលុយគេវិញ គឺយើងត្រូវសង ៣៨.០០០រៀល ។ ក្នុងដីមួយហិចតានេះ យើងត្រូវប្រើពូជ ៣០០-៥០០ គីឡូក្រាម ហើយក្នុងមួយគីឡូក្រាមតំលៃ៧០០រៀល។ ក៏ប៉ុន្តែខ្ញុំបានឈប់ធ្វើស្រែបីឆ្នាំមកហើយ ដោយសារយើងត្រូវប្រើលុយច្រើនពេកក្នុងការធ្វើស្រែ ហើយប្តីរបស់ខ្ញុំមិនបានជួយខ្ញុំក្នុងការបាចទឹកបញ្ចូលស្រែទេ តែគាត់តែងតែវាយធ្វើបាបខ្ញុំនៅពេលដែលខ្ញុំសុំឱ្យគាត់ជួយធ្វើអ្វីមួយ ។ ក្រោយពេលដែលខ្ញុំឈប់ធ្វើស្រែមក ជីវភាពរស់នៅក្នុងគ្រួសាររបស់ខ្ញុំកាន់តែដុនដាបទៅៗ ដូចនេះហើយ ពីរឆ្នាំក្រោយមក ប្តីខ្ញុំបានសំរេចចិត្តមកធ្វើការនៅទីក្រុងជាកម្មករសំណង់ ហើយគាត់រកបានការងារធ្វើ ។ គាត់បានផ្ញើលុយប្រហែល ២០.០០០-៣០.០០០រៀលទៅផ្ទះប៉ុន្តែការផ្ញើលុយនេះគឺមិនទៀតទាត់ទេ ។ ប្តីរបស់ខ្ញុំប្រាប់ខ្ញុំថាមូលហេតុដែលគាត់មិនផ្ញើលុយទៅផ្ទះច្រើនដោយសារតែអ្វីៗនៅទីក្រុងគឺថ្លៃណាស់ ទោះជាបាយឬម្ហូបក៏ដោយ ។ ខ្ញុំបានគិតក្នុងចិត្តថាខ្ញុំមិនអាចពឹងផ្អែកលើប្តីខ្ញុំយូរតទៅទៀតបានទេ បើមិនដូច្នោះទេ

កូនរបស់ខ្ញុំនឹងមិន អាចបន្តការសិក្សាឱ្យបានខ្ពស់បានទេ ។ ដូច្នេះហើយ ខ្ញុំបានសំរេចចិត្តមករកការងារធ្វើនៅទីក្រុងភ្នំពេញជាកម្មករសំណង់ ប៉ុន្តែជាអកុសលគេមិនទទួលឱ្យខ្ញុំធ្វើការទេ ដោយសារហេតុនេះហើយទើបខ្ញុំសំរេចចិត្តដើរសុំទានដើម្បីយកលុយផ្ញើរទៅផ្ទះដើម្បីចិញ្ចឹមកូនរបស់ខ្ញុំ ។ ខ្ញុំបានទុកកូនខ្ញុំឱ្យរស់នៅក្នុងផ្ទះជាមួយជីដូនរបស់គេ ដែលមានអាយុ ៦១ឆ្នាំ ហើយគាត់លក់ដូរតវ៉ាន់ចាបហួយបន្តិចបន្តួចនៅក្នុងភូមិ ។

ខ្ញុំបានមកសុំទាននៅទីនេះកាលពីមួយឆ្នាំតំបូង ។ ប្រហែលជា៩ខែតំបូងដែលខ្ញុំមកសុំទានខ្ញុំបានត្រឡប់ទៅផ្ទះវិញ ដើម្បីទៅមើលកូនៗ ។ ខ្ញុំស្នាក់នៅផ្ទះប្រហែល២ខែកន្លះដោយសារខ្ញុំមានជំងឺ ។ ខ្ញុំគ្មានលុយគ្រប់គ្រាន់ដើម្បីព្យាបាលជំងឺទេ ហេតុដូចនេះហើយខ្ញុំបានខ្ចីលុយចំនួន៥០០,០០០រៀលពីអ្នកចងការប្រាក់នៅក្នុងភូមិ (ក្នុងអត្រាការប្រាក់២០%ក្នុងមួយខែ) ដើម្បីយកមកទិញម្ហូបអាហារ អង្ករនិងឧបត្ថម្ភនៅក្នុងគ្រួសារនិងទិញថ្នាំដើម្បីព្យាបាលជំងឺហើយជាលទ្ធផលគឺសុខភាពខ្ញុំបានប្រសើរឡើង ។ ប៉ុន្តែបច្ចុប្បន្ននេះ ខ្ញុំនៅតែជំពាក់លុយគេដដែល ។ ជារៀងរាល់ថ្ងៃ ខ្ញុំដើរសុំទានគេនៅតាមមាត់ទន្លេជាមួយអ្នកសុំទានដទៃទៀត ហើយខ្ញុំអាចរកប្រាក់បានប្រហែល២០០-១,០០០រៀល ។ មូលហេតុដែលខ្ញុំរកបានតិច គឺដោយសារតែខ្ញុំមានការអៀនខ្មាស់ក្នុងការលើកដៃសុំលុយនៅចំពោះមុខគេ ហើយមួយវិញទៀតគឺដោយសារតែខ្ញុំនៅក្មេង ហើយមនុស្សជាច្រើនគឺមិនចង់ឱ្យលុយខ្ញុំទេ ។ នៅពេលយប់ ខ្ញុំស្នាក់នៅវត្តបុទុមជាមួយប្តីរបស់ខ្ញុំ ។ ជួនកាលក្នុងមួយថ្ងៃខ្ញុំនិងប្តីរបស់ខ្ញុំចំណាយច្រើនជាង៤,០០០-៥,០០០ រៀលដើម្បីទិញម្ហូបនិងចំណីផ្សេងៗ ហើយពេលខ្លះដែលប្តីរបស់ខ្ញុំនិងខ្ញុំមិនអាចរកចំណូលបាន គឺយើងខ្ចីលុយ១,០០០-២,០០០រៀលពីកម្មករសំណង់ផ្សេងទៀតដើម្បីទិញបាយនិងម្ហូប ។ នៅពេលដែលខ្ញុំនិងប្តីខ្ញុំអាចសន្សំលុយបានប្រហែល ៤០,០០០-៥០,០០០រៀល ខ្ញុំនឹងត្រឡប់ទៅផ្ទះវិញដើម្បីយកលុយទៅសងការប្រាក់ដល់ម្ចាស់លុយដែលខ្ញុំជំពាក់ ហើយខ្ញុំត្រលប់មកសុំទានវិញប្តីរបស់ខ្ញុំបានបញ្ឈប់ការវាយដំខ្ញុំតាំងពីគាត់មកធ្វើការនៅភ្នំពេញ ។ ទោះបីជាយ៉ាងណាក៏ដោយប្តីរបស់ខ្ញុំក៏ធ្លាប់បានវាយខ្ញុំរហូតដល់រាងកាយរបស់ខ្ញុំមានស្នាមជាំពាសពេញឬក៏រហូតដល់ខ្ញុំសន្លប់ ។ ខ្ញុំមិនចង់លែងលះជាមួយគាត់ទេ ដោយសារតែខ្ញុំមិនចង់ធ្វើឱ្យអនាគតកូនរបស់ខ្ញុំមានគ្រោះភយ័និងមិនចង់ឱ្យអ្នកដទៃ និយាយថាកូនរបស់ខ្ញុំជាកូនគ្មានឪពុកនោះទេ ។

&& ☆☆☆ &&

# ករណីសិក្សាទី ២១

នាងខ្ញុំ អាយុ៣២៥ឆ្នាំ រស់នៅក្នុងភូមិត្រពាំងស្រែ ឃុំត្រពាំងស្រែ ស្រុកមេសាង ខេត្តព្រៃវែង។

ខ្ញុំបានចាកចេញពីផ្ទះអស់រយៈពេលប្រាំពីរឆ្នាំមកហើយ ដោយមកជួលបន្ទប់ស្នាក់នៅនៅម៉្តុំប៊ូឌីញក្នុងតំលៃ ៣០,០០០រៀល ក្នុងមួយខែ ប៉ុន្តែក្រោយពីប៊ូឌីញត្រូវបានភ្លើងឆេះអស់មកខ្ញុំបានទៅសុំការអនុញ្ញាតិពីប្រធានឃុំ ដើម្បីសង់កូនខ្ទមមួយនៅទីនោះ ។ ឥឡូវខ្ញុំមានប្តីហើយប៉ុន្តែយើងមិនបានរៀបការទេ គឺពួកយើងរស់នៅជាមួយគ្នាតែម្តង ។ ពួកយើងនៅជាមួយគ្នាអស់រយៈពេល៤ឆ្នាំមកហើយ ។ ឪពុកម្តាយរបស់ខ្ញុំមិនបានដឹងពីរឿងនេះទេព្រោះខ្ញុំមិនបានប្រាប់គាត់ ។ ប្តីរបស់ខ្ញុំដើរខាត់ស្បែកជើងមួយថ្ងៃ គាត់រកបាន ២,០០០-២,៥០០រៀល ប៉ុន្តែគាត់មិនដែលឱ្យលុយខ្ញុំទេ គាត់តែងតែយកលុយទៅទិញស្រាផឹកនិងទៅលេងស្រី ហើយនៅពេលដែលខ្ញុំប្រាប់គាត់ឱ្យឈប់គាត់វាយខ្ញុំរៀង រាល់ពេលរហូតថ្នាក់ខ្ញុំ ភ្នែកឬខ្លួនខ្ញុំទៀតផង ។

កាលពីបីឆ្នាំមុន មានបុគ្គលិកកាកបាទក្រហមបានមកហៅខ្ញុំឱ្យទៅពិនិត្យឈាមនៅអង្គការពន្លឺជីវិត ហើយលទ្ធផលចេញមកគឺខ្ញុំមានផ្ទុកមេរោគអេដស៍ ។ ទោះបីជាយើងទាំងពីរនាក់ដឹងថា យើងមានផ្ទុកមេរោគអេដស៍ក៏ដោយក៏យើងនៅចង់មានកូនដដែល ។ បច្ចុប្បន្នយើងមានកូនស្រីម្នាក់ដែលមានអាយុមួយឆ្នាំកន្លះ ហើយឥឡូវនេះខ្ញុំកំពុងតែមានផ្ទៃពោះ ៤ខែទៀត កូនទាំង២នាក់នេះគឺបានឆ្លងរោគអេដស៍ពីពួកយើង ។ ពីមុនខ្ញុំលក់ផ្លែឈូកនៅតាមមាត់ទន្លេ ប៉ុន្តែលក់មិនសូវជាចំណេញសោះព្រោះខ្ញុំទិញវាមកក្នុងតំលៃថ្លៃ ហើយលក់ទៅវិញក្នុងតំលៃថោក ដូច្នេះខ្ញុំក៏បានសំរេចចិត្តឈប់លក់ឈូកហើយមកសុំទាននៅសួនច្បារសម្តេចហ៊ុនសែនវិញ ។ ក្នុងមួយថ្ងៃខ្ញុំអាចសុំបានពី៣,០០០-៤,០០០រៀលប៉ុន្តែលុយ ដែលខ្ញុំរកបានគឺវាមិនគ្រប់គ្រាន់សំរាប់ទិញថ្នាំមើលជំងឺកូនស្រីរបស់ខ្ញុំទេនៅពេលវាក្តៅម្តងៗ តែប្រសិនបើថ្ងៃណាកូននាងខ្ញុំអត់ឈឺនាងខ្ញុំអាចសន្សំលុយបានពី ១,០០០-២,០០០រៀល ក្នុងមួយថ្ងៃ ។

ខ្ញុំមិនចង់ត្រឡប់ទៅផ្ទះវិញទេពីព្រោះខ្ញុំខ្លាចអ្នកភូមិ ឪពុកម្តាយរបស់ខ្ញុំឬបងប្អូនសាច់ញាតិមានការមើលងាយរើសអើង នឹងខ្ញុំដោយសារខ្ញុំកើតអេស៍ ។

# ករណីសិក្សាទី ២២

នាងខ្ញុំមានអាយុ៤៧ ឆ្នាំ ។ ខ្ញុំជាស្ត្រីមេម៉ាយដោយសារតែប្តីរបស់ខ្ញុំបានស្លាប់កាលពី១០ ឆ្នាំមុនដោយជំងឺតេតាណុស ។ ខ្ញុំមានកូនស្រីម្នាក់ដែលមានអាយុ១៨ឆ្នាំ ហើយនាងបានរៀបការកាលពីឆ្នាំមុន ។ សព្វថ្ងៃនេះនាងរស់នៅក្នុងភូមិជាមួយ ប្តីរបស់នាង ។ កូនស្រីរបស់ខ្ញុំចិត្តមិនបានជាមួយខ្ញុំទេ ។

ខ្ញុំរស់នៅភូមិខ្លាងក្រោម ឃុំវាំងចាស់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ។ កាលពីមុនខ្ញុំមានដីទំហំ១០អាដែរ តែកាលពីបីឆ្នាំ មុនខ្ញុំបានខ្ចីមាសពីអ្នកភូមិជាមួយគ្នាចំនួន៣ជី ដើម្បីយកទៅទិញម្ហូបអាហារនិងអង្ករហូប ហើយនិងសំរាប់ចំណាយទៅលើថ្លៃព្យាបាលជំងឺពីព្រោះពេលនោះខ្ញុំមានជំងឺ ហើយបច្ចុប្បន្ននេះជើងរបស់ខ្ញុំម្ខាងស្វិតហើយខ្ញុំត្រូវដើរអូស១ជើង ។ ដោយសារបំណុលនេះ ខ្ញុំបានដាក់បញ្ចាំដីស្រែហើយ ឥឡូវនេះដីនោះបានដាច់ហើយក្លាយជាកម្មសិទ្ធិរបស់គេហើយដោយ សារតែខ្ញុំគ្មានលទ្ធភាពក្នុងការលោះយកដីនោះមកវិញ ។ ខ្ញុំក៏មានដីផ្ទះទំហំ២១ម៉ែត្រ X ៤៥ម៉ែត្រដែរ ប៉ុន្តែមានគ្រួសារចំនួនបួនដែលសង់ផ្ទះនៅលើដីនេះ ។ ឥឡូវនេះខ្ញុំមិនដឹងថាតើដីនោះទៅជាយ៉ាងណាទៅហើយទេ ពីព្រោះតាំងពីខ្ញុំចាកចេញពីផ្ទះមកខ្ញុំមិនដែលបានទៅលេងផ្ទះទាល់តែសោះ ។

ជារៀងរាល់ឆ្នាំ យើងរស់នៅដោយពឹងផ្អែកទៅលើទិន្នផលស្រូវ ប៉ុន្តែក្រោយពេលដែលខ្ញុំបានយកដីស្រែទៅដាក់បញ្ចាំជាមួយអ្នកភូមិមក ជីវភាពរស់នៅក្នុងគ្រួសាររបស់ខ្ញុំកាន់តែពិបាកទៅៗ ពីព្រោះនៅក្នុងភូមិក្រៅពីធ្វើស្រែទៅគឺយើងគ្មានការងារផ្សេងធ្វើទេ។ ពីមួយថ្ងៃទៅមួយថ្ងៃ យើងរស់នៅក្នុងជីវភាពដ៏លំបាកយ៉ាប់យ៉ឺនហើយដោយសារតែមូល ហេតុនេះហើយដែលធ្វើឱ្យខ្ញុំនិងកូនស្រីសំរេចចិត្តមកទីក្រុងភ្នំពេញ ដើម្បីស្វែងរកការងារធ្វើ ប៉ុន្តែនៅភ្នំពេញក៏គ្មានការងារសមស្របសំរាប់យើងធ្វើដោយសារតែយើងមិនចេះអ្វីនោះ ព្រមទាំងគ្មានកន្លែងសំរាកនៅពេលយប់ទៀតផង ។ ដូចនេះ យើងបានចាប់ផ្តើមដើរសុំទានគេ ១ឆ្នាំកន្លះហើយ ។

យើងស្នាក់នៅតាមផ្លូវជាមួយគ្នាជារៀងរាល់យប់ ប៉ុន្តែមានថ្ងៃមួយនោះ នៅពេលដែលយើងកំពុងអង្គុយសុំទានគេ បុគ្គលិករបស់មជ្ឈមណ្ឌលកូឡាបទី៤បានមកឃើញយើង ហើយពួកគេបានប្រមូលយកពួកយើងទៅរស់នៅក្នុងមជ្ឈមណ្ឌលកូឡាបទី៤ ។ ពួកគេបានបណ្តុះបណ្តាលយើងអស់រយៈពេលបួនខែឱ្យចេះត្បាញកន្ទេលហើយបន្ទាប់មកពួកគេបានប្រាប់យើងឱ្យចាកចេញទៅស្វែងរកការងារសំរាប់ខ្លួនឯង ក៏ប៉ុន្តែខ្ញុំមិនអាចស្វែងរក

ការងារបានទេដោយសារតែខ្ញុំគ្មានដើមទុន ។ ពិធីរៀបអាពាហ៍ពិពាហ៍របស់កូនស្រីខ្ញុំ គឺបុគ្គលិកមជ្ឈមណ្ឌលជាអ្នករៀបចំចាត់ចែងឱ្យ ។

បច្ចុប្បន្ននេះ ខ្ញុំរស់នៅតំបន់ប៊ូឌិញជាមួយនិងអ្នកសុំទានដទៃទៀត ហើយក្នុងមួយថ្ងៃខ្ញុំអាចរកប្រាក់បានពី ២០០-៥០០ រៀលហើយជួនកាលខ្ញុំគ្មានរកបានអ្វីសោះ ដូចនេះខ្ញុំសុំរបស់របរពីអ្នកសុំទានផ្សេងទៀតដើម្បីហូប ។ ខ្ញុំដើរសុំទាននៅផ្សារប៊ូឌិញ។ ខ្ញុំមិនទាន់មានគំរោងដើម្បីត្រឡប់ទៅភូមិវិញទេ ព្រោះខ្ញុំគ្មានលុយដើម្បីចំណាយទៅលើថ្លៃធ្វើដំណើរហើយ ម៉្យាងវិញទៀត ខ្ញុំមានអារម្មណ៍ខ្មាស់អៀនចំពោះអ្នកភូមិនិងសាច់ញាតិ របស់ខ្ញុំ ដោយសារខ្ញុំជាអ្នកក្រហើយត្រឡប់ទៅផ្ទះវិញដៃទទេ ។

&&☆☆☆&&

# ករណីសិក្សាទី ២៣

ខ្ញុំមានអាយុ ៣៧ឆ្នាំ ។ ប្តីរបស់ខ្ញុំ មានអាយុ ៣៤ ឆ្នាំ ។ ពួកយើងបានរៀបការនៅក្នុងឆ្នាំ ១៩៨០ ប៉ុន្តែបច្ចុប្បន្ននេះ យើងបានលែងលះគ្នាហើយពីព្រោះប្តីរបស់ខ្ញុំមានប្រពន្ធថ្មីទៀតកាលពីពីរឆ្នាំមុន ប៉ុន្តែក្នុងកំឡុងពេលពីរឆ្នាំនេះ គាត់តែងតែមករកខ្ញុំហើយរួមភេទជាមួយខ្ញុំ ហើយជាលទ្ធផលគឺខ្ញុំមានកូនប្រុសម្នាក់ដែលឥឡូវនេះមានអាយុ២ខែ ។ បច្ចុប្បន្ននេះ ខ្ញុំត្រូវចិញ្ចឹមកូន៣នាក់ ( កូនស្រី២នាក់ និងកូនប្រុសម្នាក់) ។ កូនស្រីច្បងរបស់ខ្ញុំមានអាយុ១៣ឆ្នាំ ហើយកូនបន្ទាប់មានអាយុ៣ឆ្នាំ ។ ខ្ញុំគ្មានឪពុកម្តាយទេ ពួកគាត់បានស្លាប់កាលពីជំនាន់ ប៉ុលពតអស់ទៅហើយ ។

ខ្ញុំមកពីភូមិក្រញូង ឃុំរមៀងថុល ស្រុកស្វាយទៀប ខេត្តស្វាយរៀង ។ បច្ចុប្បន្ននេះខ្ញុំគ្មានដីផ្ទះទេ តែខ្ញុំមានដីស្រែទំហំមួយហិចតា ហើយខ្ញុំបានឱ្យបងប្រុសរបស់ខ្ញុំជាអ្នកមើលថែនិងទុកឱ្យកូនរបស់ខ្ញុំនៅពេលដែលខ្ញុំស្លាប់ទៅ ។ បងប្រុសរបស់ខ្ញុំធ្វើស្រែនៅលើដីនេះជារៀងរាល់ឆ្នាំ ប៉ុន្តែគាត់មិនដែលចែកផលស្រូវដែលគាត់ធ្វើបាននេះឱ្យមកខ្ញុំខ្លះទេ ។

ខ្ញុំបានជួលផ្ទះនៅតំបន់ប៊ូឌិញដើម្បីស្នាក់នៅ កាលពីឆ្នាំ១៩៩២ ហើយក្នុងមួយខែខ្ញុំត្រូវបង់ថ្លៃឈ្នួល ២០,០០០ រៀល ប៉ុន្តែតាំងពីតំបន់ប៊ូឌិញត្រូវបានបំផ្លាញដោយសារភ្លើងឆេះមក ខ្ញុំបានសុំចៅសង្កាត់ដើម្បីសង់ផ្ទះតូចមួយដើម្បីរស់នៅជាមួយកូន១របស់ខ្ញុំ ។

មុនពេលដែលខ្ញុំនិងប្តីរបស់ខ្ញុំមិនទាន់លែងលះគ្នា ប្តីរបស់ខ្ញុំធ្វើជាកម្មករសំណង់ ហើយក្នុងមួយថ្ងៃគាត់រកបាន ៥,០០០ រៀល ហើយកូនស្រីរបស់ខ្ញុំជាអ្នកដើរលក់ផ្កាឈូក ឬក៏លក់ត្រកួន ។ នៅពេលព្រឹកយើងទិញត្រកួនយកទៅលក់នៅផ្សារ ហើយនៅពេលរសៀលយើងលក់ផ្លែឈូកនៅមាត់ទន្លេ ហើយក្នុងមួយថ្ងៃយើងអាចរកចំណូលបាន ៣,០០០ រៀលក្នុងមួយថ្ងៃ។ នៅពេលយប់ខ្ញុំទៅលក់ក្រូចនៅមុខវត្តបុទុម ហើយបើសិនជាមានភ្ញៀវណាម្នាក់ចង់រួមភេទជាមួយខ្ញុំ គឺខ្ញុំទៅជាមួយគេ ។ ខ្ញុំបានធ្វើការរបៀបនេះអស់រយៈពេលបីឆ្នាំ ប៉ុន្តែឥឡូវនេះ ខ្ញុំឈប់ប្រកបមុខរបរនេះហើយដោយសារខ្ញុំកាន់តែចាស់ណាស់ហើយ ហើយរូបសម្ផស្សរបស់ខ្ញុំក៏បាត់បង់ដែរ ។ ខ្ញុំមានសំណាងណាស់ ដោយសារខ្ញុំមិនបានឆ្លងជំងឺ អេដស៍ឬជំងឺកាមរោគពីភ្ញៀវដែលខ្ញុំទៅរួមភេទជាមួយនោះឡើយ ។ ប្រសិនបើខ្ញុំមិនរកស៊ីលក់ភេទទេនោះ ខ្ញុំនឹងមិន មានលទ្ធភាពដើម្បីចិញ្ចឹមកូន

របស់ខ្ញុំទេ ដោយសារលុយដែលប្តីរបស់ខ្ញុំរកបានមកនោះគាត់ឱ្យខ្ញុំតែ ២,០០០-៣,០០០ រៀលតែប៉ុណ្ណោះ ហើយលុយដែលនៅសល់ គាត់យកទៅទិញស្រាផឹកហើយគាត់តែងតែស្រវឹងជារៀងរាល់ថ្ងៃ ។ នៅពេលដែលគាត់ស្រវឹង គាត់តែងតែវាយធ្វើបាបខ្ញុំហើយមានពេលខ្លះរហូតដល់ខ្ញុំសន្លប់ទៀតផង ឬក៏មានស្នាមជាំនៅលើខ្លួនរបស់ខ្ញុំ ឬក៏មានពេលខ្លះរហូតដល់គាត់វាយខ្ញុំបែកក្បាលនៅពេលដែលខ្ញុំកំពុងតែមានផ្ទៃពោះបីខែ ។ ពេលខ្លះមានអ្នកជិតខាងមកជួយបញ្ឈប់គាត់កុំឱ្យវាយខ្ញុំ ។

ខ្ញុំនិងកូនស្រីរបស់ខ្ញុំបានចាប់ផ្តើមដើរសុំទានតាំងពីមុនពេលបុណ្យអុំទូកឆ្នាំ ២០០១ ។ មូលហេតុដែលយើងធ្វើបែបនេះ ពីព្រោះដោយសារតែយើងគ្មានដើមទុនដើម្បីទិញផ្លែឈូកយកមកលក់ ។ សព្វថ្ងៃនេះ ខ្ញុំមានកូនបីនាក់ដែលខ្ញុំត្រូវមានតួនាទីចិញ្ចឹមពួកវា ព្រោះតែខ្ញុំបានលែងលះជាមួយប្តីខ្ញុំហើយ ។ ជារៀងរាល់ល្ងាចកូនស្រីរបស់ខ្ញុំនិងខ្ញុំចាកចេញពីផ្ទះដើម្បីទៅសុំទាននៅមុខវាំង ពីព្រោះនៅទីនោះមានមនុស្សច្រើនមកអង្គុយលេង ។ ក្នុងមួយថ្ងៃ ខ្ញុំអាចរកប្រាក់បាន ៦០០រៀល ប៉ុន្តែកូនស្រីរបស់ខ្ញុំអាចរកបានច្រើនជាងខ្ញុំ ប្រហែលពី ១,០០០-២,០០០រៀលក្នុងមួយថ្ងៃ ពីព្រោះនាងពរប្អូនប្រុសរបស់ នាងទៅជាមួយហើយនៅពេលដែលមនុស្សម្នាឃើញហើយគេមានការអានិតអាសូរដល់នាង ។ ខ្ញុំមានការសោកស្តាយ ណាស់ដោយសារកូនៗរបស់ ខ្ញុំមិនអាចទៅសាលារៀនបាន។

&&  ☆☆☆  &&

# ករណីសិក្សាទី ២៤

នាងខ្ញុំអាយុ៦៨ឆ្នាំ ជាស្ត្រីមេម៉ាយ មានកូនស្រីម្នាក់អាយុ២៣ឆ្នាំ តែនាងបានរៀបការរួចហើយថែមទាំងមានកូន៧នាក់ ទៀតផង (ស្រី៦ ប្រុស១) ។ នាងបានរៀបការតាំងពីនាងមានអាយុ ១៥ឆ្នាំម្លេះ ពួកយើងរស់នៅក្នុងភូមិព្រៃខ្នាស ឃុំ ព្រៃខ្នាស ស្រុកមេសាង ខេត្តព្រៃវែង ។

នៅភូមិកូនស្រីនិងកូនប្រសាររបស់ខ្ញុំអត់មានការងារធ្វើទេក្រៅពីជួយធ្វើស្រែខ្ញុំមួយមុខនោះ ។ ខ្ញុំមានដីស្រែទំហំ ៣០អា ហើយក្នុងមួយឆ្នាំៗអាចប្រមូលផលបានប្រហែលបីតៅស្រូវ (ក្នុងមួយតៅស្រូវ=១៥គីឡូក្រាមអង្ករ) ។

មូលហេតុតែមួយគត់ដែលខ្ញុំមកសុំទាននៅភ្នំពេញនេះគឺ ដើម្បីមករកលុយយកទៅជួយផ្គត់ផ្គង់ចិញ្ចឹមចៅៗរបស់ខ្ញុំ ។ សព្វថ្ងៃនេះកូនប្រសាររបស់ខ្ញុំគ្មានការងារធ្វើទេ ពីព្រោះវាមិនសូវជាមានរាងកាយមាំមួនអត់កំលាំងកំហែងធ្វើការងារធ្ងន់ក៏មិនបានទៀត ។ ចំណែកឯកូនស្រីរបស់ខ្ញុំវិញនោះគឺកំពុងតែឈឺទៀតដោយសារនៅក្មេងតែមានកូនច្រើនពេក ដូច្នេះខ្ញុំត្រូវការលុយយកទៅទិញថ្នាំព្យាបាលជំងឺកូនស្រីរបស់ខ្ញុំ ។

កាលពី២ខែមុននេះនាងខ្ញុំបានខ្ចីលុយចំនួន ៣០,០០០រៀលពីអ្នកភូមិដើម្បីយកមកទិញថ្នាំសង្កូវឱ្យកូនស្រីរបស់ខ្ញុំ ហើយក្នុងមួយខែគេគិតការប្រាក់ពីខ្ញុំ ៦,០០០រៀល (ប្រហែល២០%) ។ ខ្ញុំបានមកសុំទាននេះបីខែមកហើយខ្ញុំតែងតែទៅផ្ទះវិញ នៅពេលណាដែលខ្ញុំអាចសន្សំលុយបានពី ៤០,០០០-៥០,០០០រៀល ។ រាល់ពេលដែលខ្ញុំទៅផ្ទះនោះ ខ្ញុំតែងតែទិញម្ហូបអាហារនិងអង្ករយកទៅផ្ញើរកូននិងចៅៗរបស់ខ្ញុំជានិច្ច ចំណែកឯប្រាក់ដែលនៅសល់ពីការទិញរបស់របរទាំងនោះគឺខ្ញុំបានទុកសំរាប់បង់ថ្លៃការប្រាក់ ។ ខ្ញុំតែងតែមកដើរសុំនៅម្តុំផ្សារអូឡាំពិក រីឯពេលយប់ទើបត្រឡប់ទៅសំរាកនៅម្តុំផ្សារដើមថ្កូវដែលមានចំងាយប្រហែលជាមួយគ.មពីផ្សារអូឡាំពិក ។ ក្នុងមួយថ្ងៃនាងខ្ញុំអាចសុំបានពី៨០០-៣,០០០រៀល តែមានថ្ងៃខ្លះប្រសិនបើ ខ្ញុំបានជួបពួកបរទេសវិញនោះគឺ ខ្ញុំអាចសុំបានច្រើនជាងនេះគឺប្រហែលជា៥,០០០រៀលក្នុងមួយថ្ងៃព្រោះ ពួកគេបានឱ្យខ្ញុំម្នាក់ ៥០០-១,០០០រៀល ។

ខ្ញុំនឹងព្យាយាមឱ្យអស់ពីសមត្ថភាពដើម្បីរកលុយយកទៅជួយផ្គត់ផ្គង់គ្រួសារក៏ដូចជាសងបំណុលគេ ។

# ករណីសិក្សាទី២៥

នាងខ្ញុំអាយុ៦០ឆ្នាំ មានទីលំនៅ នៅភូមិពន្លឺ ឃុំអង្គសរ ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានកូនប្រាំនាក់ (ប្រុស៣ ស្រី២) កូនប្រុសពៅខ្ញុំដែលមានអាយុ២០ឆ្នាំនោះ បានបួសធ្វើជាលោកសង្ឃ ចំណែកឯកូន៤នាក់ទៀតគឺមានប្រពន្ធកូនអស់ហើយ ។ ប្តីរបស់ខ្ញុំបានស្លាប់ចោលខ្ញុំតាំងពីជំនាន់ប៉ុលពតមកម្ល៉េះ ។

នាងខ្ញុំមានដីស្រែប្រវែង ២០អា ហើយកាលពីមុនក្នុងមួយឆ្នាំៗខ្ញុំអាចប្រមូលផលស្រូវបានប្រហែលជា១៥-២០ថាំង តែផលស្រូវដែលប្រមូលបាននោះគឺខ្ញុំបានចែកទៅឱ្យកូនខ្លះ (កូនដែលបានរៀបការរួចហើយនៅក្នុងភូមិតែមួយ)។ ប៉ុន្តែជាអកុសល ក្នុងរយៈពេល៣ឆ្នាំមកនេះខ្ញុំធ្វើស្រែមិនបានផលទាល់តែសោះ ដោយសារតែគ្មានទឹកសំរាប់ធ្វើស្រែ ដូច្នេះពួកយើងក៏គ្មានស្រូវអង្ករហូបគ្រប់គ្រាន់និងគេ ។

កាលពី៣ខែមុនកូនប្រុសរបស់ខ្ញុំបានរៀបការ ប៉ុន្តែលុយកាក់ដែលខ្ញុំនៅសល់នោះគឺវាមិនគ្រប់សំរាប់រៀបចំពិធីមង្គលការឱ្យកូនខ្ញុំ ដូច្នេះខ្ញុំក៏បានទៅខ្ចីប្រាក់ចំនួន ១០០,០០០រៀល ពីអ្នកអោយប្រាក់ខ្ចីដោយក្នុងមួយខែគេយកការប្រាក់ពីខ្ញុំ៣០% ។ ដោយសារតែរឿងជំពាក់បំណុលគេនេះហើយទើបនាងខ្ញុំសំរេចចិត្តមកសុំទាននៅទីក្រុងភ្នំពេញដើម្បីរកលុយយកទៅសងបំណុលគេ ។ ខ្ញុំបានមកដល់ភ្នំពេញនេះកាលពីម្សិលមិញ ហើយនេះគឺជាលើកទីមួយហើយដែលនាងខ្ញុំមកទីក្រុង ។

ខ្ញុំបានមកជាមួយអ្នកភូមិមួយចំនួនទៀត ហើយពេលយប់ពួកយើងនាំគ្នាទៅស្នាក់នៅផ្ទះក្មួយស្រីរបស់ខ្ញុំនៅម្តុំជិតពេទ្យលោកសង្ឃ ។ ខ្ញុំមានគំរោងនឹងត្រឡប់ទៅផ្ទះវិញនៅថ្ងៃបុណ្យចូលឆ្នាំខ្មែរ លុះពេលរដូវច្រូតកាត់ រួចហើយខ្ញុំនឹងត្រឡប់មកសុំទានវិញ ព្រោះនៅឯស្រុកខ្ញុំគ្មានមុខរបរឬការងារអ្វីធ្វើឡើយក្រៅពីធ្វើស្រែមួយមុខនោះ ។

# ករណីសិក្សាទី ២៦

នាងខ្ញុំអាយុ ៣៥ ឆ្នាំ ។ ប្តីរបស់ខ្ញុំអាយុ ៣៧ឆ្នាំ ហើយគាត់ធ្វើជាកម្មករសំណង់ ។ យើងរស់នៅភូមិស្វាយជ្រុំ ឃុំស្វាយជ្រុំ ស្រុកមេសាង ខេត្តព្រៃវែង ។ ខ្ញុំមានកូន៦នាក់ កូនស្រីពីរនាក់និងកូនប្រុស ៤នាក់ ។ ពួកវារៀននៅសាលាក្នុងភូមិ ។

កាលពីមុនខ្ញុំមានដីទំហំពីរហិចតា តែនៅពេលដែលស្ថានភាពនៅក្នុងគ្រួសាររបស់ខ្ញុំធ្លាក់ដុនដាប ខ្ញុំបានសំរេចចិត្តលក់ដីមួយផ្នែក ដើម្បីយកប្រាក់មកទិញអង្ករនិងរបស់របរតំរូវការផ្សេងៗទៀត ។ ខ្ញុំបានលក់ដីនោះប្រាំឆ្នាំមកហើយ ហើយខ្ញុំលក់បាន ១៥០,០០០ រៀល។ យ៉ាងហោចណាស់តាំងពីបីឆ្នាំមុន ខ្ញុំមានដីស្រែទំហំ ៣០អា តែផលស្រូវដែលទទួលបានមិនគ្រប់គ្រាន់សំរាប់ហូបទេ ។

ខ្ញុំបានមកដល់ភ្នំពេញនេះ១០ថ្ងៃមកហើយ ។ មូលហេតុដែលខ្ញុំមកទីនេះគឺដោយសារតែភាពក្រីក្រ ហើយខ្ញុំជំពាក់បំណុល ដែលខ្ញុំបានខ្ចីពីអ្នកចងការលុយនៅក្នុងភូមិចំនួន ៥០០,០០០រៀល ដើម្បីយកមកបង់ថ្លៃព្យាបាលជំងឺកូនស្រីរបស់ខ្ញុំហើយគេយកការ ២០%ក្នុងមួយខែ ។ នៅក្នុងភូមិនៅរដូវវស្សា ខ្ញុំស៊ីឈ្នួលស្ទូងនិងច្រូតឱ្យអ្នកភូមិហើយបានកំរៃ ២,០០០-២,៥០០ រៀលក្នុងមួយថ្ងៃជាមួយអាហារបីពេលក្នុងមួយថ្ងៃ ។

នៅពេលបុណ្យចូលឆ្នាំខ្មែរខាងមុខនេះ ខ្ញុំនឹងទៅផ្ទះវិញហើយពេលចូលឆ្នាំរួចខ្ញុំនឹងត្រឡប់មកវិញពីព្រោះ ខ្ញុំមិនដឹងថា តើខ្ញុំអាចធ្វើការងារអ្វីបាននៅក្នុងភូមិនោះ ហេតុដូចនេះហើយខ្ញុំត្រូវតែត្រឡប់មកទីនេះម្តងទៀតដើម្បីរកលុយនិងសន្សំទុកដោះបំណុលរបស់ខ្ញុំ ។

# ករណីសិក្សាទី ២៧

នាងខ្ញុំមានអាយុ៣៥ ឆ្នាំ។ ខ្ញុំជាស្ត្រីមេម៉ាយដោយសារប្តីរបស់ខ្ញុំបានស្លាប់កាលពីឆ្នាំមុនដោយជំងឺក្តៅ ។ ខ្ញុំមានកូនពីរនាក់ កូនប្រុសបងអាយុ ១៤ឆ្នាំ ហើយកូនស្រីពៅអាយុមួយឆ្នាំ។ ខ្ញុំរស់នៅភូមិរមាសឈរ ឃុំគោកខ្ចក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។

ឥឡូវនេះ កូនស្រីរបស់ខ្ញុំធ្លាក់ខ្លួនឈឺហើយខ្ញុំទើបតែមកដល់ភ្នំពេញនេះកាលពីរសៀលនេះ ដើម្បីមកសុំថ្នាំពីមន្ទីរពេទ្យគន្ធបុប្ផាឱ្យកូនស្រីរបស់ខ្ញុំ។ ខ្ញុំគ្មានគំរោងមកសុំទាននៅភ្នំពេញនេះទេ ។ ទោះជាយ៉ាងណាក៏ដោយនៅពេលដែលខ្ញុំមកដល់ទីនេះ ខ្ញុំគ្មានលុយមួយរយដើម្បីទិញបាយហូបទេហើយក៏គ្មានលុយដើម្បីធ្វើដំណើរត្រលប់ទៅផ្ទះវិញដែរ ហេតុនេះហើយទើបខ្ញុំសំរេចចិត្តសុំទានគេ ហើយខ្ញុំចង់បានលុយមួយចំនួនឱ្យបានឆាប់ដើម្បីត្រឡប់ទៅផ្ទះវិញ ព្រោះបើសិនជាខ្ញុំនៅទីនេះយូរនោះ កូនប្រុសខ្ញុំដែលនៅឯផ្ទះក្នុងភូមិនោះនឹងមិនមានបាយសំរាប់ហូបទេ (ខ្ញុំបានទុកវាជាមួយម្តាយរបស់ ខ្ញុំ) ។

ខ្ញុំមានដីស្រែទំហំ ៥០អា ហើយផលស្រូវដែលទទួលបានគឺមិនគ្រប់គ្រាន់សំរាប់ហូបទេ (២៥ថាំង ស្រូវ) ដូចនេះ ខ្ញុំបានខ្ចីលុយពីអ្នកភូមិ ហើយគេយកការប្រាក់៣០%ក្នុងមួយខែ ។ ខ្ញុំក៏បានប្រើលុយដែលខ្ចីនេះដើម្បីព្យាបាលជំងឺកូនស្រីរបស់ខ្ញុំ និងចំណាយទៅលើតំរូវការផ្សេងៗទៀត ។ ខ្ញុំបានខ្ចីលុយនោះបីឆ្នាំមកហើយឥឡូវនេះខ្ញុំជំពាក់បំណុលគេ។ នៅក្នុងភូមិ នៅរដូវវស្សាខ្ញុំស៊ីឈ្នួលស្ទូងឱ្យអ្នកភូមិ ហើយគេឱ្យថ្លៃឈ្នួល ២,៥០០ រៀលក្នុងមួយថ្ងៃ រួមជាមួយអាហារបីពេលក្នុងមួយថ្ងៃ ។ ផ្ទះរបស់ខ្ញុំបានត្រូវភ្លើងឆេះកាលពី ៦ខែមុនដែលកាន់តែធ្វើឱ្យខ្ញុំមានការលំបាកកាន់តែខ្លាំងឡើងៗ ។

ខ្ញុំនឹងទៅផ្ទះភ្លាមបើសិនជាខ្ញុំមានលុយ ។ ខ្ញុំមិនចង់ស្នាក់នៅទីនេះយូរពេកទេ ។ ខ្ញុំចង់ទៅធ្វើស្រែនៅក្នុងភូមិវិញព្រោះ ឥឡូវនេះគឺជិតដល់រដូវវស្សាហើយ ។

# ករណីសិក្សាទី ២៨

នាងខ្ញុំ អាយុ២៧ឆ្នាំ ។ កាលពីឆ្នាំ ១៩៩៣ នាងខ្ញុំបានរៀបការជាមួយទាហានម្នាក់ ដែលគាត់មានអាយុ ៣៧ ឆ្នាំ។ ប្តីរបស់ខ្ញុំបានធ្លាក់ខ្លួនពិការប្រាំមួយឆ្នាំមកហើយ ។ ពួកយើងមានកូនស្រី ២នាក់ កូនស្រីបងអាយុ ៧ឆ្នាំ និងកូនប្អូនអាយុ ៤ឆ្នាំ ហើយសព្វថ្ងៃនេះនាងខ្ញុំកំពុងតែមានផ្ទៃពោះ ៧ខែទៀត។

នាងខ្ញុំរស់នៅក្នុងភូមិព្រែកអំពិល ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ មូលហេតុដែលនាងខ្ញុំព្រមទាំងប្តីនិងកូនបាននាំគ្នាមករស់នៅក្នុងទីក្រុងភ្នំពេញនេះ ពីព្រោះនៅភូមិពួកយើងអត់មានការងារធ្វើណាមួយប្តីក៏ពិការទៀត ។ ខ្ញុំមានដីស្រែទំហំ ១ហិចតាប៉ុន្តែឆ្នាំខ្លះខ្ញុំធ្វើស្រែមិនបានផលទាល់តែសោះ ដោយសារតែភាពរាំងស្ងួតនិងអត់មានលុយ គ្រប់គ្រាន់សំរាប់ទិញគ្រាប់ពូជឬជីសំរាប់ដាក់រំលែស ដោយសារតែបញ្ហាទាំងនេះហើយ ខ្ញុំនិងប្តីបានពិភាក្សាគ្នារួចក៏សំរេចចិត្តនាំគ្នាធ្វើដំណើរមកភ្នំពេញដើម្បីរកលុយក្នុង គោលបំណងធ្វើឱ្យស្ថានភាពរស់នៅរបស់ពួកយើងបានប្រសើរឡើង ។ នេះគឺជាលើកទីមួយដែលពួកយើងបាននាំគ្នាចាកចេញពីស្រុកហើយមកជួលផ្ទះគេនៅក្នុងតំលៃ ២៥.០០០រៀល/ខែ ។ ពួកយើងបានមករស់នៅក្នុងទីក្រុងភ្នំពេញនេះអស់រយៈពេល ៥ឆ្នាំមកហើយ ។

ចាប់តាំងពីពួកយើងមករស់នៅភ្នំពេញ ប្តីរបស់ខ្ញុំគ្មានការងារអ្វីធ្វើឡើយ ក្រៅពីមុខរបរដើរសុំទានគេនៅតាមមាត់ទន្លេនោះ ពេលដែលប្តីរបស់ខ្ញុំចេញទៅសុំទានម្តងៗគាត់តែងតែស្លៀកពាក់ឯកសណ្ឋានទាហ៊ានជានិច្ច ។ ក្នុងមួយថ្ងៃ គាត់អាចរកប្រាក់បានពី ២.០០០ ទៅ ៣.០០០រៀល ប៉ុន្តែលុយដែលគាត់រកបានមកជួនកាលគាត់មិនបានឱ្យវាមកខ្ញុំ សូម្បីតែមួយរៀលគឺគាត់យកលុយនោះទៅទិញស្រាផឹកស្រវឹងអួរទីណ្ឌ ។ ដោយឃើញប្តីស្រវឹងដូច្នេះ ជួនកាលខ្ញុំក៏បាននិយាយឃាត់គាត់ឱ្យឈប់ផឹកស្រាទៀតតែគាត់មិនស្តាប់ខ្ញុំទេ តែបែរជាគាត់មកវាយធ្វើបាបខ្ញុំនិងឈើច្រត់របស់គាត់ និងជេរប្រមាថខ្ញុំទៅវិញ ។

នាងខ្ញុំបានគិតឃើញថា ខ្ញុំមិនអាចរស់នៅដេកស៊ីពឹងផ្អែកទៅលើកំលាំងប្តីរបស់ខ្ញុំទៀតឡើយ ព្រោះឱ្យតែពេលស្រវឹងម្តងៗ គាត់តែងតែវាយធ្វើបាបខ្ញុំ ដូច្នេះកាលពីពាឆ្នាំមុននេះនាងខ្ញុំបានសំរេចចិត្តទៅស្រុកដើម្បីខ្ចីលុយបីជីពីបងប្អូនជីដូនមួយរបស់ខ្ញុំ សំរាប់ធ្វើដើមទុនរកស៊ីលក់របស់របរកំប៉ិកកំប៉ុកដូចជាទិញផ្លែឈូកលក់នៅឯភ្នំពេញ ។ តែពេលនោះ បងប្អូនជីដូនមួយរបស់ខ្ញុំបានឱ្យខ្ញុំយកដីស្រែ(១ហិចតា)របស់ខ្ញុំទៅដាក់បញ្ចាំឱ្យគេ

បើមិនដូច្នោះទេ គេមិនព្រមឱ្យលុយខ្ញុំខ្ចីឡើយ ព្រោះពួកគេខ្លាចខ្ញុំគ្មានសមត្ថភាពរកប្រាក់សងគេវិញ ។ ខ្ញុំក៏យល់ព្រមទៅនឹងសំនើរបស់ពួកគេ ប៉ុន្តែសព្វថ្ងៃនេះដីរបស់ខ្ញុំបានក្លាយទៅជាកម្មសិទ្ធរបស់ពួកគេហើយ នេះក៏ដោយសារតែនាងខ្ញុំគ្មានលុយលោះយកដីនោះមកវិញ ។

បន្ទាប់ពីបានលុយពាជីនោះមក នាងខ្ញុំក៏បានទៅទិញឈូកពីផ្សារមកលក់នៅមាត់ទន្លេនិងតាមសួន ហើយក្នុងមួយថ្ងៃ នាងខ្ញុំចំណេញបាន ១,០០០-២,០០០រៀល ។ ប៉ុន្តែឥឡូវនេះមុខរបររបស់ខ្ញុំត្រូវបានធ្លាក់ចុះ ដោយសារតែមិនសូវមានមនុស្សមកដើរលេងហើយម្យ៉ាងទៀតត្រូវបង់លុយថ្លៃឈ្នួលផ្ទះទៀត ។

លុះ ២ឆ្នាំក្រោយមកនាងខ្ញុំក៏បានត្រឡប់ទៅភូមិម្តងទៀតដើម្បីខ្ចីលុយ ២០០,០០០រៀលពីអ្នកចងការប្រាក់យកមកព្យាបាលជើងប្តីរបស់ខ្ញុំ ព្រោះកាលនោះជើងរបស់គាត់ឈឺចុកចាប់ខ្លាំងណាស់ ។ អ្នកចងការប្រាក់នោះបានប្រាប់ខ្ញុំថា ប្រសិនបើខ្ញុំចង់បានលុយនោះទាល់តែខ្ញុំយករបស់ទៅបញ្ចាំអ្វីក៏បានដែរ តែនៅពេលនោះនាងខ្ញុំគ្មានអ្វីទាល់តែសោះ ដូច្នេះខ្ញុំក៏បានត្រឡប់មកផ្ទះវិញហើយក៏បានពិគ្រោះជាមួយម្តាយរបស់ខ្ញុំពីរឿងបញ្ហានេះ ។ ម្តាយរបស់ខ្ញុំអាណិតខ្ញុំខ្លាំងណាស់ គាត់ក៏បាននិយាយប្រាប់ខ្ញុំថាគាត់និងយកប្លង់ដីផ្ទះរបស់គាត់ដែលមានទំហំ ១៣ម៉ែត្រ x ២៥ម៉ែត្រទៅបញ្ចាំ។ ជារៀងរាល់ខែម្តាយរបស់ខ្ញុំត្រូវចេញសងការប្រាក់ ៤០,០០០រៀល ហើយពួកគេក៏បាននិយាយប្រាប់ពួកខ្ញុំផងដែរថា នៅពេលណាក៏ដោយ ឱ្យតែខ្ញុំមានលុយសងពួកគេវិញនោះ ពួកគេនិងប្រគល់ដីនោះមកឱ្យម្តាយខ្ញុំវិញ ។

ខ្ញុំបានឈប់លក់ផ្លែឈូកអស់រយះពេលមួយឆ្នាំមកហើយ។ ខ្ញុំបានទៅដើរសុំទាននៅម្តុំផ្សារទួលទំពូង ផ្សារថ្មី ផ្សារកណ្តាល អូរឬស្សី ជាមួយអ្នកសុំទានដទៃទៀតវិញ ។ ជួនកាលពួកយើងនាំគ្នាដើរទៅសុំទានតែពេលណាមានលុយនាំគ្នាជិះម៉ូតូឌុបទៅ ។ ក្នុងមួយថ្ងៃនាងខ្ញុំអាចរកលុយបានពី ២,០០០-៣,០០០ រៀល តែថ្ងៃខ្លះក៏រកមិនបានដែរ ។

បន្ទាប់ពីប៊ូឌិញត្រូវបានឆេះមកខ្ញុំក៏គ្មានផ្ទះជួលសំរាប់ជួលនៅទៀតដែរ សព្វថ្ងៃនេះនាងខ្ញុំបានសុំការអនុញ្ញាតិពីប្រធានសង្កាត់ដើម្បីសង់កូនខ្ទមមួយនៅម្តុំម្លុកប៊ូឌិញ ហើយលោកពូប្រធានសង្កាត់នោះក៏បានប្រាប់ខ្ញុំថា គាត់និងបញ្ជូនពួកយើងឱ្យទៅនៅអន្លង់ក្ងាន ប៉ុន្តែខ្ញុំមិនដឹងថាពេលណាទើបគាត់បញ្ជូនពួកយើងទៅឡើយ ។

&& ☆☆☆ &&

# ករណីសិក្សាទី ២៩

ខ្ញុំឈ្មោះ ឃឿន អាយុ ៥៧ឆ្នាំ ហើយខ្ញុំជាស្ត្រីមេម៉ាយ ។ ខ្ញុំមានកូន ៥នាក់ (ស្រី២នាក់ ប្រុស៣នាក់) ហើយកូនស្រីម្នាក់និងកូនប្រុសម្នាក់ ពួកគេបានរៀបការរួចហើយ ។ ខ្ញុំរស់នៅភូមិគងតី, ឃុំស្ពុក, ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

ខ្ញុំមានដីស្រែទំហំមួយហិចតា ប៉ុន្តែខ្ញុំមិនអាចធ្វើស្រែលើដីនេះបានទេកាលពីពីរឆ្នាំមុន ដោយសារមានគ្រោះរាំងស្ងួត ។ កាលពីខែមុន ខ្ញុំបានទៅខ្ចីលុយចំនួន១០,០០០-២០,០០០រៀល ពីម្ចាស់អ្នកចងការប្រាក់ហើយគាត់មិនគិតការប្រាក់ពីខ្ញុំទេ ដោយសារគាត់រស់នៅក្នុងភូមិជាមួយខ្ញុំ ចំណែកលុយនោះបានទិញ បន្លែ សាច់ និងសំភារៈតំរូវការផ្សេងៗ ។

ខ្ញុំបានមកដល់ភ្នំពេញកាលពីម្សិលមិញ ។ ខ្ញុំគ្មានគំរោងមកសុំទាននោះទេ ប៉ុន្តែខ្ញុំមកស្វែងរកកូនប្រុសរបស់ខ្ញុំ ដែលវាបានមកធាក់ស៊ីក្លូនៅភ្នំពេញ ដើម្បីសុំលុយវាយកទៅស៊ីការអ្នកនៅក្នុងភូមិ ។ តែជាអកុសល ខ្ញុំរកវាមិនឃើញទាល់តែសោះ ហើយខ្ញុំគ្មានប្រាក់សំរាប់ទិញម្ហូបនិងធ្វើសាហ៊ុយត្រឡប់ទៅភូមិវិញទេ ទើបខ្ញុំសំរេចចិត្តដើរសុំទានដើម្បីសន្សំលុយត្រឡប់ទៅផ្ទះវិញ ។ នៅពេលយប់ខ្ញុំដេកនៅផ្ទះប្អូនជីដូនមួយរបស់ខ្ញុំ ។

# ករណីសិក្សាទី ៣០

នាងខ្ញុំអាយុ ៤៨ឆ្នាំ ។ ប្តីរបស់ខ្ញុំអាយុ ៤៩ឆ្នាំ យើងរស់នៅក្នុង ភូមិព្រា ឃុំស្វាយជ្រុំ ស្រុកមេសាង ខេត្តព្រៃវែង ។ ពួកយើងមានកូនទាំងអស់ ៩នាក់(ស្រី៧ប្រុស២នាក់) ។ កូនប្រុសរបស់ខ្ញុំម្នាក់បានមកបួសជាលោកសង្ឃ (វត្តនៅក្នុងភូមិព្រា) កូនស្រី៣នាក់បានមកធ្វើការនៅរោងចក្រនៅឯភ្នំពេញ ចំណែកកូន៥នាក់ទៀតគឺគ្មានការងារធ្វើឡើយ ។

នាងខ្ញុំមានដីស្រែកន្លះហិចតា ប៉ុន្តែផលស្រូវដែលយើងប្រមូលបានពីការច្រូតកាត់នោះ គឺមិនគ្រប់គ្រាន់ដើម្បីចិញ្ចឹមកូនឡើយព្រោះពួកយើងមានកូនច្រើននាក់ណាស់ ហើយពួកគេសុទ្ធតែនៅក្មេងនិងមិនទាន់មានការងារធ្វើទៀត ដូច្នេះកាលពីខែវិច្ឆិកា ២០០១ឆ្នាំ មុនខ្ញុំនិងប្តីរបស់ខ្ញុំបានសំរេចចិត្តយកដីស្រែនោះទៅបញ្ចាំអ្នកភូមិក្នុងតំលៃ ១០០,០០០រៀល សំរាប់យកទៅទិញអង្ករនិងម្ហូបអាហារនិងបង់ថ្លៃសាលាកូន ។ ពួកគេបានប្រាប់ខ្ញុំថា នៅពេលណាក៏ដោយឱ្យតែខ្ញុំយកលុយ ១០០,០០០រៀល ទៅសងគេវិញនោះពួកគេនឹងប្រគល់ដីស្រែនោះមកឱ្យខ្ញុំវិញ ។ កាលពីខែមករាកន្លងទៅនេះ ខ្ញុំបានទៅខ្ចីលុយ៣០០,០០០រៀល ពីអ្នកភូមិដើម្បីចាយវាយរាល់ការចំណាយនៅក្នុងគ្រួសារ ព្រោះប្រាក់ដែលខ្ញុំបានមកពីការបញ្ចាំដីស្រែនោះ គឺវាមិនគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់គ្រួសារខ្ញុំបានយូរអង្វែងឡើយ ។ ក្នុងមួយខែពួកគេគិតការប្រាក់ពីខ្ញុំ ២០% ។

នៅក្នុងភូមិពួកយើងគ្មានមុខរបរអ្វីធ្វើឡើយក្រៅពីធ្វើស្រែមួយមុខនោះ ។ ដោយសារតែបញ្ហានេះហើយទើបខ្ញុំនិងប្តីរបស់ខ្ញុំសំរេចចិត្តមកភ្នំពេញ យើងមកភ្នំពេញនេះអស់រយៈពេល៧-៨ខែ ហើយដោយទុកឱ្យកូនៗនៅផ្ទះកណ្តោចកណ្តែងតែឯង ។ សព្វថ្ងៃនេះប្តីរបស់ខ្ញុំធ្វើការជាកម្មករសំណង់ក្នុងមួថ្ងៃគាត់អាចរកលុយបានពី ៦០០០-៨០០០រៀល តែថ្ងៃខ្លះក៏រកមិនបានដែរ ។ នៅពេលណាដែលប្តីរបស់ខ្ញុំរកលុយមិនបាន ខ្ញុំតែងតែទៅដើរសុំទានគេដោយក្នុងមួយថ្ងៃខ្ញុំអាចសុំបានពី ២,០០០-៣,០០០រៀល ។

ចាប់តាំងពីយើងធ្លាក់ខ្លួនជំពាក់បំណុលគេពេលណាមក ពីមួយថ្ងៃទៅមួយថ្ងៃស្ថានភាពរស់នៅរបស់ពួកយើងគឺកាន់តែយ៉ាប់យឺនទៅៗ ព្រោះជារៀលរាល់ខែយើងមិនអាចរកលុយមកបង់ថ្លៃការប្រាក់គេឱ្យបានគ្រប់ចំនួន ។ កាលពីខែមុន ដោយសារតែស្ថានភាពលំបាកពេកខ្ញុំក៏បានឱ្យកូនស្រីរបស់ខ្ញុំ៣នាក់មកភ្នំពេញដើម្បីរកការងារធ្វើនៅឯរោងចក្រ ប៉ុន្តែពួកវាត្រូវបានគេទារម្នាក់ប៤០ដុល្លាទើបគេឱ្យចូលធ្វើការនៅក្នុងរោងចក្រកាត់ដេរ

ពេលញូដូច្នេះខ្ញុំរួមទាំងប្ដីរបស់ខ្ញុំបានសំរេចចិត្តទៅខ្ចីលុយ ១២០ដុល្លា ពីអ្នកចងការប្រាក់ ដើម្បីយកមកឱ្យពួកគេដោយក្នុងមួយខែខ្ញុំត្រូវបង់ឱ្យពួកគេ ៤៦,៨០០រៀលថ្លៃការប្រាក់ (ប្រហែល១០ភាគរយ) ។ កូនស្រីរបស់ខ្ញុំបានប្រាប់ខ្ញុំថាវានឹងសងលុយនោះទៅគេវិញ នៅពេលដែលវាបើកប្រាក់ខែ ។

នៅពេលយប់ពួកយើងខ្ញុំទាំងពីរនាក់ប្ដីប្រពន្ធរួមជាមួយគ្នាសុំទាន និងកម្មករសំណង់ផ្សេងទៀតស្នាក់នៅមុខវត្តបុទុម ។ មានពេលខ្លះពួកចោរបានមកលួចយកលុយ ពួកយើងអស់នៅពេលដែលពួកយើងកំពុងតែដេកលក់ ប៉ុន្តែខ្ញុំមិនទាន់មានបទពិសោធន៍ជួបប្រទះនូវបញ្ហានេះនៅឡើយ ។

នៅពេលដែលខ្ញុំសន្សំលុយបានច្រើន ខ្ញុំនឹងត្រលប់ទៅផ្ទះវិញ ដើម្បីយកលុយទៅសងបំណុលគេ ។

&& ☆☆☆ &&

# ផ្នែកទី៣ ៈ ការវិភាគទិន្នន័យ

បន្ទាប់ពីយើងប្រមូលករណីសិក្សារួចមក ក្រុមស្រាវជ្រាវបានធ្វើការសំរេចចិត្តដាក់បញ្ចូលនូវទិន្នន័យដែលយើងប្រមូលបានទៅក្នុងតារាងទិន្នន័យនិងធ្វើការវិភាគ ។ ខាងក្រោមនេះគឺជាលទ្ធផលនៃការវិភាគតារាងទិន្នន័យ ។

## ***១. ទីកន្លែងដែលស្ត្រីសុំទានមកសុំ***

**តារាងទី ១៖ ឈ្មោះខេត្ត, ស្រុក, ឃុំ និង ភូមិ**

| **ខេត្ត** | **ស្រុក** | **ឃុំ** | **ភូមិ** |
|---|---|---|---|
| ព្រៃវែង | មេសាង | ត្រពាំងស្រែ | ម៉ារិញ |
| ព្រៃវែង | មេសាង | ត្រពាំងស្រែ | ព្រហ៊ូត |
| ព្រៃវែង | មេសាង | ត្រពាំងស្រែ | ព្រៃគុយ |
| ព្រៃវែង | មេសាង | ត្រពាំងស្រែ | ត្រពាំងស្រែ |
| ព្រៃវែង | មេសាង | អង្គរស | បង្រៃ |
| ព្រៃវែង | មេសាង | អង្គរស | អង្គរស |
| ព្រៃវែង | មេសាង | អង្គរស | ពន្លៃ |
| ព្រៃវែង | មេសាង | ស្វាយជ្រុំ | ស្វាយជ្រុំ |
| ព្រៃវែង | មេសាង | ស្វាយជ្រុំ | ព្រា |
| ព្រៃវែង | មេសាង | ព្រៃខ្មេស | ព្រៃខ្មេស |
| ព្រៃវែង | កំពង់ត្របែក | ព្រៃពោន | ព្រៃពោន |
| ព្រៃវែង | កំពង់ត្របែក | គោកខ្ចក | រមាសឈរ |
| ព្រៃវែង | កំពង់ត្របែក | កំពង់ត្របែក | កំពង់ត្របែល |
| ព្រៃវែង | បាភ្នំ | ធាយ | ព្យោង |
| ព្រៃវែង | ពារាំង | រាប | រាប |
| ព្រៃវែង | ព្រះស្តេច | ក្រាំងស្វាយ | ជ្រៃ |
| ព្រៃវែង | ពាមជរ | ក្រាំងត្រយ៉ង | ព្រីង |
| **សរុប ១៧ (៥៦.៧%)** | | | |

| | | | |
|---|---|---|---|
| ស្វាយរៀង | ស្វាយរៀង | ស្វាយរៀង | ស្វាយរៀង |
| ស្វាយរៀង | ស្វាយ ។ប | រមាំងខ្នុរ | ក្រញ៉ូង |
| ស្វាយរៀង | ស្វាយជ្រុំ | អង្គតាសូវ | ស្វាយមីញ |
| ស្វាយរៀង | រំដួល | ស្វាយចេក | ច្រកស្គរ |
| **សរុប ៤ (១៣.៣%)** | | | |
| កំពង់ចាម | ស្រីសន្ធរ | ព្រែកពោធិ៍ | ព្រែកពោធិ៍ |
| កំពង់ចាម | ស្រីសន្ធរ | ព្រែកពោធិ៍ | ព្រែកពោធិ៍ |
| កំពង់ចាម | កោះសូទិន | កោះសូទិន | ជីហែ |
| **សរុប ៣ (១០%)** | | | |
| កំពង់ស្ពឺ | ឧត្តុង្គ | រាំងចាស់ | ឃ្លាំងក្រោម |
| កំពង់ស្ពឺ | គងពិសី | ស្តុក | គងពី |
| **សរុប ២ (៦.៧%)** | | | |
| កំពត | ជុំគីរី | ត្រពាំងវែង | ត្រពាំងវែង |
| កំពត | ជុំគីរី | ត្រពាំងរាំង | ដូនឪ |
| **សរុប ២ (៦.៧%)** | | | |
| តាកែវ | បាទី | ពុទ្ធស | តាំងឫស្សី |
| **សរុប ១ (៣.៣%)** | | | |
| កណ្តាល | ខ្សាច់កណ្តាល | ព្រែកអំពិល | ព្រែកអំពិល |
| **សរុប ១ (៣.៣%)** | | | |

សន្ទស្សន៍នេះបង្ហាញអោយឃើញថាក្នុងចំណោមស្ត្រីសុំទានចំនួន៣០នាក់ដែលក្រុមការងារយើងបានសំភាសន៍ គឺមានស្ត្រីជាអ្នកសុំទានច្រើនជាង៥០% បានមកពីខេត្តព្រៃវែង និងភាគច្រើនមកពីស្រុកមេសាង និងស្រុកកំពង់ត្របែក។

ខេត្តព្រៃវែងមិនសូវមានប្រភពទឹកច្រើនដែលអាចសំរួលការប្រើប្រាស់បានរបស់ប្រជាជនគ្រប់គ្រាន់ទេ ។ ជាងនេះទៅទៀត ស្រុកមេសាងនិងស្រុកកំពង់ត្របែកគឺជាស្រុកពីរនៅក្នុងខេត្តព្រៃវែង ដែលគ្មានទន្លេហូរ

កាត់ឡើយ ហើយប្រជាជនពិបាកក្នុងការប្រើប្រាស់ទឹក ។ ដូច្នេះការងារធ្វើស្រែចំការរបស់ប្រជាកសិករ គឺពឹងផ្អែកទាំងស្រុងទៅលើទឹកភ្លៀង ហើយក្នុងមួយឆ្នាំពួកគេអាចធ្វើស្រែបានតែម្តងប៉ុណ្ណោះគឺនៅក្នុងរដូវវស្សា ។ ប៉ុន្តែក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សូម្បីតែធ្វើស្រែតែម្តងក្នុងមួយឆ្នាំក៏ប្រជាកសិករយើងមិនអាចធ្វើបានផងដោយសារតែភាពរាំងស្ងួតនិងទឹកជំនន់ ។ នៅរដូវដកស្ទូង សំណាបត្រូវការទឹកដើម្បីដុះលូតលាស់ ប៉ុន្តែនៅដើមរដូវវស្សាបែរជាគ្មានភ្លៀងធ្លាក់ទៅវិញ ហើយសំណាបត្រូវបានបំផ្លិចបំផ្លាញ ។ ជួនកាលសន្ទូងកំពុងតែចាប់ផ្តើមចេញពន្លកល្អ ប៉ុន្តែត្រូវបានបំផ្លិចបំផ្លាញទៅវិញដោយសារតែទឹកជំនន់ ។

***រូបទី ១: ផែនទីនៃព្រះរាជាណាចក្រកម្ពុជា***



✧ ***ចំណាំៈ កន្លែងដែលគួសបន្ទាត់ក្រហមជុំវិញគឺជាទីតាំងខេត្តព្រៃវែង***

ជាការពិតណាស់ ខេត្តព្រៃវែងគឺជាខេត្តមួយដែលផលិតស្រូវនៅក្នុងប្រទេសកម្ពុជា ហើយប្រជាជនភាគច្រើនគឺជាកសិករហើយវាក៏ជាខេត្តក្រីក្រមួយក្នុងចំណោមខេត្តក្រីក្រដទៃទៀតដែរ ។ ការធ្វើស្រែនៅក្នុងប្រទេសកម្ពុជាគឺប្រភេទកសិកម្មប្រពលវប្បកម្ម ហើយប្រជាជនភាគច្រើនគឺធ្វើស្រូវវស្សាដែលត្រូវការទឹកដើម្បីឱ្យសន្ទូងលូតលាស់បានល្អ និងកំលាំងសត្វពាហនៈអូសទាញ ។ គ្រួសារខ្លះពុំមានធនធានគ្រប់គ្រាន់ក្នុងការធ្វើស្រែឡើយ ដូច្នេះពួកគាត់ធ្វើស្រែបង្វាស់ដៃគ្នាជាមួយអ្នកជិតខាង ប៉ុន្តែប្រសិនបើនរណាមានប្រាក់វិញ គឺពួកគាត់អាចជួលកំលាំងពលកម្មឱ្យមកជួយធ្វើស្រែបាន ។

មានកត្តាជាច្រើនដែលធ្វើឱ្យប្រទេសកម្ពុជាប្រឈមមុខទៅនិងគ្រោះរាំងស្ងួតនិងគ្រោះទឹកជំនន់ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ជាពិសេសគឺការបំផ្លិចបំផ្លាចបរិស្ថានជាពិសេសគឺការកាប់ព្រៃឈើខុសច្បាប់ ។ ព្រៃឈើមានប្រយោជន៍ជាច្រើនយ៉ាងណាស់ដូចជាៈ- ទាក់ទាញទឹកភ្លៀង, ជួយរក្សាទ្រង់ទ្រាយដី និងធ្វើឱ្យដីមានជីជាតិល្អជាដើម ។ ប៉ុន្តែនៅពេលដែលព្រៃឈើទាំងនោះត្រូវបានគេកាប់រលំអស់ទៅ ធ្វើអាកាសធាតុមានការប្រែប្រួល ភ្លៀងធ្លាក់មិនទៀងទាត់ និងធ្វើឱ្យដីក្លាយទៅជាគ្មានជីជាតិ ។

ក្រៅពីបញ្ហាទាំងនេះ ប្រទេសកម្ពុជាបានបើកចំហរទីផ្សារសេដ្ឋកិច្ចទីផ្សារសេរី ហើយពូជស្រូវប្រភេទថ្មីៗត្រូវបានណែនាំឱ្យប្រជាកសិករប្រើ, ជីគីមី, ថ្នាំសំលាប់សត្វល្អិតជាដើម ត្រូវបានប្រជាជនប្រើជំនួសរបៀបបុរាណដែលពួកគាត់ធ្លាប់ប្រើទៅវិញ (ដូចជាការរក្សាផលស្រូវទុកធ្វើពូជ, ប្រើលាមកសត្វធ្វើជាជី) ។ ពូជស្រូវថ្មីដែលកសិករប្រើប្រាស់គឺត្រូវការដាក់ជីច្រើន, ថ្នាំសំលាប់សត្វល្អិត, និងប្រើទឹកច្រើនទើបទទួលផលល្អ ប៉ុន្តែគុណភាពស្រូវមិនសូវល្អ (មិនសូវឆ្ងាញ់ ឬខ្សោះ) និងធ្វើអោយដីកាន់តែខ្សោះជីជាតិឡើងៗជារៀងរាល់ឆ្នាំ ។ ដើម្បីទទួលបាននូវពូជស្រូវថ្មីយកមកបង្កបង្កើនផលនោះ ប្រជាកសិករត្រូវការចំណាយដើមទុនច្រើន ហើយមធ្យោបាយតែមួយដែលពួកគាត់អាចទទួលបានលុយច្រើននោះ គឺខ្ចីលុយពីអ្នកចងការប្រាក់ឬអង្គការក្រៅរដ្ឋាភិបាលមួយចំនួនដែលមានកម្មវិធីផ្តល់ឥណទានអោយប្រជាជនខ្ចី ។ ពួកគាត់ក៏ត្រូវការទឹកបន្ថែមទៀតដែរក្នុងការធ្វើស្រែរបស់គាត់ ហើយពួកគាត់ត្រូវតែចំណាយលុយសំរាប់ទឹកពីព្រោះភ្លៀងធ្លាក់មានការប្រែប្រួលមិនទៀងទាត់ និងគ្រោះរាំងស្ងួតជាប់ៗគ្នាពីរ-បីឆ្នាំ ។ នេះមានន័យថាប្រជាកសិករត្រូវប្រថុយប្រថានក្នុងការធ្វើស្រែហើយទីបញ្ចប់ ស្រូវរបស់គាត់ត្រូវបានបំផ្លិចបំផ្លាញដោយគ្រោះមហន្តរាយធម្មជាតិ ហើយពួកគាត់ក៏បានធ្លាក់ខ្លួនជំពាក់បំណុលគេ ។

កត្តាទាំងអស់នេះហើយធ្វើអោយមុខរបរធ្វើស្រែរបស់ប្រជាកសិករយើងធ្លាក់ចុះ ជីវភាពរបស់ប្រជាជនយើងកាន់តែយ៉ាប់ទៅៗហើយសេដ្ឋកិច្ចជាតិមានការលូតលាស់យឺត ។ ជីវភាពរស់នៅរបស់ប្រជាជន គឺសំខាន់ខ្លាំងណាស់ ហើយនៅពេលដែលប្រជាជនជួបប្រទះនូវបញ្ហាលំបាកជាច្រើននោះ គឺពួកគាត់មិនអាចរង់ចាំសេចក្តីស្លាប់បានឡើយ ពួកគាត់ត្រូវតែស្វែងរកការងារផ្សេងទៀតធ្វើដើម្បីរកលុយយកមកចិញ្ចឹមជីវិតរបស់ពួកគាត់ ក្នុងនោះមានប្រជាជនមួយចំនួនជាពិសេសស្ត្រីបានជ្រើសរើសយកមុខរបរធ្វើជាអ្នកសុំទាននៅទីក្រុង ។

## ២. អាយុរបស់ស្ត្រីអ្នកសុំទាន

ឆ្លងតាមរយៈកិច្ចសំភាសន៍យើងអាចមើលឃើញថា អ្នកសុំទានគឺជាក្រុមមនុស្សដែលមានគ្រប់អាយុទាំងអស់គិតចាប់ពី២៥-៨២ឆ្នាំ ។ គ្មានក្រុមមនុស្សដែលមានអាយុជាក់លាក់ណាមួយជ្រើសរើសមុខរបរដើរសុំទាននោះទេ តែមនុស្សគ្រប់វ័យអាចក្លាយមកជាអ្នកសុំទាន ។

មនុស្សដែលមានអាយុក្រោម៥០ឆ្នាំ គឺជាអាយុដែលមានកំលាំងពេញលេញដែលអាចជួយទំនុកបំរុងសេដ្ឋកិច្ចក្នុងគ្រួសារក៏ដូចជាសហគមន៍ផងដែរ ។ ប៉ុន្តែដោយសារតែគ្មានដីដើម្បីធ្វើស្រែ និងក្នុងភូមិគ្មានការងារធ្វើក្រៅពីមុខរបរធ្វើស្រែ បានធ្វើឱ្យពួកគាត់មួយចំនួនបានកំពុងតែដើរសុំទានគេនៅទីក្រុងនិងតំបន់ផ្សេងៗទៀត ។

### តារាងទី ២_អាយុ

| អាយុគិតជាឆ្នាំ | ប្រេកង់ | ភាគរយ | ភាគរយបូកបន្ថែម |
|---|---|---|---|
| ២៥ | ១ | ៣,៣ | ៣,៣ |
| ២៧ | ១ | ៣,៣ | ៦,៧ |
| ៣១ | ១ | ៣,៣ | ១០ |
| ៣២ | ១ | ៣,៣ | ១៣,៣ |
| ៣៤ | ២ | ៦,៧ | ២០ |
| ៣៥ | ២ | ៦,៧ | ២៦,៧ |
| ៣៦ | ១ | ៣,៣ | ៣០ |
| ៣៧ | ១ | ៣,៣ | ៣៣,៣ |
| ៤០ | ១ | ៣,៣ | ៣៦,៧ |
| ៤១ | ១ | ៣,៣ | ៤០ |

| | | | |
|---|---|---|---|
| ៤៣ | ១ | ៣,៣ | ៤៣,៣ |
| ៤៥ | ១ | ៣,៣ | ៤៦,៧ |
| ៤៧ | ២ | ៦,៧ | ៥៣,៣ |
| ៤៨ | ២ | ៦,៧ | ៦០ |
| ៥៥ | ១ | ៣,៣ | ៦៣,៣ |
| ៥៧ | ១ | ៣,៣ | ៦៦,៧ |
| ៦០ | ១ | ៣,៣ | ៧០ |
| ៦២ | ១ | ៣,៣ | ៧៣,៣ |
| ៦៣ | ១ | ៣,៣ | ៧៦,៧ |
| ៦៥ | ១ | ៣,៣ | ៨០ |
| ៦៦ | ១ | ៣,៣ | ៨៣,៣ |
| ៦៧ | ១ | ៣,៣ | ៨៦,៧ |
| ៦៨ | ១ | ៣,៣ | ៩០ |
| ៧០ | ២ | ៦,៧ | ៩៦,៧ |
| ៨២ | ១ | ៣,៣ | ១០០ |
| **សរុប** | **៣០** | **១០០** | |

ម្យ៉ាងវិញទៀត មនុស្សដែលមានអាយុចាប់ពី៥៥ឆ្នាំឡើងទៅ គឺជាក្រុមមនុស្សដែលធ្លាប់បានធ្វើការងារយ៉ាងច្រើន និងបានលះបង់ច្រើនសំរាប់គ្រួសារនិងកូនៗរបស់ពួកគេ ប៉ុន្តែទីបញ្ចប់នៃជីវិត ពួកគាត់មិនបានសប្បាយរីករាយនឹងវ័យចាស់ជរារបស់គាត់ដោយមានកូនចៅយកចិត្តទុកដាក់ថែរក្សាគាត់ឡើយ តែគាត់បែជាធ្លាក់ខ្លួនមកសុំទាននៅទីក្រុងដើម្បីចិញ្ចឹមខ្លួននិង/ចៅៗទៅវិញ ។

## ៣. ស្ថានភាពគ្រួសារ

អ្នកសុំទានជាង៥០%ចិញ្ចឹមកូនតែម្នាក់ឯងព្រោះប្តីរបស់ពួកគាត់ស្លាប់ចោលកាលពីជំនាន់ប៉ុលពត រឺស្លាប់ដោយសារជំងឺគ្រុនចាញ់ឬតេតាណុស ។ល ។ មរណៈភាពរបស់ប្តីបានបន្សល់ទុកនូវអម្រែកមួយយ៉ាងធ្ងន់ដល់ពួកគាត់និងកូនៗ ព្រោះនៅពេលដែលប្តីរបស់ពួកគាត់នៅមានជីវិតនោះ គាត់បានឈឺហើយប្រពន្ធបានខ្ចីលុយគេក្នុងអត្រាការប្រាក់ខ្ពស់ ដើម្បីយកមកបង់ថ្លៃព្យាបាលសុខភាពនិងម្ហូបអាហារ ។ លុយដែលប្រពន្ធបានខ្ចីមកនោះ

គឺត្រូវបានប្រើដើម្បីដើម្បីទិញថ្នាំមកសង្គ្រោះជីវិតរបស់ប្តីគាត់ និងទិញម្ហូបអាហារសំរាប់ឱ្យកូនហូបចុក មិនមែនយកទៅប្រើដើម្បីប្រកបការងារដែលបានកំរៃនោះឡើយ ។

## តារាងទី ៣.១- ស្ថានភាពគ្រួសាររបស់ស្ត្រីសុំទាន

| ស្ថានភាពគ្រួសារ | ហ្វ្រេកង់ | ភាគរយ | ភាគរយបូកបន្ថែម |
|---|---|---|---|
| មេម៉ាយ | ១៧ | ៥៦,៧ | ៥៦,៧ |
| អ្នកមានប្តី | ១០ | ៣៣,៣ | ៩០ |
| លែងលះ | ៣ | ១០ | ១០០ |
| **សរុប** | **៣០** | **១០០** | |

នេះមានន័យថា ស្ត្រីក៏ដូចជាក្រុមគ្រួសាររបស់នាងគឺបានធ្លាក់ទៅក្នុងស្ថានភាពមួយពិបាកជាងមុនរួចទៅហើយ ចាប់តាំងពីថ្ងៃដែលនាងបានទៅខ្ចីលុយគេមកប្រើនោះ ពីព្រោះវាគ្មានវិធីណាមួយដើម្បីទទួលបាននូវប្រាក់ចំនេញពីលុយដែលគេយកទៅប្រើនោះឡើយ ។ ពួកគេមានតែវិធីមួយគឺស្វែងរកប្រាក់ដើម្បីសងបំណុលវិញតែប៉ុណ្ណោះ ។

ប៉ុន្តែ បន្ទាប់ពីប្តីរបស់ខ្ញុំបានស្លាប់ទៅជីវភាពរបស់ពួកយើង នៅក្នុងគ្រួសារបានធ្លាក់ចុះដុនដាប ពីព្រោះខ្ញុំត្រូវចិញ្ចឹមកូនតែម្នាក់ឯងព្រោះពួកគេសុទ្ធតែនៅក្មេង។ជាពិសេស ខ្ញុំមិនមានដីសំរាប់ធ្វើស្រែទេ **ខ្ញុំបានយកដីស្រែទៅបញ្ចាំឱ្យអ្នកចងការប្រាក់នៅក្នុងតំលៃ មាស៧ជី ដើម្បីព្យាបាលប្តីរបស់ខ្ញុំកាលពីគាត់ឈឺ** ។ ឥឡូវនេះពួកយើងគ្មានលុយដើម្បីលោះយកដីមកវិញទេ ។(ករណី សិក្សាទី៤)

មូលហេតុដែលពួកយើងមកសុំទាននៅភ្នំពេញនេះគឺដើម្បីមករកលុយយកទៅលោះដីស្រែដែលមានទំហំ៤០អាពីអ្នកចងការប្រាក់**វិញព្រោះកាលពីមុនខ្ញុំបានយកដីនោះទៅបញ្ចាំក្នុងតំលៃ ៣-៤ជីមាស សំរាប់យកលុយមកមើលជំងឺប្តីរបស់ខ្ញុំ ។ សព្វថ្ងៃនេះពួកគេកំពុងធ្វើស្រែនៅលើដីនោះ ពួកគេបានប្រាប់ខ្ញុំថានៅពេលណា ដែលខ្ញុំមានលុយខ្ញុំអាចយកលុយទៅលោះយកដីស្រែនោះមកវិញបាន ។ ជារៀងរាល់ឆ្នាំពួកយើងរស់នៅពឹងផ្អែក ទៅលើផលស្រូវដែលយើងបានប្រមូលនៅរដូវច្រូតកាត់** និងរស់នៅទៅលើប្រាក់ចំណូលរបស់ប្តីខ្ញុំដែលបានមកពីការធ្វើកម្មករសំណង់ ប៉ុន្តែគាត់បានបាត់បង់ការងារនៅពេលដែលគាត់ធ្លាក់ខ្លួនឈឺដូច្នេះឥលូវនេះក្នុងមួយឆ្នាំ។ពួកយើងគ្មានរកប្រាក់ចំណូលចូលឡើយ។ (ករណីសិក្សាទី ៦)

នៅក្នុងករណីខ្លះទៀត ស្ត្រីត្រូវតែបញ្ចាំដីស្រែដើម្បីយកលុយមកព្យាបាលជំងឺរបស់ប្តីខ្លួន ។ ដីស្រែគឺជាជីវិត និងជាចំណូលរបស់សមាជិកនីមួយៗនៅក្នុងគ្រួសារ ហើយនៅពេលដែលដីស្រែត្រូវបានយកទៅដាក់បញ្ចាំ វាធ្វើឱ្យសេដ្ឋកិច្ចនៅក្នុងគ្រួសារធ្លាក់ចុះពីព្រោះថា គ្មានដីសំរាប់ធ្វើស្រែតទៅទៀតទេ ។

នៅភ្នំពេញគ្មានជំរើសណាសំរាប់អោយស្ត្រីយើងទទួលបានការងារល្អធ្វើឡើយ ដោយសារតែពួកគាត់ទទួលបានការសិក្សាទាបឬអ្នកខ្លះមិនចេះអក្សរហើយគ្មានលុយទៀត ។ ដូច្នេះជំរើសដែលនៅសល់ដ៏តិចតួចសំរាប់ពួកគាត់គឺការប្រកបមុខរបរធ្វើជាស្ត្រីរកស៊ីផ្លូវភេទ, កម្មកររោងចក្រ (គឺជាមុខរបរដែលពួកគេត្រូវការបង់លុយទើបអាចចូលធ្វើការបាន) អ្នករើសសំរាម អ្នកសុំទាន អ្នកបំរើតាមផ្ទះឬកម្មករសំណង់ ។ នៅតាមកន្លែងធ្វើការមួយចំនួនដូចជារោងចក្រ ការងារសំណង់និងអ្នកបំរើតាមផ្ទះ ពួកគាត់បានជួបប្រទះនូវការរើសអើងផ្នែកយេនឌ័រនៅកន្លែងធ្វើការងារ ។

បុរសអាចចូលធ្វើជាកម្មករសំណង់ហើយ ទទួលបានប្រាក់កំរៃច្រើនជាងនារី ។ ប៉ុន្តែជាការពិតណាស់ មានបុរសមួយចំនួនកំរផ្ញើរលុយទៅផ្ទះណាស់ ព្រោះគាត់គិតថាប្រាក់ដែលគាត់រកបានគឺវាស្ទើរតែមិនគ្រប់សំរាប់ខ្លួនគាត់ចំណាយនៅក្នុងទីក្រុងផង ។ ផ្ទុយទៅវិញ ទោះបីជាស្ត្រីយើងរកប្រាក់ចំណូលតិចជាងបុរសក៏ដោយ ក៏ពួកគាត់នៅតែផ្ញើរលុយទៅផ្ទះបានទៀងទាត់ឬញឹកញាប់ជាងបុរសទៅទៀតដើម្បីជួយទំនុកបំរុងនៅក្នុងគ្រួសារ ។ បទពិសោធន៍កន្លងមកដែលយើងដឹងតាមរយៈការធ្វើការសិក្សាស្រាវជ្រាវជាមួយកម្មកររោងចក្រ គឺកម្មការិនីនៅពេលដែលបើកប្រាក់ខែរួច ពួកគេតែងតែផ្ញើរលុយទៅផ្ទះជានិច្ចដើម្បីយកទៅជួយផ្គត់ផ្គង់គ្រួសាររបស់ពួកគេ ហើយពួកគេមិនបានសន្សំទុកសំរាប់ខ្លួនឯងឡើយ ។ ស្ថិតក្នុងលក្ខខ័ណ្ឌការងារជាកម្មករដូចគ្នា កម្មករបុរសកម្រផ្ញើរលុយទៅផ្ទះណាស់គឺពួកគេសន្សំលុយទុកសំរាប់ខ្លួនឯងជារៀងរាល់ខែ ។

ចំណែកស្ត្រីរកស៊ីផ្លូវភេទវិញបានសំរេចចិត្តលក់ខ្លួនប្រាណរបស់នាង ដើម្បីយកប្រាក់ទៅផ្គត់ផ្គង់សមាជិកនៅក្នុងគ្រួសារនៅឯភូមិ នាងមិនអាចរង់ចាំមើលក្រុមគ្រួសារនិងខ្លួនរបស់នាងដាច់ពោះស្លាប់បានឡើយ ។ បញ្ហាដែលកើតឡើងចំពោះស្ត្រីអ្នកសុំទានវិញក៏មិនខុសគ្នាដែរ ក្នុងមួយថ្ងៃពួកគាត់ភាគច្រើនអាចសុំបានតិចជាង ៤,០០០រៀល ប៉ុន្តែពួកគាត់ទាំងនោះនៅតែផ្ញើរលុយទៅផ្ទះ ដើម្បីបង់ថ្លៃការប្រាក់និងចំណាយទៅលើតំរូវការចាំបាច់ផ្សេងៗនៅក្នុងគ្រួសារ ទោះបីជាពួកគេត្រូវតែចិញ្ចឹមខ្លួនឯងនៅក្នុងទីក្រុងក៏ដោយ ។ ដូច្នេះយើងអាចមើលឃើញថា ស្ត្រីមានការទទួលខុសត្រូវខ្ពស់នៅក្នុងគ្រួសារមិនថាពួកគេនៅទីណា នៅក្នុងគ្រួសារឬក៏នៅឆ្ងាយពីគ្រួសារក៏ដោយ ។

មានថ្ងៃខ្លះ ខ្ញុំអាចសុំគេបានត្រឹមតែទិញបាយហូបសំរាប់មួយថ្ងៃតែប៉ុណ្ណោះ តែថ្ងៃណាដែលនាងខ្ញុំអាចសុំបានពី ១,០០០-២,០០០រៀលវិញនោះ ខ្ញុំតែងតែដក១០០០រៀលទុកសំរាប់សន្សំជានិច្ច ។ ចំពោះថ្ងៃសីលខ្ញុំអាចរកបាន ពី៥,០០០-៦,០០០រៀលក្នុងមួយថ្ងៃ ។ ខ្ញុំមានការព្រួយបារម្ភណ៍ខ្លាំងណាស់ចំពោះកូនស្រីនិងចៅ៧របស់ខ្ញុំ ដែលរស់នៅឯភូមិ ដូច្នេះរាល់ពេលដែលអ្នកភូមិជាមួយខ្ញុំត្រលប់ទៅផ្ទះនោះ ខ្ញុំតែងតែផ្ញើរលុយតាមគេ៥០០-១,០០០រៀល ដើម្បីយកទៅអោយកូនស្រីខ្ញុំទិញម្ហូប។ (ករណីសិក្សាទី៨)

នៅក្នុងករណីខ្លះទៀត យើងក៏បានរកឃើញដែរថា មានគ្រួសារខ្លះដែលប្តីប្រពន្ធរស់នៅជាមួយគ្នាស្ត្រីនៅតែទទួលខុសត្រូវក្នុងការបំពេញនូវតំរូវការនៅក្នុងគ្រួសារ ដោយសារប្តីរបស់គេជាមនុស្សប្រមឹក ជាមនុស្សអត់ការងារធ្វើ ជាមនុស្សលេងល្បែងស៊ីសង ។ នៅក្នុងគ្រួសារខ្លះទៀត បុរសជាប្តីបានទៅខ្ចីលុយគេយកទៅលេងល្បែងស៊ីសង ហើយប្រពន្ធត្រូវរកលុយដើម្បីសងបំណុលជំនួសប្តី ។

នាងខ្ញុំអាយុ ៤០ឆ្នាំ។ នាងខ្ញុំមានកូនទាំងអស់៤នាក់សុទ្ធតែប្រុស។ នាងខ្ញុំរស់នៅក្នុង*ភូមិដូនឪ ឃុំអូររាំង ស្រុកជុំគិរី ខេត្តកំពត* ។ **មុនពេលដែលនាងខ្ញុំមិនទាន់បានលែងលះប្តីនោះ ប្តីរបស់នាងខ្ញុំតែងតែផឹកស្រាស្រវឹង ហើយរករឿងវាយធ្វើបាបខ្ញុំហើយនិងកូន ។ ប៉ុន្តែសព្វថ្ងៃនេះគាត់បានរៀបការជាមួយនិងប្រពន្ធថ្មី ហើយពួកគេបាននាំគ្នាទៅរស់នៅឯក្រុងព្រះសីហនុអស់រយះពេលជិតមួយឆ្នាំហើយ។** (ករណីសិក្សាទី ១២)

ករណីខាងលើនេះបង្ហាញឱ្យឃើញថា ប្តីរបស់នាងមិនបានគិតអំពីអ្វីដែលកើតមានឡើងនៅក្នុងគ្រួសារទាំងមូលនោះទេ ប៉ុន្តែគាត់គ្រាន់តែគិតពីរឿងសប្បាយផ្ទាល់ខ្លួនគេតែប៉ុណ្ណោះ ។ នៅពេលដែលស្ត្រីមិនអាចធានានូវនិរន្តន៍ភាពនៃជីវិតរបស់សមាជិកនៅក្នុងគ្រួសារបានទេនោះ ព្រោះស្រូវក្នុងស្រែត្រូវបំផ្លាញដោយគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត គ្មានការងារធ្វើនៅក្នុងភូមិក្រៅពីធ្វើស្រែ គ្មានធនធានសំរាប់ឱ្យពួកគាត់រកប្រកបរបរបាននោះ ពួកគាត់ត្រូវមកទីក្រុងដើម្បីស្វែងរកការងារធ្វើ ។

**តារាងទី៣.២-ប្រសិនបើអ្នករៀបការ តើអ្នកមានបញ្ហានៅក្នុងគ្រួសារដែរឬទេ?**

| បញ្ហា | ហ្វ្រេកង់ | ភាគរយ | ភាគរយបូកបន្ថែម |
|---|---|---|---|
| ចាស | ៦ | ៦០ | ៦០ |
| ទេ | ៤ | ៤០ | ១០០ |
| **សរុប** | **១០** | **១០០** | |

ក្នុងចំណោមអ្នកសុំទាន១០នាក់ដែលបានរៀបការរួចហើយ គឺមាន៦០%បានជួបប្រទះនូវបញ្ហាជាច្រើន នៅក្នុងគ្រួសារ ហើយបញ្ហាចំបងគឺអំពើហិង្សានៅក្នុងគ្រួសារ ។ ប្រពៃណីវប្បធម៌ខ្មែរបានបង្ហាត់បង្រៀនឱ្យស្ត្រីខ្មែរជាច្រើនជំនាន់និងគ្រប់ពេលវេលានៅក្នុងជីវិតរបស់នាង ឱ្យគោរពនិងមិនត្រូវនិយាយ ឬធ្វើអ្វីប្រឆាំងនឹងប្តីរបស់នាងនោះទេ ។ ទាំងនេះហើយគឺជាមូលហេតុ ដែលធ្វើឱ្យស្ត្រីយើងមិនហ៊ាននិយាយការពិតនៅពេលដែលគេសួរគាត់ថា តើនៅក្នុងគ្រួសាររបស់គាត់មានបញ្ហាឬអត់នោះ គាត់តែងតែឆ្លើយតបមកវិញថាគាត់គ្មានបញ្ហាអ្វីទេ ។

ជាងនេះទៅទៀត ប្រសិនបើគាត់មានបញ្ហានៅក្នុងគ្រួសារដូចជាអំពើហិង្សាក្នុងគ្រួសារ បញ្ហានេះត្រូវបានសង្គមនិងអ្នកជិតខាងគិតថា ជាការខ្មាសអៀននិងអាប់អោនកិត្តិយសក្នុងការដែលគាត់និយាយរឿងទាំងនេះប្រាប់ទៅអ្នកខាងក្រៅ ។ នេះគឺជាបញ្ហាមួយដែលតែងតែពិបាកសំរាប់យើងក្នុងការព្យាយាមយល់ពីបញ្ហារបស់ស្ត្រី ព្រោះស្ត្រីគឺជាមនុស្សម្នាក់គត់ដែលជាអ្នកទទួលរងនូវការឈឺចាប់ពីអំពើហិង្សាទាំងនេះ តែនាងមិននិយាយចេញមក ។ នៅពេលដែលមានមនុស្សម្នាក់មកពីខាងក្រៅសាកសួរពតមានពីស្ត្រីទាំងនោះ គេនឹងមិនបានទទួលពតិមានពិត ស្តីពីស្ថានភាពនៃជីវិតស្ត្រីឡើយ ។

**តារាង ៣.៣-ប្រសិនបើអ្នកមានបញ្ហា, តើបញ្ហាអ្វីខ្លះ?**

| ប្រភេទនៃបញ្ហា | ប្រេកង់ | ភាគរយ | ភាគរយបូកបន្ថែម |
|---|---|---|---|
| ប្តីអត់ការងារធ្វើ | ៣ | ៥០ | ៥០ |
| អំពើហិង្សាក្នុងគ្រួសារ, ប្តីស្រវឹង និង គ្មានការងារធ្វើ | ៣ | ៥០ | ១០០ |
| **សរុប** | **៦** | **១០០** | |

រាជរដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាលជាច្រើន បាននិងកំពុងតែធ្វើការងារផ្តោតទៅលើបញ្ហាអំពើហិង្សាប្រឆាំងស្ត្រីនិងកុមារ ជាពិសេសគឺអំពើហិង្សាក្នុងគ្រួសារ ។ ប៉ុន្តែនៅតែមានករណីអំពើហឹង្សាជាច្រើនកើតឡើង ក្នុងនោះក៏រាប់បញ្ចូលទាំងអំពើហឹង្សាដែលកើតឡើងនៅក្នុងគ្រួសារអ្នកសុំទានផងដែរ ។ ករណីសិក្សាខាងក្រោមនេះគឺជាតឹកតាងបង្ហាញពីអំពើហិង្សាក្នុងគ្រួសារដែលកើតឡើងនៅក្នុងគ្រួសារអ្នកសុំទាន ។

កាលពីមុន ខ្ញុំមានដីស្រែប៉ុន្តែប្តីរបស់ខ្ញុំបានលក់ដីនោះ ដើម្បីយកលុយមករៀបចំពិធីមង្គលការរបស់គាត់ជាមួយប្រពន្ធថ្មីរបស់គាត់ ។ គាត់បានវាយក្បាលខ្ញុំនឹងចាន ហើយខ្ញុំបានទៅដេកពេទ្យ ។ នៅពេលដែលខ្ញុំនៅក្នុងមន្ទីរពេទ្យ ប្តីរបស់ខ្ញុំបានលក់ដីនោះទៅ ។ ខ្ញុំមិនដឹងថាតើគាត់លក់បានប្រាក់ប៉ុន្មាននោះទេ ។ (ករណីសិក្សាទី ១២)

ខ្ញុំអាយុ ៣៤ឆ្នាំ ប្តីរបស់ខ្ញុំអាយុ ៣០ ឆ្នាំ ។ យើងបានរៀបការជាមួយគ្នា១០ឆ្នាំមកហើយ យើងមានកូនពីរនាក់ ។ កូនប្រុសរបស់យើងមានអាយុ៥ឆ្នាំហើយកូនស្រីរបស់យើងមានអាយុ៦ខែ ។ តាំងពីយើងរៀបការរហូតមកទល់និងពេលនេះ ខ្ញុំគឺជាមនុស្សតែម្នាក់គត់ដែលទទួលខុសត្រូវនៅក្នុងគ្រួសារ ពីព្រោះប្តីរបស់ខ្ញុំគ្មានធ្វើអ្វីទេក្រៅពីផឹកស្រាស្រវឹងហើយវាយដំខ្ញុំនិងកូនៗ ។ យើងរស់នៅ ភូមិជ្រៃ, ឃុំក្រាំងស្វាយ ស្រុកព្រះស្តេច ខេត្តព្រៃវែង ។ (ករណីសិក្សាទី១៩)

អំពើហិង្សានៅក្នុងគ្រួសារគឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ ដែលកំពុងតែកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ននេះនៅក្នុងគ្រួសារគ្រប់ស្រទាប់វណ្ណៈ ។ មនុស្សខ្លះនិយាយថាមូលហេតុដែលធ្វើឱ្យមានអំពើហឹង្សាក្នុងគ្រួសារកើតឡើង គឺដោយសារប្តីប្រពន្ធទាំងពីរនាក់នោះក្រ មិនចេះអក្សរ តែចំលើយទាំងនេះគឺមិនពិតឡើយ ។ អំពើហិង្សាក្នុងគ្រួសារ គឺជាទង្វើមួយនៃទំនាក់ទំនងអំណាចការត្រួតត្រាទៅលើអ្នកដទៃទៀត ។ នៅក្នុងប្រទេសកម្ពុជាក៏ដូចជាប្រទេសដទៃទៀតនៅលើពិភពលោកយើងនេះដែរ ករណីហិង្សាជាច្រើនគឺបុរសជាអ្នកប្រព្រឹត្ត ព្រោះបុរសគិតថាគេគឺជាម្ចាស់លើអ្វីៗគ្រប់បែបយ៉ាង ហើយគេត្រូវតែមានអំណាចលើមនុស្សគ្រប់គ្នានៅក្នុងគ្រួសារ ។ ករណីខាងក្រោមនេះ ប្តីរបស់នាងបានប្រើអំពើហិង្សាមកលើរូបនាង ព្រោះគាត់ចង់លក់ដីស្រែប៉ុន្តែប្រពន្ធមិនព្រម ។ នាងយល់ថាប្រសិនបើលក់ដីស្រែ តើគ្រួសាររស់នៅយ៉ាងដូចម្តេច?

**តារាង៣.៤-បញ្ហាដែលអ្នកសុំទានជាស្ត្រីមេម៉ាយជួបប្រទះ**

| ប្រភេទនៃបញ្ហា | ប្រេកង់ | ភាគរយ | ភាគរយបូកបន្ថែម |
|---|---|---|---|
| ធ្វើស្រែមិនកើតព្រោះភាពរាំងស្ងួត | ៤ | ២៦.៧ | ២៦.៧ |
| ខ្ញុំចិញ្ចឹមកូនច្រើនហើយផ្គត់ផ្គង់ពួកគេឱ្យរៀនសូត្រ | ២ | ១៣.៣ | ៤០ |
| ខ្ញុំមានជីវិតចតួចហើយស្រូវហូបមិនគ្រប់ | ២ | ១៣.៣ | ៥៣.៣ |
| គ្មានលទ្ធភាពបញ្ជូនកូនទៅសាលារៀន | ១ | ៦.៧ | ៦០ |
| គ្មានដីនិងត្រូវចិញ្ចឹមកូន៥នាក់ | ១ | ៦.៧ | ៦៦.៧ |
| គ្មានដីនិងត្រូវចិញ្ចឹមចៅជាច្រើននាក់ | ១ | ៦.៧ | ៧៣.៣ |

| | | | |
|---|---|---|---|
| គ្មានដី, ត្រូវការចិញ្ចឹមកូន | ១ | ៦.៧ | ៨០ |
| ជួលដីស្រែនិងត្រូវការបញ្ជូនកូនឱ្យទៅសាលារៀន | ១ | ៦.៧ | ៨៦.៧ |
| ខ្ញុំមានផ្ទុកមេរោគអេដស៍ដូច្នេះកូនស្រីខ្ញុំក៏ឆ្លងដែរ | ១ | ៦.៧ | ៩៣.៣ |
| កូនៗនៅផ្ទះអត់បាយគ្មាននរណាមើលថែទាំ | ១ | ៦.៧ | ១០០ |
| សរុប | **១៥*** | **១០០** | |

*ករណីបាត់ទិន្នន័យ = ២

អ្នកសុំទានខ្លះបានឆ្លើយតបថា ការរស់នៅម្នាក់ឯងគឺវាពិបាកខ្លាំងណាស់ព្រោះគាត់គ្មានប្ដីនៅជួយសំរាលបន្ទុកគ្រួសារគាត់ ។ ដោយគ្មានការជួយទំនុកបំរុងពីប្ដីគាត់ប្រហែលជានឹងគ្មានលទ្ធភាពបញ្ជូនកូនឱ្យទៅសាលារៀនទេ ព្រោះគ្មាននរណានៅជួយរកប្រាក់ចំណូលដើម្បីយកមកចិញ្ចឹមគ្រួសារ ។ វាក៏ពិបាកក្នុងការធ្វើស្រែដែរព្រោះស្ត្រីមានកូនតូចៗគឺមិនមានកំលាំងពលកម្មគ្រប់គ្រាន់ដើម្បីធ្វើការងារទេ ។ ប៉ុន្តែពួកគាត់នៅតែព្យាយាមរកលុយ ដើម្បីឱ្យកូនឬចៅរបស់ពួកគាត់មានលទ្ធភាពបានទៅសាលារៀន ។ ពួកគាត់សង្ឃឹមថា ក្មេងៗជំនាន់ក្រោយនិងជៀសផុតពីគ្រោះអវិជ្ជា ។ តាមរយៈការសម្ភាសន៍ យើងសង្កេតឃើញថា អ្នកសុំទានភាគច្រើនបានប្រាប់យើងថា ពួកគាត់មិនចេះអក្សរហើយពួកគាត់មិនចង់ឱ្យកូនឬចៅរបស់គាត់ក្លាយទៅជាមនុស្សមិនចេះអក្សរដូចគាត់ឡើយ ។

ប៉ុន្តែនៅក្នុងករណីខ្លះ យើងសង្កេតឃើញថាស្ថានភាពរបស់ស្ត្រីមួយចំនួនដែលរៀបការគឺវាពិបាកជាងអ្នកដែលរស់នៅម្នាក់ឯង(មេម៉ាយ)ទៅទៀត ព្រោះក្រៅពីការទទួលខុសត្រូវទាំងឡាយនៅក្នុងគ្រួសារ គឺគាត់នៅបានទទួលរងនូវអំពើហិង្សាពីប្ដីរបស់គាត់ថែមទៀត ។ គ្រោះមហន្តរាយធម្មជាតិ ជាពិសេសទឹកជំនន់ និងភាពរាំងស្ងួតកាលពីប៉ុន្មានឆ្នាំមុន បានជះឥទ្ធិពលទៅលើជីវភាពរស់នៅរបស់គ្រួសារជាច្រើននៅតាមជនបទមិនថាគ្រួសារស្ត្រីមេម៉ាយដែលដើរសុំទានទេ ។ ពួកគាត់ទាំងអស់ប្រឈមមុខទៅនិងគ្រោះអត់ឃ្លាន ហើយពួកគាត់ត្រូវការទៅខ្ចីលុយគេដើម្បីដោះស្រាយនូវស្ថានភាពរបស់ពួកគាត់ ។ បច្ចុប្បន្ននេះ សេវាកម្មផ្នែកថែទាំសុខភាពនិងការអប់រំត្រូវបានគេដាក់ឱ្យក្លាយទៅជារបស់ឯកជន ហើយកុមារដែលមកពីគ្រួសារក្រីក្រមិនអាចរៀនសូត្របានជ្រៅជ្រះទេ ប្រសិនបើពួកគេគ្មានលុយសំរាប់បង់ថ្លៃសាលានោះ ។ វាកាន់តែពិបាកទៅទៀតសំរាប់ក្មេងទាំងអស់ ទោះបីជាពួកគេមកពីគ្រួសារដែលបុរសជាមេគ្រួសារឬស្ត្រីជាមេគ្រួសារក៏ដោយក៏មានការពិបាកក្នុងការទទួលបានការអប់រំណាស់ នៅក្នុងស្ថានភាពនាពេលបច្ចុប្បន្ន ដែលពួកគេត្រូវជួយធ្វើការរកលុយដើម្បីចិញ្ចឹមខ្លួននិងគ្រួសារមុននឹងគិតគូរពីការសិក្សា ។

## ៤. ការងារផ្សេងទៀតដែលកសិករយើងធ្វើ

**តារាងទី ៤-តើមានមុខរបរផ្សេងក្រៅពីធ្វើស្រែ ដែលកសិករអាចធ្វើបានដែរឬទេ?**

| ប្រភេទនៃការងារ | ប្រេកង់ | ភាគរយ | ភាគរយបូកបន្ថែម |
|---|---|---|---|
| ស៊ីឈ្នួលស្ទូង | ៧ | ២៣,៣ | ២៣,៣ |
| ទេ | ១៨ | ៦០ | ៨៣,៣ |
| ចិញ្ចឹមសត្វពាហនៈ | ២ | ៦,៧ | ៩០ |
| លក់ដូរ | ៣ | ១០ | ១០០ |
| **សរុប** | **៣០** | **១០០** | |

ជីវិតរបស់ប្រជាជននៅតាមជនបទ គឺពឹងផ្អែកទាំងស្រុងទៅលើការចិញ្ចឹមជីវិតតាមបែបយថាកម្ម (តាមត្រឹមតែមួយរស់) ។ នៅរដូវធ្វើស្រែ ពួកគេអាចលក់កំលាំងពលកម្មដោយធ្វើការក្នុងវាលស្រែឱ្យអ្នកភូមិដទៃទៀតដើម្បីទទួលបានប្រាក់កំរៃ ។ ប្រសិនបើពួកគេស៊ីឈ្នួលស្ទូងឬច្រូតកាត់ ក្នុងមួយថ្ងៃពួកគាត់ទទួលបាន ២,៥០០-៣,០០០រៀល និងអាហារពីរពេល ។ ប៉ុន្តែក្រោយពីរដូវធ្វើស្រែ ពួកគេគ្មានការងារធ្វើទេ ពួកគេត្រូវចាកចេញពីភូមិដើម្បីស្វែងរកការងារផ្សេងទៀតធ្វើ ។

## ៥- ស្ថានភាពដីស្រែ

**តារាងទី ៥.១ តើអ្នកមានដីទេ សព្វថ្ងៃនេះ?**

| មានដី | ប្រេកង់ | ភាគរយ | ភាគរយបូកបន្ថែម |
|---|---|---|---|
| មាន | ១៣ | ៥០ | ៥០ |
| មានតែបញ្ចាំគេ | ៩ | ៣៤,៦ | ៨៤,៦ |
| គ្មាន | ៤ | ១៥,៤ | ១០០ |
| **សរុប** | **២៦*** | **១០០** | |

*ករណីបាត់ពត៌មាន = ៤

**តារាងទី៥.២ តើអ្នកធ្លាប់លក់ដីស្រែទេ?**

| លក់ដីស្រែ | ប្រេកង់ | ភាគរយ | ភាគរយបូកបន្ថែម |
|---|---|---|---|
| បាទ | ៥ | ១៧,៩ | ១៧,៩ |
| ទេ | ២៣ | ៨២,១ | ១០០ |
| **សរុប** | **២៨*** | **១០០** | |

*ករណីបាត់ពត៌មាន = ២

ប្រជាជននៅតាមទីជនបទ គឺរស់នៅពឹងផ្អែកទៅលើការងារកសិកម្មប្រពលវប្បកម្ម គឺពួកគាត់ធ្វើស្រែនៅ រដូវវស្សា ។ នេះមានន័យថាដីគឺជាទ្រព្យសម្បត្តិដ៏មានន័យបំផុតសំរាប់ពួកគាត់ ប្រសិនបើពួកគាត់សំរេចចិត្តលក់ដីស្រែ ឬបញ្ចាំដីនោះមានន័យថាវាគឺជាជំរើសចុងក្រោយដែលពួកគាត់បានជ្រើសរើសដើម្បីចិញ្ចឹមជីវិត។ មានការសិក្សាស្រាវជ្រាវជាច្រើនដែលបានធ្វើឡើងដោយកម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ-អុកស្វាមហុងកុង ក្នុងនោះយើងបានជួបសំណេះសំណាលជាមួយកសិករជាច្រើន យើងអាចមើលឃើញថាប្រជាជនដែលរស់នៅតាមជនបទគឺបានបាត់បង់ដី ដោយសារតែពួកគាត់ត្រូវការលុយដើម្បីយកមកបង់ថ្លៃសេវាថែទាំសុខភាព សងបំណុលគេ និងដោះស្រាយតំរូវការប្រចាំថ្ងៃរបស់ពួកគេ ។

## ៦. ការទំនាក់ទំនងនៃអំណាច

**តារាងទី ៦-តើនរណាជាអ្នកសំរេចចិត្តលក់ដី?**

| អ្នកណាជាអ្នកសំរេចចិត្ត | ប្រេកង់ | ភាគរយ | ភាគរយបូកបន្ថែម |
|---|---|---|---|
| ប្តីនិងប្រពន្ធ | ២ | ៤០ | ៤០ |
| ប្តីដោយគ្មានការព្រមព្រៀងពីប្រពន្ធ | ២ | ៤០ | ៨០ |
| ខ្ញុំជាអ្នកសំរេចព្រោះប្តីរបស់ខ្ញុំស្លាប់ | ១ | ២០ | ១០០ |
| **សរុប** | **៥** | **១០០** | |

ទំនាក់ទំនងនៃអំណាច គឺជាបញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ជាច្រើននៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងគ្រួសារជាច្រើនផងដែរ ដែលករណីជាច្រើនបុរសជាអ្នកត្រួតត្រាទៅលើគ្រួសារទាំងមូល ទោះបីជាគាត់មិនមែនជាអ្នករកប្រាក់កាសមកផ្គត់ផ្គង់ជីវភាពនៅក្នុងក្រុមគ្រួសារក៏ដោយ ។ គ្រួសារអ្នកសុំទានមួយចំនួនមិន

មានដីស្រែឬផ្ទះសំបែងឡើយ ហើយអ្នកខ្លះបានបញ្ចាំដីនិងអ្នកខ្លះទៀតក៏បានលក់ដីស្រែទៅឱ្យអ្នកចងការប្រាក់ ដើម្បីយកលុយមកដោះស្រាយតំរូវការបន្ទាន់ឬសងបំណុលគេ ។ ទាក់ទងទៅនិងការធ្វើការសំរេចចិត្តស្ត្រីជាច្រើនដែលក្រុមការងារយើងសំភាសន៍ច្រើននិយាយថា ទាំងពីរនាក់ប្តីប្រពន្ធជាអ្នកធ្វើការសំរេចចិត្ត ។ ប៉ុន្តែប្រសិនបើយើងក្រលេកមើលទៅលើករណីនីមួយអំពីទស្សនះយេនឌ័រវិញ យើងអាចមើលឃើញថា វាមិនមានសមភាពរវាងបុរសនិងស្ត្រីនៅក្នុងការធ្វើសេចក្តីសំរេចចិត្តឡើយ ។

យោងទៅលើបទពិសោធន៍នៃការស្រាវជ្រាវជាច្រើនដែលធ្វើជាមួយស្ត្រី នៅពេលដែលនាងត្រូវបានគេសួរថា តើការសំរេចចិត្តនៅក្នុងគ្រួសារយ៉ាងដូចម្តេចដែរ ? នាងបានឆ្លើយថាពួកយើងទាំងពីរនាក់ប្តីប្រពន្ធបានជួយផ្តល់ជាគំនិតយោបល់ឱ្យគ្នាទៅវិញទៅមកមុននិងសំរេចចិត្ត ។ ក្រោយមកនៅពេលដែលគេសួរនាងកាន់តែស៊ីជំរៅទៅៗទាក់ទងទៅនិងការចាយវាយលុយកាក់សូម្បីតែរបស់របរកំប៉ិកកំប៉ុក ចំលើយរបស់នាងឆ្លើយមកនឹងបង្ហាញពីទំនាក់ទំនងនៃអំណាចដែលស្ត្រីមិនមានអំណាចស្មើគ្នានឹងបុរស ក្នុងការសំរេចចិត្តហើយមានតែប្តីម្នាក់គត់ដែលជាអ្នកមានអំណាច ។ បុរសគិតថាអ្វីៗដែលគាត់ធ្វើឬសំរេចចិត្តនោះគឺត្រឹមត្រូវទាំងអស់ ។ ពេលដែលគាត់ចង់បានលុយដើម្បីចំណាយទៅលើរបស់អ្វីមួយ ទោះជាមិនមានការយល់ព្រមពីប្រពន្ធរបស់គាត់ក៏ដោយក៏គាត់ត្រូវតែធ្វើ ។ គាត់មានអំណាចក្នុងការសំរេចចិត្តលក់របស់របរ ហើយនិងអំណាចក្នុងការសំរេចថា តើលុយកាក់នឹងត្រូវចំណាយទៅលើអ្វី ។ ប៉ុន្តែនៅក្នុងគ្រួសារស្ត្រីគឺជាមនុស្សតែម្នាក់ដែលដឹងពីតំរូវការនៅក្នុងផ្ទះទាំងមូល ដូច្នេះប្រសិនបើនាងមិនមានអំណាចក្នុងការសំរេចចិត្តចាយវាយលុយកាក់ទេ ប្រាក់ដែលគេចាយនោះនឹងត្រូវបានគេចាយវាយទៅក្នុងផ្លូវខុស ហើយមិនបានឆ្លើយតបទៅនិងតំរូវការផ្សេងៗឡើយ ។ នៅក្នុងករណីខាងក្រោមនេះបុរសបានប្រើប្រាស់លុយដែលបានមកពីការលក់ដីដើម្បីរៀបការជាមួយប្រពន្ធថ្មី ។

> មូលហេតុដែលនាងខ្ញុំមកទីក្រុងភ្នំពេញនេះ គឺដើម្បីមកដើររើសអេតចាយតែពេលខ្លះនាងខ្ញុំបានដើរសុំទានគេដើម្បីយកលុយមកទិញម្ហូបអាហារទទួលទាន ។ ខ្ញុំបានមកភ្នំពេញនេះអស់រយះពេល២ឆ្នាំមកហើយ គឺមកតាំងពីពេលដែលនាងខ្ញុំនៅជុំនិង ប្តីរបស់នាងខ្ញុំមកម្លេះគឺមកដើម្បីរកលុយយកទៅចិញ្ចឹមប្តីនិងកូន ។ លើកនេះនាងខ្ញុំបានមកស្នាក់នៅភ្នំពេញអស់រយះពេល២ខែមកហើយ ។ សព្វថ្ងៃនេះនាងខ្ញុំគ្មានសេសសល់ដីស្រែគ្មានផ្ទះសម្បែង និងគ្មានអ្វីទាំងអស់។ កាលពីមុនខ្ញុំមានដីស្រែតែក្រោយមកប្តីរបស់ខ្ញុំបានលក់ដីនោះ ដើម្បីយកលុយទៅការប្រពន្ធថ្មីហើយបានប៉ុន្មាននោះខ្ញុំមិនដឹងទេ ។ ថ្ងៃមួយប្តីរបស់នាងខ្ញុំបានយកចានមកវាយខ្ញុំពេលនោះ ខ្ញុំក៏បានទៅមន្ទីរពេទ្យស្រាប់តែក្នុងថ្ងៃនោះ ដែលប្តីរបស់ខ្ញុំក៏បានលួចលក់ដីស្រែទៅឱ្យគេ។ (ករណីសិក្សាទី១២)

ស្ត្រីរងទុក្ខវេទនាជាច្រើននៅក្នុងជីវិតរបស់ខ្លួន នាងគ្មានអំណាចក្នុងការសំរេចចិត្តនៅក្នុងគ្រួសារឡើយ ។ ប្រសិនបើនាងបដិសេធន៍មិនធ្វើតាមនូវអ្វីដែលប្តីនាងចង់ឱ្យធ្វើ នាងនឹងទទួលរងនូវហឹង្សា និងការវាយធ្វើបាបពីសំណាក់ប្តីរបស់នាង ។ បុរសគិតថាគាត់គឺជាអ្នកមានអំណាចលើគេ គេអាចត្រួតត្រាស្ត្រីនិងចាត់ទុកស្ត្រីជាវត្ថុឬរបស់របរដែលគាត់អាចលេងសើចបាន ។ គាត់បានប្រើនូវកំលាំងដើម្បីបង្ហាញពីអំណាចរបស់ខ្លួន ។ លើសពីនេះទៅទៀត ស្ត្រីខ្លួនឯងគិតថានាងគួរតែគោរពប្តីរបស់នាង និងធ្វើតាមនូវរាល់ការសំរេចចិត្តរបស់ប្តីទាំងអស់ព្រោះប្រពៃណី និងទំនៀមទំលាប់ខ្មែរបានបង្រៀននាង ដូចនេះតាំងពីនាងធំដឹងក្តីមក ។

ម្យ៉ាងវិញទៀត ស្ត្រីដែលនៅម្នាក់ឯងគឺតែងតែមានសំណាងជាងស្ត្រីដែលមានប្តីក្នុងការសំរេចចិត្ត ព្រោះនាងគ្មានប្តីនៅត្រួតត្រាលើរូបនាងទៀតទេ ហេតុដូច្នេះនាងគឺជាមនុស្សម្នាក់ដែលជាអ្នកធ្វើការសំរេចចិត្តនៅក្នុងគ្រួសារ។ ប៉ុន្តែសំរាប់ស្ត្រីដែលមានប្តី នាងមិនដែលសំរេចចិត្តធ្វើអ្វីដោយមិនបានសួរយោបល់ប្តីជាមុនឡើយ ។ នាងតែងតែពិភាក្សាជាមួយប្តីនាងហើយប្រសិនបើប្តីរបស់នាងបដិសេធន៍ នាងប្រាកដជាមិនធ្វើវាទេ ។ នេះបង្ហាញអោយឃើញថា ស្ត្រីគ្មានសិទ្ធិក្នុងការធ្វើសេចក្តីសំរេចចិត្តម្នាក់ឯងទេ នៅពេលដែលនាងចង់លក់ដីបញ្ចាំដី ខ្ចីលុយគេ មកសុំទាននៅទីក្រុង ទិញរបស់របរតូចតាចដែលជាតំរូវការចាំបាច់នៅក្នុងគ្រួសារ ឬធ្វើអ្វីផ្សេងទៀតនោះ នាងត្រូវតែពិភាក្សាជាមួយប្តីនាង ។

ដូច្នេះ ប្រសិនបើការសិក្សាស្រាវជ្រាវចង់ធ្វើការពិនិត្យមើលទៅលើទំនាក់ទំនងអំណាចនៅក្នុងគ្រួសារនៃប្រជាជនកម្ពុជានោះ អ្នកស្រាវជ្រាវត្រូវតែប៉ិនប្រសប់ក្នុងការសួរសំនួរដើម្បីទទួលបាននូវចំលើយល្អ ដែលទាក់ទងទៅនិងស្ថានភាពពិតរបស់ស្ត្រី ។ ប្រសិនបើអ្នកសួរសំនួរត្រង់ៗពេកហើយយកនូវគំនិតយោបល់ឬចំលើយទាំងនោះទៅប្រើធ្វើជាពតិមានដែលមានប្រយោជន៍នៅក្នុងលទ្ធផលនៃការស្រាវជ្រាវនោះ វានឹងមិនបង្ហាញពីស្ថានភាពជាក់ស្តែងនៅក្នុងជីវិតរបស់ស្ត្រីឡើយ ។

# ៧. ការជំពាក់បំណុល

**តារាងទី ៧.១-តើអ្នកមានជំពាក់បំណុលគេទេមុនពេលមកភ្នំពេញ?**

| ស្ថានភាពបំណុល | ប្រេកង់ | ភាគរយ | ភាគរយបូកបន្ថែម |
|---|---|---|---|
| ជំពាក់ | ២០ | ៧១.៤ | ៧១.៤ |
| មិនជំពាក់ | ៨ | ២៨.៦ | ១០០ |

| | | | |
|---|---|---|---|
| សរុប | **២៨*** | **១០០** | |

*ករណីបាត់ពតិមាន= ២

អ្នកសុំទានភាគច្រើនបានឆ្លើយតបថា ពួកគាត់បានធ្លាក់ខ្លួនជំពាក់បំណុលគេដោយសារពួកគាត់បានខ្ចីលុយពីអ្នកចងការប្រាក់ ឬអង្គការក្រៅរដ្ឋាភិបាលមួយចំនួនដែលមានកម្មវិធីឥណទាននៅក្នុងភូមិរបស់ពួកគាត់ ។ ប្រាក់ដែលពួកគាត់បានខ្ចីគឺពួកគាត់បានប្រើដើម្បីព្យាបាលជំងឺសមាជិកនៅក្នុងគ្រួសាររបស់គាត់ ជាពិសេសប្ដី ហើយនិងកូន ប៉ុន្តែមិនមែនខ្លួនគាត់ទេ ។ តាំងពីសេវាសុខភាពបានដាក់ទៅជារបស់ឯកជនមក អ្នកក្រមិនអាចទទួលបាននូវសេវាទាំងនោះឡើយ ។ ដូច្នេះ នៅពេលដែលសមាជិកក្នុងគ្រួសាររបស់គាត់ឈឺ គាត់ត្រូវតែបញ្ជូនពួកគេទៅព្យាបាលនៅគ្លីនិកឯកជនដែលត្រូវការលុយច្រើនសំរាប់ព្យាបាល ។

លើសពីនេះទៅទៀត ប្រាក់ដែលគាត់បានខ្ចីមិនត្រឹមតែប្រើសំរាប់ព្យាបាលជំងឺមួយមុខទេតែភាគច្រើនគឺពួកគាត់ចំណាយទៅលើតំរូវការចាំបាច់នៅក្នុងគ្រួសារ ដូច្នេះ តើពួកគាត់អាចរកប្រាក់មកសងបំណុលគេវិញ រឺបង់ថ្លៃការប្រាក់ជារៀងរាល់ខែយ៉ាងដូចម្ដេច ព្រោះប្រាក់ដែលគាត់បានខ្ចីមកនោះគឺគាត់ប្រើដើម្បីចិញ្ចឹមត្រឹមតែរស់និងបង់ថ្លៃថ្នាំព្យាបាលជំងឺហើយម្យ៉ាងវិញទៀតនៅស្រុកស្រែគ្មានការងារអ្វីសំរាប់អោយពួកគាត់ធ្វើឡើយក្រៅពីប្រកបរបរធ្វើស្រែ ។ បំណុលរបស់គាត់កាន់តែច្រើនឡើងៗ នៅពេលដែលពួកគាត់គ្មានលុយបង់ថ្លៃការប្រាក់អោយម្ចាស់បំណុល ។ ក្រុមគ្រួសារអ្នកនៅតាមជនបទភាគច្រើនគឺជំពាក់បំណុលគេ ហើយស្ត្រីគឺជាមនុស្សម្នាក់ដែលទទួលខុសត្រូវក្នុងការបំពេញសេចក្ដីគ្រួសាររបស់នាង ហើយនាងក៏ជាធនធានដ៏សំខាន់ផងដែរនៅក្នុងគ្រួសារទាំងមូល ។

### តារាងទី ៧.២-តើអត្រាការប្រាក់ប៉ុន្មានគិតជា%?

| អត្រាការប្រាក់គិតជា % | ប្រេកង់ | ភាគរយ | ភាគរយបូកបន្ថែម |
|---|---|---|---|
| ៤ | ១៤ | ៤៦.៧ | ៤៦.៧ |
| ២០ | ១២ | ៤០ | ៨៦.៧ |
| ៣០ | ៤ | ១៣.៣ | ១០០ |
| **សរុប** | **៣០** | **១០០** | |

ប្រសិនបើពួកគាត់ខ្ចីប្រាក់ពីអ្នកឱ្យលុយខ្ចីនៅក្នុងភូមិ ក្នុងមួយខែគាត់ត្រូវបង់ការប្រាក់ពី២០-៣០%ក្នុងមួយខែ ប៉ុន្តែប្រសិនបើខ្ចីពីអង្គការក្រៅរដ្ឋាភិបាលក្នុងមួយខែត្រូវបង់ការប្រាក់ពី ៤-៥% ។ តើលោកអ្នកអាច ធ្វើការស្រមើស្រមៃពីប្រាក់កម្ចីដែលប្រជាជនយើងខ្ចីពីអ្នកចងការប្រាក់ក្នុងអាត្រាការប្រាក់ខ្ពស់ដែរឬទេ ? ក្នុងរយៈពេលបីខែ អត្រាការប្រាក់នឹងឡើងស្មើនិងប្រាក់កម្ចី ។ តើអ្នកក្រអាចគេចផុតពីវដ្តនៃការជំពាក់បំណុលគេនោះបានយ៉ាងដូចម្តេច? ពួកគាត់នឹងគ្មានថ្ងៃសងបំណុលគេរួចបានឡើយ ។

សំរាប់អ្នកដែលបានខ្ចីលុយពីអង្គការក្រៅរដ្ឋាភិបាល ពួកគាត់ត្រូវតែបង់ការប្រាក់ជារៀងរាល់ខែនិងដល់ពេលកំណត់មួយ (តាមអង្គការនីមួយៗ) បុគ្គលិកអង្គការនិងចុះមកប្រមូលយកប្រាកកម្ចីវិញ នៅពេលដែលពួកគាត់គ្មានលុយសងគេវិញ ពួកគាត់ក៏បានទៅខ្ចីលុយពីអ្នកចងការប្រាក់ឯកជនដែលនៅក្នុងភូមិរបស់គាត់ឬលក់ដី លក់ស្រែ ឬបញ្ចាំដីស្រែដើម្បីយកលុយមកសងគេ ប៉ុន្តែទោះបីជាគាត់ខំលក់អស់ដីស្រែយ៉ាងណាក៏ដោយក៏វានៅតែសងគេមិនគ្រប់ដដែល ។ ខាងក្រោមនេះគឺជាកណីសិក្សាស្តីពីអ្នកសុំទានម្នាក់ដែលគាត់បានលក់អ្វីៗគ្រប់យ៉ាង ដើម្បីយកលុយមកសងបំណុលគេក៏ប៉ុន្តែគាត់នៅតែជំពាក់បំណុលគេ ។ ប្រជាជននៅតាមជនបទភាគច្រើនរស់នៅពឹងផ្អែកទៅលើមុខរបរធ្វើស្រែចំការ ប៉ុន្តែនៅពេលដែលដីស្រែរបស់គាត់ត្រូវរឹបអូសដោយអង្គការ ឬម្ចាស់បំណុលរឹបអូសយកដើម្បីលួសបំណុលដែលពួកគាត់បានជំពាក់គេហើយនោះ តើពួកគាត់អាចទ្រទ្រង់ជីវិតគាត់អោយរស់នៅបានយ៉ាងដូចម្តេចទៅ ?

> ពីមួយថ្ងៃទៅមួយថ្ងៃយើងរស់នៅលក្ខខណ្ឌដ៏សែនលំបាកដូច្នេះខ្ញុំក៏បានសំរេចចិត្តបញ្ចាំដីស្រែរបស់ខ្ញុំ ដែលមានទំហំ២០អាទៅឱ្យអង្គការគណៈកម្មការសុខភាពប្រជាជនកម្ពុជា ក្នុងទឹកប្រាក់ចំនួន៥០០០០០រៀលដោយក្នុងមួយខែខ្ញុំត្រូវបង់ថ្លៃការប្រាក់ចំនួន២០០០០រៀល (ការប្រាក់៤%) ។ ប៉ុន្តែជារៀងរាល់ខែខ្ញុំគ្មានលទ្ធភាពរកលុយដើម្បីបង់ការប្រាក់នេះឡើយខ្ញុំក៏បានទៅខ្ចីមាសពាក់ជីពីអ្នកចងការប្រាក់ដែលរស់នៅក្នុងភូមិនេះដោយក្នុងមួយខែៗខ្ញុំត្រូវបង់១០០០០រៀល ថ្លៃការប្រាក់ (ក្នុង១០០០០គេយកការប្រាក់២០០០រៀលក្នុងមួយខែ) ។ បំណុលរបស់ខ្ញុំកាន់តែច្រើនឡើងៗប៉ុន្តែខ្ញុំមិនអាចរកប្រាក់បានគ្រប់គ្រាន់ដើម្បីមកដោះបំណុលបានឡើយ ដូច្នេះខ្ញុំក៏សំរេចចិត្តលក់ដីលក់គោក្របីដើម្បីយកលុយមកសងបំណុលគេតែប្រាក់ដែលខ្ញុំប្រមូលបានពីការលក់របស់របរទាំងអស់នោះនៅតែសងគេមិនគ្រប់ទៀត ។សព្វថ្ងៃនេះខ្ញុំនៅតែជំពាក់លុយគណៈកម្មការសុខភាពគ្រួសារប្រជាជនកម្ពុជាចំនួន២០ម៉ឺនរៀលទៀត ។ មុនពេលដែលខ្ញុំបានចាកចេញមកសុំទាននៅទីក្រុង ខ្ញុំបានខ្ចីលុយ ១៥០០០រៀល ពីអ្នកជិតខាងសំរាប់ធ្វើសាហ៊ុយមកដោយក្នុងមួយម៉ឺនរៀលគេយកការប្រាក់៣០០០រៀល/ខែ តែពេលខ្ញុំត្រលប់ទៅផ្ទះវិញទើបគេយក ។ (ករណីសិក្សាទី១)

## តារាងទី៨-នៅពេលដែលអ្នករស់នៅក្នុងទីក្រុងភ្នំពេញ តើអ្នកជួបប្រទះបញ្ហាអ្វីខ្លះ?

| ប្រភេទនៃបញ្ហា | ហ្វ្រេកង់ | ភាគរយ | ភាគរយបូកបន្ថែម |
|---|---|---|---|
| ខ្ញុំបានចាញ់បោកបុរសម្នាក់ហើយវាបានយកលុយពីខ្ញុំ | ២ | ៧.៤ | ៧.៤ |
| ខ្ញុំមានការភ័យខ្លាចហើយខ្ញុំមិនស្គាល់ទីតាំងច្បាស់លាស់ | ៩ | ៣៣.៣ | ៤០.៧ |
| របស់របរនៅទីនេះថ្លៃខ្លាំងណាស់ | ១០ | ៣៧ | ៧៧.៨ |
| ខ្លាចពួកជើងកាងចាប់រំលោភ | ១ | ៣.៧ | ៨១.៥ |
| ផ្ទះរបស់ខ្ញុំឆេះអស់ហើយឥលូវគ្មានផ្ទះនៅ | ៣ | ១១.១ | ៩២.៦ |
| ពួកជើងកាងលួចលុយខ្ញុំ | ១ | ៣.៧ | ៩៦.៣ |
| ខ្ញុំការរស់នៅរបស់ពួកយើងនៅភ្នំពេញគឺពឹងផ្អែកទៅលើកូនតូចៗ | ១ | ៣.៧ | ១០០ |
| **សរុប** | **២៧*** | **១០០** | |

*ករណីបាត់ពតិមាន= ៣

អ្នកសុំទានភាគច្រើនគ្មានសាច់ញាតិបងប្អូននៅភ្នំពេញទេ ។ អ្នកសុំទានដែលទើបតែមកថ្មីដែលយើងបានសំភាសន៍បាននិយាយថា ពួកគាត់មិនស្គាល់ទីកន្លែងដែលអាចអោយពួកគាត់ស្នាក់នៅពេលយប់ទេព្រោះពួកគាត់ទើបតែមកពីជនបទនិងជាពិសេសពួកគាត់មិនស្គាល់ច្បាស់ពីទីតាំងភូមិសាស្ត្រឬស្ថានភាពនៅទីក្រុងច្បាស់លាស់ទេ ។ ស្ត្រីចំណាស់ម្នាក់បានប្រាប់យើងថា គាត់ហើយនិងប្អូនស្រីរបស់គាត់រួមជាមួយនិងអ្នកសុំទានដទៃទៀតត្រូវបានបុរសម្នាក់បោក ហើយពួកគាត់ក៏បានបាត់បង់លុយកាក់អស់ច្រើនណាស់ ។

> ក្នុងមួយថ្ងៃ ខ្ញុំអាចរកប្រាក់បានពី ១,០០០-១,៥០០រៀលដូចដែលខ្ញុំគ្មានបទពិសោធន៍ក្នុងការដើរសុំទានទេ ។ នៅថ្ងៃទីពីរដែលយើងមកដល់ទីក្រុង ខ្ញុំនិងអ្នកភូមិពីរនាក់ទៀតបានចាញ់បោកបុរសម្នាក់ដែលមានអាយុ៣០ឆ្នាំ ។ យើងបានជួបគាត់នៅមាត់ទន្លេ នៅខណៈពេលដែលយើងកំពុងតែសុំទាន គាត់បានអញ្ជើញពួកយើងឱ្យទៅវត្តភ្នំដើម្បីទៅទទួលអង្ករ និង លុយចំនួន ៣០០,០០០រៀល ពីសាច់ញាតិរបស់គាត់ម្នាក់ដែលទើបតែមកពីសហរដ្ឋអាមេរិច។ នៅពេលដែលយើងទៅដល់វត្តភ្នំ គាត់បានសួរយើងថា តើយើងមានលុយសំរាប់ទិញ សំបុត្រទៅយកអំនោយទាំងនោះឬទេហើយយើងទាំងបីនាក់បានប្រមូលលុយបាន៤០,០០០រៀលឱ្យទៅគាត់ហើយបន្ទាប់មកគាត់បានប្រាប់យើងឱ្យនៅចាំហើយគាត់ទៅទិញសំបុត្រក៏ប៉ុន្តែយើងបានចាំគាត់យ៉ាងយូរ តែមិនឃើញគាត់ត្រលប់មកវិញឡើយ ។ (ករណីសិក្សាទី១៧)

ពួកគាត់ក៏បានសំដែងការព្រួយបារម្ភណ៍ពីការរស់នៅរបស់គាត់ក្នុងទីក្រុងផងដែរ ពួកគាត់ខ្លាចពួកជើងកាងចាប់រំលោភ និងខ្លាចចោរលួចលុយគាត់នៅពេលដែលគាត់កំពុងតែដេកលក់ ព្រោះកន្លងមកគាត់ធ្លាប់មានបទពិសោធន៍ដោយមានពួកជើងកាងច្រើននាក់បានបន្ទំខ្លួនចូលដេកជិតគាត់ ហើយបានយកដៃលូកហោប៉ៅរបស់គាត់ ។ អ្នកសុំទានផ្សេងទៀតក៏បានបញ្ជាក់ដែរថា ពួកគាត់គឺជាអ្នកមកថ្មីមិនអាចរកលុយបានច្រើនដើម្បីចំណាយទៅលើការចាយវាយចាំបាច់ឡើយព្រោះរបស់របរនៅក្នុងទីក្រុងថ្លៃណាស់ ។

> ជារៀងរាល់យប់ខ្ញុំស្នាក់នៅជិតផ្សារថ្មីជាមួយអ្នកសុំទានដ៏ទៃទៀត។ ជួនកាលមនពួកជើងកាងបានមកបន្ទំខ្លួនចូលដេកជិតខ្ញុំ ពួកវាបានលូកដៃចូលក្នុងហោប៉ៅរបស់ខ្ញុំ ដើម្បីរកលុយហើយមានយប់មួយនោះមួយ ក្នុងខណៈពេលដែលខ្ញុំកំពុងតែដេកលក់ស្រាប់តែមានគេមកលួចយកលុយរបស់ខ្ញុំអស់៥០០០រៀល។ (ករណីសិក្សាទី៣)

## ៩- ចំណូលនិងចំណាយ

**តារាងទី៩.១-ក្នុងមួយថ្ងៃតើអ្នកសុំបានប៉ុន្មាន-រៀល?**

| ចំណូលប្រចាំថ្ងៃ-រៀល | ប្រេកង់ | ភាគរយ | ភាគរយបូកបន្ថែម |
|---|---|---|---|
| តិចជាង ៥០០ | ៤ | ១៣.៨ | ១៣.៨ |
| ៥០០ | ១ | ៣.៤ | ១៧.២ |
| ១,០០០ | ១ | ៣.៤ | ២០.៦ |
| ១,០០០-១,៥០០ | ៩ | ៣១ | ៥១.៦ |
| ១,៥០០-២,០០០ | ៣ | ១០.៣ | ៦១.៩ |
| ៨០០-៣,០០០ | ១ | ៣.៤ | ៦៥.៣ |
| ២,០០០-៣,០០០ | ៧ | ២៤.១ | ៨៩.៤ |
| ៣,០០០-៤,០០០ | ១ | ៣.៤ | ៩២.៨ |
| មិនទាន់បានដើរសុំទេ | ២ | ៦.៩ | |
| **សរុប** | **២៩*** | **១០០** | |

*ករណីបាត់ពត៌មាន=១

**បន្ទាត់ទី៩.២- តើក្នុងមួយថ្ងៃអ្នកចំណាយទៅលើម្ហូបអាហារអស់ប៉ុន្មាន?**

| លុយចំណាយលើបម្ហូប | ប្រេកង់ | ភាគរយ | ភាគរយបូកបន្ថែម |
|---|---|---|---|
| ៣០០ | ១ | ៤ | ៤ |
| ៥០០ | ៦ | ២៤ | ២៨ |
| ៧០០ | ២ | ៨ | ៣៦ |
| ៥០០-១០០០ | ២ | ៨ | ៤៤ |
| ១០០០ | ៩ | ៣៦ | ៨០ |
| ១៥០០ | ៤ | ១៦ | ៩៦ |
| ម្សិរ តហាន ២០០០ | ១ | ៤ | ១០០ |
| សរុប | **២៥*** | **១០០** | |

*ករណីបាត់ពតិមាន= ៥

ចំនួនទឹកប្រាក់ជាមធ្យមដែលអ្នកសុំទានអាចរកបានក្នុងមួយថ្ងៃគឺពី ១,០០០-១,៥០០រៀល ប៉ុន្តែពួកគាត់ចំណាយ១,០០០រៀលទៅលើម្ហូបអាហារ ។ ប្រាក់ដែលពួកគាត់រកបាននោះគឺស្ទើរតែមិនគ្រប់ទិញម្ហូបអាហារព្រោះទឹកប្រាក់ចំនួនប៉ុណ្ណឹងមិនអាចផ្តល់អាហារល្អៗឱ្យគាត់ហូបបានឡើយ ប៉ុន្តែអាចឱ្យពួកគាត់រស់បានតែមួយថ្ងៃទៅមួយថ្ងៃប៉ុណ្ណោះ ។ ប្រសិនបើថ្ងៃមួយគាត់ធ្លាក់ខ្លួនឈឺ តើគាត់អាចរកលុយមកព្យាបាលខ្លួនយ៉ាងដូចម្តេចទៅ ? ពួកគាត់នឹងស្លាប់ព្រោះគាត់គ្មានប្រាក់គ្រប់គ្រាន់ដើម្បីបង់ថ្លៃសេវាកម្មឯកជនផ្នែកសុខភាពនៅក្នុងទីក្រុងព្រោះវាថ្លៃណាស់ ។ ហើយម្យ៉ាងវិញទៀត ពួកគាត់បានចាកចេញពីផ្ទះមករកការងារធ្វើដើម្បីរកប្រាក់ចំណូលទៅផ្គត់ផ្គង់គ្រួសាររបស់ពួកគាត់ និងដើម្បីធ្វើឱ្យគាត់បានរួចផុតពីការជំពាក់បំណុលគេផងដែរ ។ ប៉ុន្តែជាមួយនឹងប្រាក់ដែលគាត់រកបានជារៀងរាល់ថ្ងៃ វាអាចជួយគាត់ត្រឹមតែបង់ថ្លៃការប្រាក់គេតែប៉ុណ្ណោះមិនមែនសងដើមគេទេ តើសមាជិកនៅក្នុងគ្រួសារវិញយ៉ាងម៉េចដែរ ? តើការអប់រំរបស់កូន ម្ហូបអាហារនិងការថែទាំសុខភាពយ៉ាងដូចម្តេច? ប្រសិនបើគាត់ចង់ធ្វើអ្វីមួយគាត់ត្រូវតែចំណាយលុយ ។ ឧទាហរណ៍ប្រសិនបើគាត់ចង់ផ្ញើរលុយទៅផ្ទះគាត់ត្រូវតែយកទៅដោយខ្លួនឯង ជួនកាលចំនួនទឹកប្រាក់ដែលគាត់ផ្ញើរទៅផ្ទះគឺពាក់កណ្តាលនៃប្រាក់នោះគាត់បានចំណាយទៅលើថ្លៃធ្វើដំណើរ ។

## ១០. ស្ថានភាពកូន

### បន្ទាត់ទី១០.១-តើអ្នកយកកូនមកជាមួយទេ?

| យកកូនមកជាមួយ | ប្រេកង់ | ភាគរយ | ភាគរយបូកបន្ថែម |
|---|---|---|---|
| ចាស | ១៤ | ៤៦,៧ | ៤៦,៧ |
| ទេ | ១៦ | ៥៣,៣ | ១០០ |
| **សរុប** | **៣០** | **១០០** | |

### បន្ទាត់ទី១០.២-តើអ្នកយកកូនស្រីមកជាមួយប៉ុន្មាននាក់?

| ចំនួនកូនស្រី | ប្រេកង់ | ភាគរយ | ភាគរយ បូកបន្ថែម |
|---|---|---|---|
| ១ | ៧ | ៧៧,៧ | ៧៧,៧ |
| ២ | ២ | ២២,៣ | ១០០ |
| **សរុប** | **៩** | **១០០** | |

### បន្ទាត់ទី១០.៣-តើអ្នកយកកូនប្រុសមកជាមួយប៉ុន្មាននាក់?

| ចំនួនកូនប្រុស | ប្រេកង់ | ភាគរយ | ភាគរយបូកបន្ថែម |
|---|---|---|---|
| ១ | ៧ | ១០០ | ១០០ |
| **សរុប** | **៧** | **១០០** | |

***ចំណាំ:*** *មានស្ត្រីខ្លះបាននាំកូនស្រីនិងកូនប្រុសមកជាមួយដែរ*

យោងទៅតាមលទ្ធផលនៃកិច្ចសំភាសន៍ គឺមានអ្នកសុំទានចំនួន៤៦%បាននាំកូនមកសុំទានជាមួយពួកគាត់ដែរ ។ គាត់បាននិយាយថាមូលហេតុដែលពួកគាត់នាំកូនយកមកជាមួយព្រោះ គាត់មានអារម្មណ៍ខ្មាសគេខ្លាំងណាស់នៅពេលដែលគាត់លើកដៃហើយសុំលុយអ្នកដ៏ទៃ១០០រៀលដើម្បីយកមកទិញបាយហូបនោះ ។ អ្នកសុំទានខ្លះ មិនហ៊ានសុំដោយខ្លួនឯងទេដោយសារតែគាត់មានអារម្មណ៍ខ្មាស ដូច្នេះគាត់បានសុំឱ្យកូនៗរបស់គាត់ជាអ្នកសុំហើយពួកគាត់ដើរតាមក្រោយខ្នងពួកគេ ។ ករណីសិក្សាខាងក្រោមនេះគឺជាតឹកតាងដែលបញ្ជាក់ថាម្តាយមិនបានដើរសុំទានដោយខ្លួនឯងទេប៉ុន្តែគាត់បានឱ្យកូនគាត់ជាអ្នករកលុយ ។

ពួកយើងមកដល់(ភ្នំពេញ) បាន៣ថ្ងៃហើយជារៀងរាល់ថ្ងៃខ្ញុំបាននាំកូនរបស់ខ្ញុំមកសុំនៅ ផ្សារតាប៉ាង នៅពេលទៅដល់ទីនោះខ្ញុំអត់ដើរសុំទេគឺឱ្យកូនរបស់ខ្ញុំទៅសុំម្នាក់ឯង ។នៅពេលបាយថ្ងៃត្រង់យើងត្រលប់ មកកន្លែងដែលយើងស្នាក់នៅ (មុខវាំង) និងទិញបាយ ម្ហូបដើម្បីញុំាទាំងអស់គ្នា បន្ទាប់មកយើងត្រលប់ទៅ ផ្សារតាប៉ាងម្តងទៀត ។ កូនទាំង២របស់ខ្ញុំក្នុងមួយថ្ងៃអាចរកបាន ១០០០-២០០០រៀល និង ពួកយើងចំណាយតែ១០០០រៀលសំរាប់ទិញបាយហូប ហើយសល់ពីនោះគឺសន្សំទុក ។ (ករណីសិក្សាទី៦)

ការពិត ស្ត្រីប្រឈមមុខទៅនិងស្ថានភាពដែលងាយនិងទទួលភាពរងគ្រោះជាងគេ ហើយមានឱកាសតិចតួចជាងបុរសនៅក្នុងសង្គមតាំងពីពេលដែលគាត់នៅក្មេងម្ល៉េះ ។ ក្មេងស្រីភាគច្រើនដែលឪពុកម្តាយនាំយកមកជាមួយដើម្បីដើរសុំទានគឺសុទ្ធសឹងតែជាក្មេងស្រីវ័យក្មេង ទោះបីជាគេនៅក្មេងក៏ដោយក៏ពួកគេនៅតែអាចជួយគ្រួសាររបស់គេ ។ ក្មេងស្រីទាំងនោះបានបោះបង់ចោលការសិក្សាហើយមកជាមួយម្តាយ/ឪពុកម្តាយដើម្បីរកប្រាក់កំរៃជួយផ្គត់ផ្គង់ម្តាយឪពុក និងបងប្អូនប្រុសរបស់ពួកគេ ។

ខ្ញុំជាស្ត្រីមេម៉ាយប្តីរបស់ខ្ញុំបានស្លាប់កាលពីឆ្នាំមុនដោយសារជំងឺលើសឈាមខ្ញុំមានកូន ៥នាក់ ស្រីពីរនិងប្រុសបីនាក់ ។ ខ្ញុំទើបតែមកភ្នំពេញក្នុងរយៈពេល៧ ខែកន្លងមកហើយ ជាមួយកូនស្រីពៅរបស់ខ្ញុំដែលមាន អាយុ៥ឆ្នាំ ។ កូន៧ផ្សេងទៀតរបស់ខ្ញុំរស់នៅឯភូមិ ហើយកូនបងគេបង្អស់ជាអ្នកមើលថែរក្សាប្អូន១ ។ ក្នុងរយៈពេលដែលខ្ញុំមិននៅផ្ទះ ប្រសិនបើពេលខ្លះដែលគេគ្មានអ្វីហូបទេនោះគឺអោយពួកគេសុំសាច់ញាតិនិងអ្នកនៅជិតខាងដើម្បីហូបរយៈពេលដែលខ្វះ ។ (ករណីសិក្សាទី៤)

ចំពោះករណីសិក្សាខាងលើបង្ហាញឱ្យឃើញថា ក្មេងស្រីតូចមួយនេះបានចាប់ផ្តើមរកលុយជួយផ្គត់ផ្គង់គ្រួសារបងប្អូនប្រុសបីនាក់និងបងស្រីតាំងពីនាងមានអាយុប្រាំឆ្នាំមកម្ល៉េះ នាងមិនដែលមានឱកាសចូលសាលារៀននិងទទួលការអប់រំដូចក្មេងស្រីដទៃទៀតឡើយ តើអនាគតនាងនិងក្លាយទៅជាយ៉ាងណា បើសិនជានាងមិនបានទទួលការអប់រំ ? ប្រសិនបើថ្ងៃណាមួយនាងមានជំងឺហើយនាងមិនអាចដើរសុំទានបាននោះ តើមានអ្វីនិងកើតឡើងចំពោះសមាជិកក្នុងគ្រួសាររបស់នាងដែលរស់នៅពឹងផ្អែកមកលើរូបនាង ? ក្មេងបីនាក់ទៀតដែលនៅចាំផ្ទះនៅពេលដែលម្តាយរបស់ពួកគេមកសុំទាននៅភ្នំពេញ គឺពួកគេពឹងផ្អែកទៅលើម្ហូបអាហារ អង្ករដែលអ្នកភូមិនិងសាច់ញាតិរបស់ពួកគេបានផ្តល់ឱ្យ ប្រសិនបើគ្មាននរណាគិតគួរអើពើ ហើយភ្លេចក្មេងទាំងបីនាក់នេះ តើពួកគេរស់នៅយ៉ាងដូចម្តេច ? ហើយក្មេងទំាងបីនាក់នេះនិងមិនមានឱកាសចូលសាលារៀនផងដែរ ។

# ការសន្និដ្ឋាន

ឆ្លងតាមរយៈលទ្ធផលនៃការចុះធ្វើការស្រាវជ្រាវ បានបង្ហាញឱ្យឃើញថាមានកត្តាជាច្រើនបានជំរុញអោយប្រជាជនយើងមួយចំនួនចាកចោលភូមិស្រុកដើម្បីមករកការងារធ្វើ ឬដើរសុំទានគេនៅក្នុងទីក្រុងដូចជា ភាពគ្មានដីធ្លី អំពើហឹង្សានៅក្នុងគ្រួសារ ខ្វះមធ្យោបាយនិងមិនអាចទទួលបានធនធាន ប្តីមិនទទួលខុសត្រូវក្នុងការជួយផ្គត់ផ្គង់គ្រួសារ ការជំពាក់បំណុល ភាពក្រីក្រ ភាពជាស្ត្រីមេម៉ាយ គ្រោះមហន្តរាយធម្មជាតិ ភាពគ្មានការងារធ្វើជាដើម ។

សេដ្ឋកិច្ចប្រទេសកម្ពុជាពឹងផ្អែកទៅលើកសិកម្មហើយប្រជាជនប្រហែលជា៩០%គឺជាកសិករ ។ ការកាប់បំផ្លាញព្រៃឈើខុសច្បាប់បានធ្វើឱ្យអាកាសធាតុមានការប្រែប្រួល ដែលជាហេតុធ្វើឱ្យប្រជាជនប្រឈមមុខទៅនឹងគ្រោះរាំងស្ងួតនិងគ្រោះទឹកជំនន់ៗជាប់គ្នារហូតដល់ ២-៣ឆ្នាំ នេះគឺជាមូលហេតុចំបងនៃការខូចខាតផលដំណាំរបស់ប្រជាជននិងធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាជនកាន់តែធ្លាក់ដុនដាបទៅៗ ។ ម្យ៉ាងវិញទៀតធនធានធម្មជាតិដែលប្រជាជនយើងអាចទទួលបានកាលពីមុខ ត្រូវបានដាក់ឱ្យក្លាយទៅជារបស់ឯកជន ធ្វើឱ្យប្រជាជនយើងគ្មានសិទ្ធិនឹងទទួលបានធនធានទាំងអស់នោះដូចកាលពីមុនបានឡើយ ប្រសិនបើពួកគាត់គ្មានលុយដើម្បីបង់ថ្លៃសេវាកម្ម ។

ប្រជាជនខ្លះ បានសំរេចចិត្តបញ្ចាំដីរបស់គាត់ទៅអ្នកចងការប្រាក់ ដើម្បីយកលុយមកចំណាយលើតំរូវការចាំបាច់ផ្សេងៗ ឬក៏បង់ថ្លៃសេវាសុខភាព ។ ចំណុចនេះធ្វើឱ្យប្រជាជនបាត់បង់ដីធ្លី ផ្ទះសំបែង សត្វពាហនៈ ហើយនៅទីបំផុត ពួកគេគ្មាននៅសល់អ្វីទៀតទេសំរាប់ចិញ្ចឹមជីវិតនៅក្នុងភូមិ ។ នៅពេលដែលគេគ្មានការងារធ្វើ គេក៏សំរេចចិត្តចេញទៅរកការងារធ្វើគឺការសុំទាននៅទីក្រុងឬនៅតាមបណ្តាលប្រទេសជិតខាងដូចជាប្រទេសថៃនិងប្រទេសវៀតណាមជាដើម ដើម្បីចិញ្ចឹមខ្លួនឯងនិងសមាជិកគ្រួសារ ។

នៅក្នុងករណីខ្លះទៀត យើងសង្កេតឃើញថាមានស្ត្រីមួយចំនួនទៀតបានចាកចេញពីផ្ទះមកសុំទាន ដោយសារប្តីរបស់ពួកគេប្រើអំណាចជាប្តី/មនុស្សប្រុស វាយធ្វើបាបប្រពន្ធកូន ។ មិនតែប៉ុណ្ណោះ ប្តីគាត់មិនទទួលខុសត្រូវក្នុងការជួយឧបត្ថម្ភក្នុងគ្រួសារ ប៉ុន្តែគាត់គ្រាន់តែដើរផឹកស៊ីជាមួយមិត្តភក្តិ មានស្ត្រីថ្មី ហើយបុរសខ្លះទៀតបានចំលងមេរោគអេដស៍ដល់កូននិងប្រពន្ធនៅផ្ទះថែមទៀតផង ។ តើចំនុចនេះ បង្ហាញពីសមភាពយេនឌ័រដែរឬទេ ? តើពេលណាទៅ ទើបបុរសះចេះភ្ញាក់ខ្លួនហើយអាណិតប្រពន្ធកូន ? នៅពេល ដែលគាត់

ធ្លាក់ខ្លួនឈឺដោយសារតែជំងឺនេះ តើនរណាជាអ្នកទទួលខុសត្រូវចិញ្ចឹមបីបាច់ថែរក្សាកូនៗរបស់គាត់ បន្ទាប់ពីពួកគាត់ស្លាប់ទៅនោះ ? បន្ទុកដ៏ធ្ងន់នេះ ត្រូវធ្លាក់ទៅលើជីដូនជីតាដែលមានវ័យចាស់ជរាជាអ្នកចិញ្ចឹមចៅៗបន្តក្រោយពេលដែលឪពុកម្តាយក្មេងៗទាំងនោះបានស្លាប់ទៅ ។ នៅក្នុងករណីជាច្រើន ស្ត្រីគឺជាជនរងគ្រោះនៅគ្រប់ស្ថានការទាំងអស់ពីព្រោះស្ត្រីគឺជាមនុស្សដែលគ្មានអំណាចនៅក្នុងគ្រួសារ ទោះបីជាស្ត្រីមានការទទួលខុសត្រូវច្រើននៅក្នុងគ្រួសារក៏ដោយ ។

នៅពេលដែលបុរសជាប្តី ដែលមានចំនែកនៅក្នុងបញ្ហាជាច្រើនដែលកើតឡើងនៅក្នុងគ្រួសារ មិនទទួលខុសត្រូវនៅក្នុងគ្រួសារ មានន័យថាស្ត្រីទទួលបន្ទុកធ្ងន់ក្នុងការរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់គ្រួសារ ។ នៅក្នុងគ្រួសាររបស់អ្នកសុំទានខ្លះ ប្តីជាអ្នករកប្រាក់ចំណូល ប៉ុន្តែគាត់មិនជួយផ្គត់ផ្គង់គ្រួសារទេ ។ គាត់យកលុយនោះទៅប្រើសំរាប់តែការស៊ីផឹកជាមួយមិត្តភក្តិ ហើយនៅពេលដែលស្រវឹង គឺគាត់វាយប្រពន្ធ កូន ។ ហេតុដូចនេះហើយ បានជានៅក្នុងគ្រួសាររបស់អ្នកសុំទាន ដែលដូចជាគ្រួសារជាច្រើននៅក្នុងប្រទេសកម្ពុជាដែរ ទោះបីជាចំណងអាពាហ៍ពិពាហ៍នៅស្ថិតស្ថេរក៏ដោយ ស្ត្រីជាប្រពន្ធរងទុក្ខវេទនាយ៉ាងខ្លាំងពីអំពើហឹង្សានៅក្នុងគ្រួសារ ។

កុមារីដែលត្រូវបានឪពុកម្តាយនាំយកមកជាមួយដើម្បីមកសុំទាននៅក្នុងទីក្រុងភ្នំពេញ បាត់បង់ឱកាសក្នុងការក្នុងការទទួលបានការសិក្សារៀនសូត្រ ហើយនៅថ្ងៃអនាគត ពួកគេនឹងក្លាយជាមនុស្សមិនចេះអក្សរ ។ អនាគតរបស់ក្មេងស្រីទាំងនេះគឺប្រហាក់ប្រហែលនឹងម្តាយរបស់គេដែរ ពីព្រោះថាពួកគេមិនចេះអក្សរហើយវាគឺជាការលំបាកណាស់សំរាប់ក្មេងស្រីទាំងនេះក្នុងការស្វែងរកការងារធ្វើនៅពេលដែលពួកគេធំឡើង ព្រោះនៅជំនាន់របស់ពួកគេនឹងមានអ្នកដែលទទួលការអប់រំល្អៗជាច្រើន ។

ការដែលក្លាយខ្លួនជាអ្នកសុំទានគឺបានបន្សល់ទុកនូវស្លាកស្នាមដ៏អាក្រក់នៅក្នុងជីវិត ។ អ្នកសុំទានតែងតែទទួលរងនូវការរើសអើងពីសំណាក់មនុស្សនៅគ្រប់កន្លែងទាំងអស់: ការរើសអើងពីសង្គម សហគមន៍ ក៏ដូចជានៅក្នុងក្រុមគ្រួសារនិងញាតិសន្តានរបស់គេផងដែរ ។ អ្នកដទៃទៀត ដែលមិនមែនជាអ្នកសុំទានអាចនិយាយពាក្យពេចន៍អ្វីក៏បានដែរ ដែលធ្វើឱ្យអ្នកសុំទានមានការឈឺចាប់ពីព្រោះពួកគេមិននៅក្នុងស្ថានភាពដែលអ្នកសុំទានទាំងនោះកំពុងជួបប្រទះ ។ ពួកគេមិនដឹងថា តើទុក្ខវេទនានៃការគ្មានបាយហូបនោះ វាយ៉ាងណា ពីព្រោះពួកគេមិនដែលមានអារម្មណ៍ដូចនោះ ។ ការរើសអើងទាំងនេះ ធ្វើឱ្យអ្នកសុំទានបាត់បង់នូវជំនឿទុកចិត្តលើខ្លួនឯង ពីព្រោះថា តាមរយៈការសំភាសន៍យើងសង្កេតឃើញថា អ្នកសុំទានទាំងនោះមិនហ៊ានប្រាប់ប្រជាជននៅក្នុងសហគមន៍ថា ពួកគេមកភ្នំពេញដើម្បីសុំទាននោះទេ ។ ពួកគេលាក់មុខរបស់គេដែលធ្វើជាអ្នកសុំទាន

ពីអ្នកនៅជុំវិញខ្លួន ពីព្រោះពួកគេដឹងយ៉ាងច្បាស់ថា បើសិនជាអ្នកដទៃដឹងថា ស្ត្រីទាំងនោះជាអ្នកសុំទានពួកគេ នឹងរើសអើង ហើយក្រុមនេះ នឹងបន្តលាក់មុខរបស់គេតទៅទៀត ហើយយើងទាំងអស់គ្នានឹងមិនដឹងថា តើពួកគេរងទុក្ខវេទនាយ៉ាងណានៅក្នុងជីវិត ? តើហេតុអ្វីបានជាពួកគេស្ថិតនៅក្នុងស្ថានភាពដ៏អាក្រក់បែបនេះ ? តើហេតុអ្វីបានជាពួកគេសំរេចចិត្តជ្រើសរើសយកមុខរបរសុំទានដែលមនុស្សទូទៅនៅក្នុងសង្គមមិនផ្ដល់តំលៃឱ្យដូចនេះ ?

ស្ត្រីគឺជាក្រុមមនុស្សដែលងាយទទួលរងគ្រោះជាងគេនៅក្នុងសង្គម ប៉ុន្តែពួកគេគឺជាធនធានដ៏មានតំលៃដែលមានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមនៅក្នុងការងារអភិវឌ្ឍន៍ប្រទេសជាតិ ។ ប្រសិនបើស្ត្រីប្រឈមមុខទៅនឹងការរើសអើង ហើយពួកគេមិនត្រូវបានអ្នកដទៃផ្ដល់តំលៃនឹងទទួលស្គាល់នោះ វាគឺជាការលំបាកមួយក្នុងការអភិវឌ្ឍន៍ឬធ្វើការផ្លាស់ប្ដូរអ្វីមួយនៅក្នុងសង្គម ។ បន្ថែមពីលើនេះទៀត ស្ត្រីគឺជាមាតាម្នាក់នៅក្នុងគ្រួសារ ហើយប្រសិនបើនាងបាត់បង់ជំនឿចិត្តលើខ្លួនឯង គឺវាធ្វើឱ្យមានការប៉ះពាល់យ៉ាងខ្លាំងទៅលើការអប់រំកូនចៅនៅក្នុងគ្រួសារ ។

**រូបទី២: មូលហេតុដែលខ្ញុំមកសុំទាននៅទីក្រុង**

